ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សន្និបាត

## បូកសរុបលទ្ធផលការងារ
## អប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ
## ឆ្នាំសិក្សា ២០១៦-២០១៧ និងទិសដៅ
## ឆ្នាំសិក្សា ២០១៧-២០១៨

ថ្ងៃទី២៤-២៥ ខែមករា ឆ្នាំ២០១៨

# អារម្ភកថា

ជារៀងរាល់ឆ្នាំ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា ប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបង្ហាញពីលទ្ធផលការងារដែលបានអនុវត្តពេញមួយឆ្នាំកន្លងមក ពិសេសបង្ហាញពីការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ និងបញ្ហាប្រឈមនានា ដែលបានកើតឡើង ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៥.២០១៧ ក្នុងនោះដែរមន្ទីរអប់រំយុវជននិងកីឡាខេត្តបានខិតខំអនុវត្តនូវសកម្មភាពនានាឱ្យសម្រេចបានតាមការគ្រោងទុក។

ក្នុងឆ្នាំសិក្សា២០១៦.២០១៧មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សម្រេចបានសមិទ្ធផលជាច្រើនទៅតាមអនុវិស័យគឺ ៖

១.អនុវិស័យ ការអប់រំកុមារតូច ២.អនុវិស័យ ការអប់រំបឋមសិក្សា ៣.អនុវិស័យ ការអប់រំមធ្យមសិក្សា ៤.អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ ៥.អនុវិស័យ ការអភិវឌ្ឍយុវជន ៦.អនុវិស័យ ការអប់រំកាយ និងកីឡា។ លទ្ធផលអនុវិស័យទាំង៦នេះ គឺបានបង្ហាញអំពីការចូលរួមចំណែកការអនុវត្តគោលនយោបាយ កំណែទម្រង់វិស័យអប់រំទាំង ១៥ចំណុច និងចំនុចដៅនៃសូចនាករ ដែលបានដាក់ចេញដោយ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមានការចូលរួមពី អាជ្ញាធរដែនដី មន្ទីរពាក់ព័ន្ធសប្បុរសជននានាដៃគូអភិវឌ្ឍន៍ក្នុងវិស័យអប់រំធ្វើឱ្យវិស័យអប់រំមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមន្ត្រីជំនាញទាំងអស់ មន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍនានា ដែលបានចូលរួមយ៉ាងសកម្ម និង ជួយគាំទ្រទាំងផ្នែកបច្ចេកទេស សម្ភារៈ និងថវិកាដល់ដំណើរការរៀបចំសន្និបាតបូកសរុប វាយតម្លៃការងារ អប់រំ យុវជន និងកីឡា ទទួលបានលទ្ធផលល្អតាមកម្មវិធី ដែលបានគ្រោងទុក។

ថ្ងៃពុធ ៨-៩ កើត ខែមាឃ ឆ្នាំរកា ឧព្វស័ក, ព.ស ២៥៦១
ឧត្តរមានជ័យ-ថ្ងៃទី២៤-២៥ ខែមករា ឆ្នាំ២០១៨

# មាតិកា


អារម្ភកថា ........ i

មាតិកា ........ ii

១-សេចក្តីផ្តើម ........ - 1 -

២-វឌ្ឍនភាព ........ - 3 -

២-១-លទ្ធផលរួមរបស់ វិស័យអប់រំ យុវជន និង កីឡា ........ - 3 -

២-១-១-វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល និង ចំណុចដៅសម្រាប់ឆ្នាំសិក្សា ២០១៧.-២០១៨ ........ - 3 -

២-២-១--.២០១៥វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៦ ........ - 3 -

២-៣-១- វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់អាទិភាព ទាំង១៥ ........ - 4 -

២-១-៤-វឌ្ឍនភាពនៃការគ្រប់គ្រង និង ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ........ - 9 -

២-៥-១--២០១៧វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិ ........ - 16 -

២២--លទ្ធផលតាមអនុវិស័យ ........ - 17 -

២-២-១--១-អនុវិស័យ ការអប់រំកុមារតូច ........ - 17 -

២-២-២- អនុវិស័យ ការអប់រំបឋមសិក្សា ........ - 20 -

២អនុវិស័យ-៣-២- ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស ........ - 28 -

២-៤-២--អនុវិស័យការអប់រំក្រៅប្រព័ន្ធ ........ - 36 -

២-៥-២- អនុវិស័យ ការអភិវឌ្ឍយុវជន ........ - 40 -

២-២-៦-អនុវិស័យ ការអប់រំកាយ និងកីឡា ........ - 45 -

២-៧-២- ការងារផែនការ និង គ្រប់គ្រងជំនួយ ........ - 48 -

២-៨-២- ការងាររដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល ........ - 50 -

២-៩-២- ការិយាល័យ គណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ ........ - 53 -

២-១០-២- ការិយាល័យ អធិការកិច្ច ........ - 56 -

៣-អនុសាសន៍ និង ទិសដៅ ឆ្នាំសិក្សា ២០១៧.២០១៨ ........ - 58 -

៣-១-ទិសដៅតាមអនុវិស័យ ........ - 58 -

៣-១-១-អនុវិស័យ ការអប់រំកុមារតូច ........ - 58 -

៣-១-២-អនុវិស័យ ការអប់រំបឋមសិក្សា........ - 58 -

៣-១-៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និង អប់រំបច្ចេកទេស ........ - 59 -

៣-១-៤ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ ........ - 59 -

៣-១-៥ អនុវិស័យ ការអភិវឌ្ឍយុវជន........ - 60 -

៣-១-៦ អនុវិស័យ ការអប់រំកាយ និងកីឡា........ - 60 -

៣-២- ទិសដៅឆ្លងអនុវិស័យ........ - 61 -

៣-២-១-ការងាររដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល........ - 61 -

៣-២-២-ការងារផែនការ និង គ្រប់គ្រងជំនួយ ........ - 61 -

៣-២-៣-ការងារសំណង់........ - 62 -

៣-២-៤-ការិយាល័យ គណនេយ្យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ ........ - 62 -

៣-២-៥ ការងារសុខភាពសិក្សា........ - 63 -

៣-២-៦ ការងារអធិការកិច្ច ........ - 63 -

៣-៣-សំណូមពរ........ - 64 -

៣-៤- លទ្ធផលនៃការពិភាក្សាលើប្រធានបទ និង ទិសដៅត្រូវអនុវត្តឆ្នាំសិក្សា ២០១៧-២០១៨........ - 65 -

៤សេចក្តីសន្និដ្ឋាន-........ - 65 -

# របាយការណ៍

## សន្និបាតបូកសរុប វាយតម្លៃលទ្ធផលការងារ អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៦-២០១៧ និង ទិសដៅការងារឆ្នាំសិក្សា ២០១៧-២០១៨

### ១-សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យ ជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង ២៥ ដែលស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា មានចំងាយ ៤៦៩ គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៥ ខាងជើងជាប់ និងប្រទេសថៃខាងត្បូងជាប់ និងខេត្តសៀមរាប ខាងលិចជាប់ និងខេត្តបន្ទាយមានជ័យ ខាងកើតជាប់និងខេត្តព្រះវិហារ មានផ្ទៃដី ៦,៨៤០.៩១គីឡូម៉ែត្រការេ ក្រុង១ ស្រុក៤ សង្កាត់៥ ឃុំមាន១៩ ភូមិមាន ៣០៤ គ្រួសារ ៥៧,២២៨ ប្រជាជនសរុប ២៤៣,៨០២នាក់ ស្រី១២០,១៩៤នាក់ ប្រជាពលរដ្ឋមានអាយុ១៨ឆ្នាំឡើងមាន ១៤៤២៤៧នាក់ ប្រជាពលរដ្ឋចំណាកស្រុក ទៅក្រៅប្រទេស ១៦៧៩៥នាក់ (ទិន្នន័យរបាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្តខែមករា ឆ្នាំ២០១៧ ) សាលារៀនសរុបមានចំនួន ៣៤៨សាលា កើន០៨សាលា ថ្នាក់រៀន១៩១៥ កើន១០១ថ្នាក់ សិស្សានុសិស្សសរុបចំនួន ៥២ ៩៣២នាក់ ស្រី ២៥ ៨៣២នាក់ ថយ ២៧៥នាក់ ស្រី ២១២នាក់ បុគ្គលិកអប់រំសរុប១៨៩១ នាក់ ស្រី ៧២៥ នាក់កើន២៦នាក់ ស្រី២៩នាក់ ។

ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ មន្ទីរ អប់រំយុវជន និងកីឡាខេត្ត កំពុងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអបរំ ២០១៤-២០១៨ និង បានអនុវត្តតាមគោលដៅទី៤ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០១៣០ ស្តីពីការអប់រំនៅកម្ពុជា ៖

- **គោលនយោបាយទី ១៖** ***ធានាការអប់រំប្រកបដោយគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ននិង លើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ។***
- **គោលនយោបាយទី ២៖** ***ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ។***

វឌ្ឍនភាពនៃការអនុវត្ត និង ការពិនិត្យតាមដានតាមរយៈ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៥.២០១៧ ផែនការយុទ្ធសាស្ត្រថវិកា២០១៧.២០១៩ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ បានបង្ហាញក្នុងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០១៧ និង បានឆ្លុះបញ្ចាំងក្នុងខ្លឹមសារ សូចនាករស្នូលនៃរបាយការណ៍សន្និបាតអប់រំពី វឌ្ឍនភាព បញ្ហាប្រឈម អនុសាសន៍ និងទិសដៅនានា ដែលបានជួបប្រទះកន្លងមក ។ របាយការណ៍នេះមានសារៈសំខាន់ណាស់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យ

អប់រំ ផែនការយុទ្ធសាស្ត្រថវិកា ផែនការវិនិយោគបីឆ្នាំរំកិល ផែនការប្រតិបត្តិប្រចាំឆ្នាំ និងការរៀបចំផែនការផ្សេងៗទៀត សំដៅអភិវឌ្ឍវិស័យអប់រំឱ្យឆ្លើយតប នឹង ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។ កន្លងមកនេះ វិស័យអប់រំក្នុងខេត្តមានការរីកចម្រើនដោយមានការជួយឧបត្ថម្ភគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា សប្បុរសជន សហគមន៍ ព្រមទាំងមានចូលរួមពីមន្ទីរពាក់ព័ន្ធ និងមានការខិតខំប្រឹងប្រែងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដែលមានលទ្ធផលអប់រំឆ្នាំសិក្សា២០១៧-២០១៨ បញ្ជាក់ដូចតទៅ ៖

**ក.សាលារៀនសរុបមានចំនួន ៣៤៨សាលា កើន០៨សាលា ថ្នាក់រៀន១៩១៥ កើន១០១ថ្នាក់**

- មត្តេយ្យក្នុងបឋមសិក្សាសរុបមានចំនួន៩៧សាលាមាន១១៧ ថ្នាក់ កើន០៣សាលា និង១០ថ្នាក់
- សាលាបឋមសិក្សាសរុបមានចំនួន២១៤សាលា មាន ១៤៧៨ ថ្នាក់ កើន០៤សាលា និង៣៩ថ្នាក់
- អនុវិទ្យាល័យសរុបចំនួន ២៨សាលា មាន ១៩៧ ថ្នាក់ ថយ០១សាលា និងថយ២១ថ្នាក់
- វិទ្យាល័យសរុបចំនួន ០៩សាលា មាន ១២៣ ថ្នាក់ កើន០២សាលា និង៤៥ថ្នាក់

**ខ.សិស្សានុសិស្សសរុបចំនួន ៥២ ៩៣២នាក់ ស្រី ២៥ ៨៣២នាក់ ថយ ២៧៥នាក់ ស្រី ២១២នាក់**

- សិក្សាមត្តេយ្យសិក្សាចំនួន ៣៣៨៥ នាក់ ស្រី ១៦៩០ នាក់ កើន៣៣៣នាក់ ស្រី១៨៤នាក់
- សិស្សបឋមសិក្សាមានចំនួន ៣៦៩៣៧នាក់ ស្រី ១៧៧៣៥ នាក់ កើន២៦នាក់ ស្រី១៧នាក់
- សិស្សអនុវិទ្យាល័យមានចំនួន ៩០៥៨ នាក់ ស្រី ៤៦១១នាក់ ថយ១០៣៨នាក់ ស្រី៥៩៨នាក់

  សិស្សវិទ្យាល័យមានចំនួន ៣៥៥២ នាក់ ស្រី ១៧៩៦នាក់ កើន៤០៤នាក់ ស្រី១៨៥នាក់

**គ.បុគ្គលិកអប់រំសរុប១៨៩១ នាក់ ស្រី ៧២៥ នាក់ កើន២៦នាក់ ស្រី២៩នាក់**

- បុគ្គលិកមន្ទីរអប់រំមានចំនួន ៥០ នាក់ ស្រី ១២ នាក់
- បុគ្គលិកការិ.ក្រុង/ស្រុក ៦៣ នាក់ ស្រី ០៩ នាក់
- បុគ្គលិកសាលាមត្តេយ្យក្នុងបឋមសរុបចំនួន ៤៧ នាក់ ស្រី ៤៦ នាក់
- បុគ្គលិកសាលាបឋមសិក្សាសរុបចំនួន ១១២៤ នាក់ ស្រី ៤៧៤ នាក់
- បុគ្គលិកអនុវិទ្យាល័យសរុប ៤៩១ នាក់ ស្រី ១៦៣ នាក់
- បុគ្គលិកវិទ្យាល័យសរុប ១១៦ នាក់ ស្រី ២១ នាក់
- ពលករបណ្តែតសរុបមានចំនួន ០៦ នាក់ ស្រី ០២ នាក់(មិនរាប់បញ្ចូល)

# ២-វឌ្ឍនភាព

## ២-១-លទ្ធផលរួមរបស់ វិស័យអប់រំ យុវជន និង កីឡា

### ២-១-១-វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល និង ចំណុចដៅសម្រាប់ឆ្នាំសិក្សា ២០១៧.២០១៨

| សូចនាករស្នូល | ស្ថានភាព ២០១៦.១៧ | ចំណុចដៅ ២០១៧.១៨ | ជាក់ស្តែង ២០១៧.១៨ |
|---|---|---|---|
| **គោលនយោបាយទី ១ ៖ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និង លើកកម្ពស់ឱកាស សិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា** | | | |
| ១.ភាគរយកុមារអាយុ៥ឆ្នាំក្នុងការអប់រំកុមារតូច គ្រប់រូបភាព | 44% | 48% | 55% |
| ២.ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋម សិក្សាយ៉ាងតិច ៨០ភាគរយ | 1/5 | 5 | 1/5 |
| ៣.ចំនួនស្រុកដែលបានសម្រេចអត្រាមធ្យមសិក្សា បឋមភូមិយ៉ាងតិច ៨០ភាគរយ | 0/5 | 5 | 0/5 |
| ៤.អត្រាអក្ខរជនពេញវ័យ (អាយុ ១៥ឡើង) | 92% | 92,5% | 92,5% |
| ៥.ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | | | |
| ការអាន | na | na | na |
| គណិតវិទ្យា | na | Na | na |
| ៦.ចំនួនគ្រឹះស្ថាន សិក្សាបានធ្វើការវាយតម្លៃ | 8 | 10 | 0 |
| **គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់** | | | |
| ៧.ចំនួនគ្រូបង្រៀនបានចូលរួមថ្នាក់ពន្លឿន | 16 | 20 | 20% |
| ៨.ចំនួននាយកសាលាបានបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល | 20 | 20 | 90% |
| ៩.ភាគរយនៃការទូទាត់ថវិកា កម្មវិធីប្រចាំឆ្នាំ | 92 ,71% | 98% | 96,63% |

### ២-១-២-វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៥.២០១៦

ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានទិសដៅសន្និបាតសរុប ១៤៧ បានអនុវត្តទិសដៅចំនួន ១៣៤ ។

| អនុវិស័យ/ឆ្លងអនុវិស័យ | សកម្មភាព | បានអនុវត្ត | សេចក្តីបញ្ជាក់ |
|---|---|---|---|
| **១-អនុវិស័យ** | | | |
| ១.១ ការអប់រំកុមារតូច | 24 | 22 | 2គ្មានថវិកា |
| ១.២ ការអប់រំបឋមសិក្សា | 19 | 18 | |
| ១.៣ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | 15 | 13 | 2គ្មានថវិកាអនុវត្ត |
| ១.៤ ការអប់រំក្រៅប្រព័ន្ធ | 15 | 13 | 2គ្មានដៃគូឧបត្ថម្ភ |
| ១.៥ ការអភិវឌ្ឍយុវជន | 22 | 19 | |
| ១.៦ ការងារអប់រំកាយ និងកីឡា | 15 | 12 | |
| **២-ឆ្លងអនុវិស័យ** | | | |
| ២-១-ការិយាល័យ រដ្ឋបាលបុគ្គលិក និងបណ្តុះបណ្តាល | 6 | 6 | |
| ២-២-ការិយាល័យ ផែនការ | 12 | 12 | |
| ២-៣-ការិយាល័យ គណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ | 13 | 13 | |
| ២-៤-ការិយាល័យ អធិការកិច្ច | 6 | 6 | |
| **សរុប** | 147 | 134 | |

## ២-១-៣- វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់អាទិភាព ទាំង១៥

មន្ទីរអប់រំយុវជន និងកីឡាខេត្តបាន និង កំពុងអនុវត្ត កំណែទម្រង់លើវិស័យអប់រំ យុវជន និង កីឡា ដូចខាងក្រោម៖

- កំណែទម្រង់ទី ១ ៖ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
  - បានបែងចែកផែនការថវិកាPB និងSIG តាមក្រុង/ស្រុកទាំង០៥ក្នុងខេត្តតាមប្រព័ន្ធធនាគារ
  - បានចុះពិនិត្យតាមការអនុវត្តថវិកានៃកិច្ចបញ្ជិការទាំង៦មុខ តាមក្រុងស្រុក និងសាលារៀន
  - បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១
  - បានរៀបចំផែនការប្រតិបត្តិឆ្នាំ២០១៧
  - បានប្រជុំណែនាំពីនិតិវិធីរៀបចំជម្រះសម្ភារចេញពីបញ្ជីសារពើភ័ណ្ឌដល់ការិយាល័យជំនាញ ក្រុងស្រុក និងសាលារៀនទូទាំងខេត្ត
  - ប្រជុំណែនាំពីនិតិវិធីរៀបចំគម្រោងថវិកាឆ្នាំ២០១៨ តាមកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព នីមួយៗ នៃអនុវិស័យទាំង៦ និងការិយល័យគាំទ្រ
  - មានការផ្សព្វផ្សាយ អនុក្រឹត្យ ប្រកាសអន្តរក្រសួង ប្រកាស សារាចរណែនាំ និងលិខិតបទដ្ឋានផ្សេងៗ ដើម្បីគាំទ្រក្នុងការអនុវត្ត របស់អង្គភាពថវិកា ឱ្យឆ្លើយតបទៅ នឹងកណែទម្រងហិរញ្ញវត្ថុ ដំណាក់កាល ទី3 ថវិកាផ្សាភ្ជាប់និងគោលនយោបាយ
  - អង្គភាពថវិកាជាអ្នករៀបចំប្រមូលឯកសារចំណូលចំណាយ និងលិខិតយុត្តិការផ្សេងៗដើម្បីរៀនចំបោះផ្សាយអាណត្តិបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ និង ស្នើសុំថវិកាដំណើរការសាលារៀនសាធារណៈទូទាំងខេត្តប្រចាំត្រីមាសនីមួយៗ រួចបញ្ចូលតាមគណនីសាលានៃដើមត្រីមាស
  - បានផ្តល់ថវិកាគាំទ្រសមមូល មសស តាមការិយាល័យស្រុកទាំង០៥និងបានបើកប្រាក់អាហារូបករណ៍សិស្សក្រីក្រ ១០០នាក់ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ ។
  - អង្គភាពថវិកាបានពិនិត្យនិងផ្ទៀតផ្ទាត់ លើតារាងកើន ថយ សម្ភារ បរិក្ខាបច្ចេកទេស សង្ហារឹម គ្រឿងយន្ត និងអគារ ប្រចាំឆ្នាំ២០១៧ នៅមន្ទីរ ក្រុងស្រុក
  - បានរៀបចំនិតិវិធីជម្រះសម្ភារៈចេញពីបញ្ជីសារពើភ័ណ្ឌ (ដល់សាលាខេត្ត)
  - អង្គភាពថវិកាបានចូលរួមប្រជុំលើរបាយការណ៍អាជ្ញាធរសវនកម្មជាតិ បំប៉នធ្វើ

របាយការណ៍ស្តង់ដាបំប៉នធ្វើផែនការថវិកាសាលារៀនរបាយការណ៍តាមប្រព័ន្ធពត៌/ម្ភារបំប៉នស្តីពីការគ្រប់គ្រងស/មានវិទ្យា និងទ្រព្យសម្បត្តិ រដ្ឋប្រជុំបូកសរុបការអនុវត្ត / ២០១៨បចំផែនការលទ្ធកម្មប្រចាំឆ្នាំ រៀ / ថវិកាកន្លងមក

- បានបើកវគ្គបំប៉នស្តីពីការពង្រឹងឡើងវិញលើកិច្ចបញ្ជិកាទាំង៦មុខ ណែនាំពីមាតិកាថវិកាថ្មីប្រកាស លេខៈ៥២៣ សម្រាប់អនុវត្តឆ្នាំ២០១៨ និងការគ្រប់គ្រប់សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ ។

> កំណែទម្រង់ទី២៖ ការពង្រាយគ្រូបង្រៀន

- បានបែងចែកគំរូកម្មវិធីសមមូលទៅតាមក្រុងនាក់ កម្មវិធីអក្ខរកម្មចំនួន១០ស្រុកចំនួន/នាក់ គ្រូកម្មវិធីចូលរៀនឡើងវិញ០៦នាក់ និង គ្រូកម្មវិ ធីបង្កើនប្រាក់ចំណូលចំនួន២៤នាក់២៤
- ពង្រាយគ្រូក្នុងខេត្ត០១នាក់ ឆ្លងស្រុក១នាក់ ឆ្លងខេត្ត ១នាក់ ។

> កំណែទម្រង់ទី៤៖ ការលើកកម្ពស់គុណវុឌ្ឍគ្រូបង្រៀន

- បានបំប៉នវិធីសាស្រ្តបង្រៀនមនុស្សពេញវ័យដល់គ្រូអក្ខរកម្មចំនួន២៤នាក់មានរយៈពេល៥ថ្ងៃ និងបំ ប៉នគ្រូ ចូលរៀនឡើងវិញ២៤នាក់ចំនួន៣ថ្ងៃ
- បានជ្រើសរើសវាយតម្លៃគ្រូបឋមដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិ យភូមិចំនួន ២៤នាក់ ទៅបំ ប៉នជាគ្រូកម្រិតមូលដ្ឋាន និងជ្រើសរើសគ្រូកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញា បត្រ ចំនួន១៩នាក់ បំប៉ន នៅវិទ្យាស្ថានជាតិអប់រំ
- បើកវគ្គសិក្ខាសាលាស្តីពីការបង្រៀនថ្នាក់គួបដែលមានសិក្ខាកាម៨៤នាក់ ស្រី២០នាក់
- បានបញ្ជូនបុគ្គលិកមន្ទីរអប់រំ ០១ រូបចូលរៀន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ពីជំនាញគ្រប់គ្រងអប់រំ
- គ្រូបង្រៀន ២រូបបានប្រឡងជាប់ និងបានចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ពីជំនាញគ្រប់គ្រងអប់រំ
- បានបណ្តុះបណ្តាលគ្រូបង្រៀនលើជំនាញភាសាបរទេស
- បានបញ្ជូនគ្រូបង្រៀន ចូលរួមវគ្គគ្រប់គ្រងនាយកសាលាបឋមសិក្សា
- បានបញ្ជូនមធ្យមសិក្សាបឋមភូមិពន្លឿនជាគ្រូកម្រិតឧត្តមនៅវិទ្យាស្ថានជាតិអប់រំ
- ការលើកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន បានជ្រើសរើសវាយតម្លៃគ្រូបឋមដែលមានសញ្ញាបត្រ

- មធ្យមសិក្សាទុតិយភូមិ ចំនួន ២៤ នាក់ ទៅបំប៉នជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន ៣រូប ចូលរៀនកម្មវិធីពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ

➢ កំណែទម្រង់ទី ៥ ៖ការងារអធិការកិច្ច

- ចុះអធិការកិច្ចតាមប្រព័ន្ធ អធិការកិច្ចថ្មី ដោយអធិការកិច្ចតាមកាលកំណត់
- សហការធ្វើតេស្តលទ្ធផលសិក្សារបស់សិស្ស ថ្នាក់ជាតិ (ថ្នាក់ទី៦ និងទី៨ )និងតេស្តអន្តរជាតិ សម្រាប់ការអភិវឌ្ឍ(PISAD)ថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ។
- ផ្សព្វផ្សាយយលទ្ធផលអធិការកិច្ចនិងលទ្ធផលតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៦ និងថ្នាក់ទី៨ ។

➢ កំណែទម្រង់ទី៦ ៖ វង្វាយតម្លៃលទ្ធផលសិក្សា

បឋមសិក្សា ៖ ជាប់មធ្យមភាគ82,1កើន %0,72ធ្លាក់មធ្យមភាគ %11,71ថយ %0,94 % បោះបង់6,27កើន %0,22នៅបឋមសិក្សា

- បានរៀបចំផែនការចុះធ្វើតេស្តវាយតម្លៃចំនួន១០សាលា(សាលា០៣ធ្វើបាន)
- លទ្ធផល នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម័យប្រឡង ៖០៧ សីហា ២០១៧
  - ✓ បេក្ខជនសរុប១៨៧២នាក់ ស្រី៩៧៨នាក់ ប្រឡងជាប់១៦៩៣នាក់ ស្រី៨៨៩នាក់ ស្មើនឹង៩០.៤៤% ស្រី៩០.៩០% ។
- លទ្ធផល នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖ ២១ សីហា ២០១៧
  - ✓ បេក្ខជនសរុប៩៤០នាក់ ស្រី៤៤៧នាក់ ប្រឡងជាប់៨៣៦នាក់ ស្រី៤១៤នាក់ ស្មើនឹង ៨៨.៩៤%ស្រី៩២.៦២% ។
  - ✓ ក្នុងនោះនិទ្ទេសA ០០ នាក់ និទ្ទេសB ១១នាក់ស្រី០៤នាក់ និទ្ទេសC ៧០នាក់ស្រី៣៧នាក់ និទ្ទេសD ១៦៧នាក់ស្រី៩០នាក់ និងនិទ្ទេសE ៥៨៨នាក់ស្រី២៨៣នាក់ ។

➢ កំណែទម្រង់ទី ៧ ៖កំណែទម្រង់ការប្រឡង

- លទ្ធផល នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម័យប្រឡង ៖០៧ សីហា ២០១៧

- ✓ បេក្ខជនសរុប១៨៧២នាក់ ស្រី៩៧៨នាក់ ប្រឡងជាប់១៦៩៣នាក់ ស្រី៨៨៩នាក់ ស្មើនឹង៩០.៤៥% ស្រី៩០.៩០% ។

- លទ្ធផល នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖ ២១ សីហា ២០១៧
  - ✓ បេក្ខជនសរុប៩៤០នាក់ ស្រី៤៤៧នាក់ ប្រឡងជាប់៨៣៦នាក់ ស្រី៤១៤នាក់ ស្មើនឹង ៨៨.៩៥%ស្រី៩២.៦២% ។
  - ✓ ក្នុងនោះនិទ្ទេសA ០០ នាក់ និទ្ទេសB ១១នាក់ស្រី០៤នាក់ និទ្ទេសC ៧០នាក់ស្រី៣៧នាក់ និទ្ទេសD ១៦៧នាក់ស្រី៩០នាក់ និងនិទ្ទេសE ៥៨៨នាក់ស្រី២៨៣នាក់ ។
- បានរៀបចំការប្រឡងសិស្សពូកែថ្នាក់ខេត្ត និងដឹកនាំសិស្សចំនួន នាក់ចូលរួមប្រឡងថ្នាក់ជាតិ
  - ✓ ប្រឡងសិស្សពូកែថ្នាក់ខេត្តៈ បឋមភូមិ១០២នាក់ ស្រី៥៨នាក់ និង ទុតិយភូមិ២៩នាក់ ស្រី០៨នាក់ ។
  - ✓ ប្រឡងសិស្សពូកែថ្នាក់ជាតិៈ
    - បឋមភូមិ០៣នាក់ស្រី ០១នាក់
    - ទុតិយភូមិ០៣ ស្រី០០នាក់

➢ កំណែទម្រង់ទី៨៖ កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល

- ការអនុវត្តម៉ោង និងកម្មវិធីសិក្សា នៅបឋមសិក្សា (ការអនុវត្តកម្មវិធីសិក្សា)
  - ពេលព្រឹកចូលម៉ោង៧:០០ ចេញម៉ោង១១:០០
  - ពេលរសៀលចូលម៉ោង១៣:០០ ចេញម៉ោង ១៧:០០
  - ការអនុវត្តកម្មវិធីសិក្សាបាន៩០%
- **ការផ្គត់ផ្គង់សម្ភារៈសិក្សា**(សៀវភៅសិក្សាគោល)នៅបឋមសិក្សា
  - ភាសាខ្មែរចំនួនសៀវភៅកំពុងប្រើប្រាស់៩៥%
  - គណិវិទ្យាចំនួនសៀវភៅកំពុងប្រើប្រាស់៩៥%
  - សិក្សាសង្គមចំនួនសៀវភៅកំពុងប្រើប្រាស់៩៥%
  - វិទ្យាសាស្ត្រអនុវត្តចំនួនសៀវភៅកំពុងប្រើប្រាស់៩៥%
- ចុះពិនិត្យតាមដានការប្រើប្រាស់សៀវភៅសិក្សាគោលតាមសាលារៀនបានចំនួន០៩

ដង ស្មើនឹង១៩ សាលាបានរៀបចំផែនការតម្រូវការសៀវភៅសិក្សាគោលសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨

- បើកវគ្គបំប៉នស្តីពីការប្រើប្រាស់សៀវភៅសិក្សាគោលដល់នាយកសាលាចំនួន៥០នាក់ ស្រី០២នាក់ចូលរួមសិក្ខាសាលាសៀវភៅសិក្សាគោលនៅរាជធានីភ្នំពេញចំនួន០២ដង
- **ការអនុវត្តម៉ោង និង កម្មវិធីសិក្សានៅមត្តេយ្យសិក្សា**
    - ថ្នាក់កម្រិតទាបចំនួន 50%
    - ថ្នាក់កម្រិតមធ្យមចំនួន 50%
    - ថ្នាក់កម្រិតខ្ពស់ចំនួន 90%

➢ កំណែទម្រង់ទី៩៖ ការសាងសង់អគារសិក្សា និងការជួសជុល

- បានទទួលអគារសិក្សាដែលជាអំណោយ សម្តេចតេជោ ហ៊ុនសែន និង សម្តេចគតិព្រឹទ្ធបណ្ឌិតប៊ុនរានី ហ៊ុនសែន ចំនួន ៩០ ខ្នង ៦៧៧បន្ទប់ (ក្នុងនោះទទួលបានកាលពីថ្ងៃទី ២៦ -២៧ខែសីហា ឆ្នាំ២០១៦ ដែលសម្តេចចុះសួរសុខទុកប្រជាពលរដ្ឋក្នុងខេត្តឧត្តរមានជ័យ ចំនួន ៩១ខ្នង ៩០៩ បន្ទប់) ។
- បានទទួលមណ្ឌលមត្តេយ្យសិក្សាសហគមន៍ចំនួន១៥កន្លែងពីក្រសួងអប់រំ
- អគារសិក្សាកំពុងសាងសង់១៨ខ្នង ៦៦បន្ទប់
- អន្តេវាសិកដ្ឋានសិស្សប្រុសកំពុងសាងសង់ ២ខ្នង ពីអង្គការសម្រេចសុបិនកុមារ
- ទទួលបង្គន់អនាម័យពីក្រសួង សម្រាប់សាលាបឋមសិក្សា ៩សាលា
- បានសាងសង់បង្គន់អនាម័យតាមសាលារៀន
- សាងសង់អគារមត្តេយ្យធនធានចំនួន២កន្លែង
- ចុះពិនិត្យតាមដានការសាងសង់អគារសិក្សា និងប្រមូលរបាយការណ៍សាលាដែលត្រូវការសាងសង់ និងត្រូវការជួសជុលបានរៀបចំបច្ចុប្បន្នភាពសំណង់អគារសិក្សា

➢ កំណែទម្រង់ទី ១១ ៖ ការលើកកម្ពស់វិស័យកីឡា

- បានរៀបចំប្រកួតកីឡាបឋមសិក្សា និងមធ្យមសិក្សាថ្នាក់ខេត្តសរុប៧២០នាក់ ស្រី៣៦០នាក់
- ត្រូវមានការប្រកួតថ្នាក់ខេត្ត និងទូទាំងប្រទេសដើម្បីឆ្លើយតបទៅនឹងកីឡាស៊ីហ្គេមលើកទី៣២ ឆ្នាំ ២០២៣ដែលប្រទេសកម្ពុជាត្រៀមធ្វើជាម្ចាស់ផ្ទះ។

➢ កំណែទម្រង់ទី ១២ ៖ ការអនុវត្តផែនការ សកម្មភាពគោលនយោបាយយុវជន

- ចូលរួមបោះជំរំយុវជនថ្នាក់ជាតិលើកទី១៩ក្រោមប្រធានបទ “យុវជនដើម្បីសន្តិភាព និងវឌ្ឍនភាព” ដែលខេត្តឧត្តរមានជ័យបានចូលរួមចំនួន១៣នាក់ ស្រី០៣នាក់
- ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើន ឱ្យយុវជនបានចូលរួមសកម្មភាពសង្គម ដើម្បីអភិវឌ្ឍចំណេះ ដឹងរបស់ពួកគេ

➢ *កំណែទម្រង់ទី ១៣ ៖ ការអប់រំបច្ចេកទេស*

- បានចូលរួមសិក្ខាសាលាការអប់រំបច្ចេកទេសសម្រាប់សាលាមធ្យមសិក្សាបឋមភូមិនិង ទុតិយភូមិ

## ២-១-៤-វឌ្ឍនភាពនៃការគ្រប់គ្រង និង ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ

### ក-ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍឆ្នាំ២០១៧( គិតជាលានរៀល )

| ល.រ | ឈ្មោះអង្គការ/ដៃគូ/គម្រោង | ថវិកា | ផ្សេងៗ |
|---|---|---|---|
| ១ | ថវិកាអភិវឌ្ឍសមត្ថភាព CDPF | 13 | |
| ២ | អង្គការយូនីសេហ្វ UNICEF | 12 | |
| ៣ | កម្មវិធីស្បៀងអាហារពិភពលោក (WFP) | 375 | |
| ៤ | អង្គការកែប្រែសហគមន៍ CTO ថវិកា **23,798$** | 95 | |
| ៥ | គម្រោងកែលម្អសាលារៀន(SIG) | 666 | |
| សរុប | | 1161 | |

- សម្គាល់ : ទិន្នន័យស្រង់ពីផែនការប្រតិបត្តិឆ្នាំ២០១៧

### ខ-លទ្ធផលសម្រេចបានរបស់អង្គការ ដៃគូអភិវឌ្ឍវិស័យ អប់រំយុវជន និងកីឡា

#### ខ-១-អង្គការ UNICEF /CDPF

ក្នុងឆ្នាំ២០១៧អង្គការUNICEF /CDPFបានផ្តល់ការគាំទ្រសកម្មភាពពង្រឹកការអប់រំ មូលដ្ឋាន ៖

1. **អនុវត្តដោយការិយាល័យបឋម និង មត្តេយ្យសិក្សា (ផ្នែកមត្តយ្យសិក្សា)**

   ប្រជុំប្រចាំត្រីមាសតាមក្រុង/ស្រុក (មត្តេយ្យសហគមន៍និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ )

   - ចុះពិនិត្យតាមដានតាមភូមិគោលដៅ

2. **អនុវត្តដោយការិយាល័យ ផែនការ និងគ្រប់គ្រងជំនួយ**

   - បើកវគ្គបំប៉ននៅតាមក្រុងស្រុកទាំង៥អំពីការងារផែនការស្ថិតិ តារាងជំរឿន ស្ថិតិសាលារៀន តារាងពិន្ទុសិស្ស របាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ ។
   - ចុះពិនិត្យតាមដានតាមសាលារៀន លើការបំពេញតារាងជំរឿនស្ថិតិសាលារៀន និងការរៀបចំផែនការអភិវឌ្ឍសាលារៀន ។

- ប្រជុំក្រុមបច្ចេកទេសចម្រុះវិស័យអប់រំនិងប្រជុំក្រុមលេខាធិការដ្ឋាន
    - ប្រជុំពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ
    - ដោះស្រាយបញ្ហាប្រឈមនានារបស់វិស័យអប់រំ
    - ប្រជុំពីការរៀបចំរបាយការណ៍សមិទ្ធកម្ម
    - របាយការណ៍សន្និបាតអប់រំ

**ខ-២-អង្គការ ស្បៀងអាហារពិភពលោកWFPថវិកា** 375 លានរៀល

- ➢ នៅក្នុងឆ្នាំ២០១៧សាលារៀនចំនួន១៦២សាលាបានអនុវត្តកម្មវិធីអាហារតាមសាលារៀនស្បៀងនិង២១សាលាបានប្រើប្រាស់កសិផលពិសហគមន៍ក្នុងស្រុក ចុងកាល់។
- ➢ ផ្តល់អាហារតាមសាលារៀន និងបំប៉នសមត្ថភាព ដល់នាយកសាលា នាយឃ្លាំង មេឃុំ អ្នកផ្គត់ផ្គង់ បេឡា ។
- ➢ ផ្តល់អាងត្រងទឹកភ្លៀងចំនួន ២៥ នៅឆ្នាំ២០១៦ ក្នុងក្រុងស្រុកទាំង៥ ដែលសាងសង់ដោយ អង្គការ អង្គការទឹកភ្លៀងកម្ពុជា និងបន្តសាងសង់បន្ថែមទៀតនៅឆ្នាំ២០១៧ ។
- ➢ ប្រជុំប្រចាំត្រីមាស ប្រចាំឆ្នាំនៅតាមក្រុង/ស្រុក ។
- ➢ បង្កើតគណៈកម្មការ គ្រប់គ្រងស្បៀងនៅតាមសាលារៀន និងក្រុងស្រុក

**ខ-៣-គម្រោងកែលម្អសាលារៀន** SIG **166,417.93$ ស្មើនិង 666លានរៀល**

ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ ទទួលបានថវិកាសរុបចំនួន៖ **166,417.93$ក្នុងនោះ ៖**

- ❖ ថវិកា គ.ជ.ខ = 6,810$
- ❖ ថវិកា គ.ជ.ស =15,200$ ( 3,040 x 5 )
- ❖ ថវិកា គ.ទ.ស.ម = 144,407.93 $

**ក.មន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

- ❖ បានអនុវត្តការងារប្រជុំបូកសរុបប្រចាំឆ្នាំថ្នាក់ខេត្ត អ្នកចូលរួមសរុបចំនួន ១៣៨ នាក់
- ❖ ការចុះត្រួតពិនិត្យតាមសាលារៀនគោលដៅចំនួន ២៣ ដង ស្មើនឹង ៤៣សាលាដោយមន្ត្រីក្រោមឱវាទមន្ទីរអប់រំខេត្ត
- ❖ បានណែនាំពីការប្រើប្រាស់ថវិកា ការកែលម្អបរិស្ថានសាលារៀន ការទុកដាក់ឯកសារ និងការទូទាត់ឯកសារ ដល់នាយកសាលា មន្ត្រីទទួលបន្ទុក (ហេរញ្ញិកសាលា) និងអ្នកពាក់ព័ន្ធនានា
- ❖ បានណែនាំពីការធ្វើផែនការថវិកា ផែនការអភិវឌ្ឍសាលារៀន ...

- ❖ បានត្រួតពិនិត្យការបង្រៀន និងរៀនតាមសាលារៀន
- ❖ បានទទួលរបាយការណ៍ស្តីពីការផ្ទេរថវិការបស់ក្រសួងអប់រំ ការទូទាត់ថវិកា ការរីកចម្រើន
- ❖ បានធ្វើការចែករំលែក ឬចូលរួមក្នុងការងារសង្គមនានាដែលចាំបាច់ដល់មូលដ្ឋានសាលារៀន
- ❖ ក្រុមការងារក្រោមឱវាទមន្ទីរបានប្រើប្រាស់លើការងារបច្ចេកទេសរបស់ខ្លួនមួយផ្នែកតូច ដូចជា បានត្រួតពិនិត្យការងារបង្រៀនពីរពេល ការបង្រៀននិងរៀន ការគ្រប់គ្រងថ្នាក់ ការគ្រប់គ្រងសាលារៀន ....តាមដានការធ្វើផែនការអភិវឌ្ឍសាលារៀន ....

**ខ.ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក**

- ❖ បានអនុវត្តការងារប្រជុំថ្នាក់ក្រុងស្រុក
- ❖ បានចុះត្រួតពិនិត្យតាមសាលារៀននីមួយៗ
- ❖ បានចុះប្រមូលរបាយកាណ៍ចំពោះសាលាមួយចំនួនដែលមានការយឺតយ៉ាវ និងមានកម្រិតក្នុងការធ្វើរបាយការណ៍
- ❖ បានបញ្ជូនរបាយការណ៍មន្ទីរអប់រំខេត្ត គ្រប់ការិ.អយកក្រុងស្រុក
- ❖ បានធ្វើកិច្ចសហការល្អជាមួយ មន្ទីរអប់រំខេត្ត និងសាលារៀន

**គ.សាលារៀន**

- ❖ បានទិញសម្ភារប្រើប្រាស់សម្រាប់បម្រើការបង្រៀន និងរៀន
- ❖ បានកែលម្អបរិស្ថានសាលារៀនបានតាមកម្រិតអនុវត្តផ្ទាល់
- ❖ បានរៀបចំទុកដាក់ឯកសារគាំទ្រការចំណាយទៅតាមឆ្នាំអនុវត្ត
- ❖ ប្រើប្រាស់ថវិកា តាមបំណែងចែកថវិកា(គាំទ្រដំណើរការ ពង្រីកការចូលរៀន និងកែលម្អគុណភាពអប់រំ )

**ខ-៤-អគារ សម្រេចសុបិនកុមារ** ( ៩១៩០៧២$ )

| | | | |
|---|---|---|---|
| ➢ អគារសិក្សា | ១៤ អគារ | អស់ទឹកប្រាក់ | ៧៦២៧៤៦$ |
| ➢ ស្ទួនកុមារ | ៨ | អស់ទឹកប្រាក់ | ១៧៩៩៨$ |
| ➢ អាងទឹក | ៧ | អស់ទឹកប្រាក់ | ៣៩៣០០$ |
| ➢ ស្ទូឡា | ៨ | អស់ទឹកប្រាក់ | ៥០៥៧៣$ |
| ➢ អន្តេវាសិកដ្ឋាន | ១ | អស់ទឹកប្រាក់ | ៤៨៥៥៥$ |
| ➢ សរុប | ៣៨ | អស់ទឹកប្រាក់ | ៩១៩០៧២$ |

**ខ-៥-អង្គការ** Green Way

- សាលាគ្រីនវេបានបង្រៀន ភាសាអង់គ្លេស និងកុំព្យូទ័រ ថ្នាក់ពេញម៉ោង ដោយឥតបង់ថ្លៃសិក្សាដល់សិស្សានុសិស្ស ។
- គាំទ្រផ្នែកបឋមសិក្សា កម្មវិធី កន្លែងលាងដៃ ជួយសម្អាតបរិស្ថានសាលារៀន លាមជញ្ជាំងសាលារៀន និងបង្រៀនសិស្សក្រៅម៉ោងដោយជនជាតិបរទេសមិនយកប្រាក់កម្រៃ ។
- សាងសង់រោងចម្អិនអាហារពេលព្រឹកនិងបំពាក់សូឡានៅសាលាបឋមសិក្សាបន្សាយរាក់ ក្រុងសំរោងខេត្ត ឧត្តរមានជ័យ ។
- ផ្តល់អាហារូបករណ៍ ដល់សិស្សក្រីក្រ និងផ្តល់សម្ភារសិក្សា កង់សម្លៀកបំពាក់ បាល់បោះ បាល់ទាត់ ប្រដាប់វាយរ៉ាកែត ។
- អប់រំសិស្សពីអនាម័យ មាត់ធ្មេញ ការលាងសម្អាតដៃ និងផ្តល់សម្ភារ ច្រាសដុសធ្មេញ ធុងចម្រោះទឹក ......។
- ជួសជុលបង្គន់អនាម័យ កន្លែងលាងដៃ សួនកុមារ កន្លែងញុំាអាហារពេលព្រឹក កន្លោងទ្វាសាលារៀន និងបញ្ជូនអ្នកស្មគ្រចិត្ត ទៅសាលាបឋមបន្សាយរាក់ បំបាក់ផ្ទាំងសូឡាដោយប្រើថាមពលពន្លឺព្រះអាទិត្យ និងអំពូលភ្លើងតាមសាលារៀន ថ្នាក់រៀន និងលាបថ្នាំអគារ ។

**ខ-៦-អង្គការ** CIDO 22,113.23$

ក្នុងឆ្នាំ២០១៧ អង្គការបានអនុវត្តការងារដូចជា

- បានប្រជុំគណៈកម្មការដឹកនាំគម្រោងចំនួន០២ដង ស្រុកបន្ទាយអំពិល និង ក្រុង) (សំរោង
- អ្នកចូលរួម សរុប១៧នាក់ ។ (គ្មាន) ស្រី /
- លោកគ្រូ-អ្នកគ្រូចំនួន៣៨នាក់ មកពីក្រុងសំរោង និង ស្រុកបន្ទាយ (នាក់០៩ស្រី) អំពិលបាន
- ទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំបន្លែ លើប្រធានបទ សួនមេត្រីភាពនឹងបរិស្ថាន ការគ្រប់គ្រងសត្វល្អិត និងជម្ងឺលើដំណាំបន្លែ ដោយគ្រូជនជាតិអាមេរិកកាំង ។
- លោកគ្រូ-អ្នកគ្រូចំនួន១២នាក់ នាក់មកពី០៦នាក់មកពីស្រុកបន្ទាយអំពិល និង ០៦) (ក្រុងសំរោងបានធ្វើ
- ទស្សនៈកិច្ចសិក្សាអំពីដំណាំបន្លែបែបអភិរក្ស រយៈពេល០២ថ្ងៃ នៅខេត្តសៀមរាប ។

- លោកគ្រូ-អ្នកគ្រូចំនួន៥១នាក់ លការបណ្តុះបណ្តាលបំប៉នបានទទួ (នាក់០៦ស្រី) ថ្ងៃ អំពីការពិនិត្យប៉េហាស់ដី០២បច្ចេកទេសបន្លែមរយៈពេល(pH) ដោយប្រើឧបករណ៍ ការគ្រប់គ្រងជីវជាតិលើដំណាំបន្លែ ការគ្រប់គ្រងសត្វល្អិត និងជម្ងឺ ដោយគ្រូជនជាតិខ្មែរ មកពីសហរដ្ឋអាមេរិក ។
- សាលារៀនចំនួន៤២សាលារៀន សាលា២០សាលារៀននៅក្រុងសំរោង និង ២២) (រៀនបានទទួលការឧបត្ថម្ភជាសំភារៈសួនបន្លែ ប្រព័ន្ធតបណ្តាញទឹកស្រោចស្រព និងគ្រាប់ពូជដើម្បីដឹកនាំសិស្សអនុវត្តសួនបន្លែនៅតាមសាលារៀន ។
- សាលារៀនចំនួន៤២សាលារៀនបានអនុវត្តសួនបន្លែដោយមានសិស្សបានរៀនចំនួន ៦,៨២៦នាក់ សិស្សប្រឡងជាប់ទទួលបានវិញ្ញាបនប័ត្រចំនួន១,២០៥នាក់ បន្លែដាំបានចំនួន ១៣តោន និង ថវិកាចំណូលពីបន្លែសរុបចំនួន ១,២១៦,៤០០ រៀល ។
- បានផ្តល់ការតម្រង់ទិសដល់យុវជនចំនួន៣០០នាក់មកពីសាលាវិទ្យាល័យចំនួន០២ អំពីជំនាញកសិកម្ម ។

## ខ-៧-អង្គការកុមារមេគង្គ ( Enfonts Du Mekong )

អង្គការកុមារមេគង្គបានជួយកុមារក្រីក្រកម្ពុជានៅតាមជុំរុំជនភៀសខ្លួន កម្ពុជា ថៃចាប់ពីឆ្នាំ **1986** ហើយបានចូលមក ធ្វើការនៅប្រទេសកម្ពុជាក្នុងឆ្នាំ 1991។បច្ចុប្បន្នអង្គការ កុមារមេគង្គមានមជ្ឈមណ្ឌលចំនួន 6 **ស៊ីសុផុន បន្ទាយឆ្មា ខេត្តបន្ទាយមានជ័យ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហា ខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។**

ដើម្បីជួយកុមារក្រីក្រងាយរងគ្រោះដែលមានឆន្ទៈខ្ពស់ក្នុងការសិក្សារៀនសូត្រអោយទទួលបានការអប់រំប្រកបដោយគុណភាព និងតម្លាភាព ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា។

**នៅប្រទេសកម្ពុជាអង្គការកុមារមេគង្គមានគំរោងធំៗមួយចំនួនដូចជា៖**

1- កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់សិស្សនិស្សិតក្រីក្រតាមរយៈឪពុកម្តាយធម៌ទាំងក្នុងមណ្ឌល និងក្រៅមណ្ឌល

2- ជាមជ្ឈមណ្ឌលសិក្សាបំប៉នបន្ថែមចាប់ពីថ្នាក់មត្តេយដល់សកលវិទ្យាល័យ

3- កម្មវិធីផ្តល់កន្លែងស្នាក់នៅសំរាប់សិស្សតាមស្រុកមកពីតំបន់ដាច់ស្រយាល

4- កម្មវិធីសាងសង់ និងជួសជុលអាគាសិក្សា មានទាំងជីកស្រះ អណ្តូងទឹក បង្គន់អនាម័យនៅ តាមសាលារៀន។

5- គំរោងផ្សេងៗដូចជាជួយសិស្សដែលរៀនពូកែហើយមានឆន្ទៈបានបន្តការសិក្សាដល់ថ្នាក់ មហាវិទ្យាល័យ មណ្ឌុះបណ្តាលគ្រូបង្រៀនបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ ជួយសិស្ស ដែល

រៀនមិនសូវពូកែប៉ុន្តែមានឆន្ទៈក្នុងការសិក្សាទៅរៀននៅតាមជ្ឈមណ្ឌល បណ្តុះបណ្តាល វិជ្ជាជីវៈផ្សេងៗ។

**ដោយឡែកក្នុងខេត្តឧត្តរមានជ័យអង្គការកុមារមេត្តាមានគំរោងធំៗចំនួនបី**

1. កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់សិស្សក្រីក្រតាមរយៈឪពុកម្តាយធម៌ទាំងក្នុងមណ្ឌល និងក្រៅមណ្ឌលពីបឋមសិក្សារហូតដល់វិទ្យាល័យ(**បច្ចុប្បន្ននេះមានកូនធម៌ចំនួន 160នាក់)**
2. ជាមជ្ឈមណ្ឌលសិក្សាបំប៉នបន្ថែមចាប់ពីថ្នាក់អនុវិទ្យាល័យដល់វិទ្យាល័យ **(មានសិស្សចំនួន 150នាក់កំពុងសិក្សានៅក្នុងមជ្ឈមណ្ឌលដែលមានមុខវិជ្ជាដូចជា ភាសាខ្មែរ គណិតវិទ្យា គីមីវិទ្យា រូបវិទ្យា ជីវៈវិទ្យា និងភាសាអង់គ្លេស)។**
3. កម្មវិធីផ្តល់កន្លែងស្នាក់នៅសំរាប់សិស្សតាមស្រុកមកពីតំបន់ដាច់ស្រយាល **(មានសិស្សចំនួន 72នាក់(សិស្សស្រី36នាក់)** កំពុងរស់នៅក្នុងមណ្ឌល។មានរបបអាហារចំនួន ២ពេលក្នុង១ថ្ងៃ។

**ខ-៨-អង្គការ** Seven Day Adventist

បង្រៀនកុមារក្នុងសាលា Seven Day Adventist និង អាហារូករណ៍ ក្នុងក្រុងសំរោងខេត្តឧត្តរមានជ័យ

**ខ-៩-អង្គការកែប្រែសហគមន៍** CTO **ចំណាយ**ថវិកា **23,798$**

## សកម្មភាព និងលទ្ធផលសម្រេចបាន

**កម្មវិធី**៖មានបីសំខាន់ៗគឺ ការអភិវឌ្ឍជីវភាព សហគមន៍ព្រៃឈើ និងអប់រំ។ដែលសកម្មភាពអប់រំមានសកម្មភាពដូចខាងក្រោម៖

- កម្មវិធីអប់រំទូទៅនៅតាមភូមិ និងសាលាបឋមសិក្សា( អនាម័យ ល្បែងកំសាន្ត និទានរឿង គូររូប)ភូមិចំនួន ១៨ ភូមិ ១/ឆ្អើប ២/គោកច្រេស ៣/អូរកន្សែង ៤/អូរឬស្សី ៥/ឈូក ៦/ដូនកែន ៧/ ពុរ ៨/អូរទេង ៩/ឈើស្លាប់ ១០/គាប ១១/ គោកខ្ពស់ ១២/ប្រិយ៍ ១៣/ព្រៃទទឹង ១៤/បន្សាយរាក់ ១៥/សំបួរមាស ១៦/រំដួលវាសនា ១៧/ត្នោត ១៨/ពោធិវង្ស ។
- ប្រជុំគ្រូស្មគ្រ័ចិត្ត(2ដង)២៦នាក់ការិយាល័យអង្គការកែប្រែសហគមន៍។
- គាំទ្រសម្ភារៈដល់ក្លិបកុមារ១០ សាលាបឋម ដូនកែនត្បៀត បឋមសិក្សាសំរោង បឋមសិក្សាគោកគរ បឋមសិក្សាហ៊ុនសែនឆ្អើប បឋមសិក្សាបន្សាយរាក់ បឋមសិក្សាអូរទេង បឋមសិក្សាត្នោត បឋមសិក្សាពោធិវង្ស បឋមសិក្សាឈើស្លាប់ និង បឋមសិក្សាគោកខ្ពស់ថ្មី ។

- សាងសង់ក្លិបកុមារ២សាលាសាលាបឋមសិក្សាពោធិវង្ស សង្កាត់បន្សាយរាក់ និងឈើស្លាប់ឃុំគោកខ្ពស់
- សាងសង់បង្គន់២សាលា/៤បន្ទប់សាលាបឋមសិក្សាពោធិវង្ស សង្កាត់បន្សាយរាក់ និងឈើស្លាប់ឃុំគោកខ្ពស់
- ពីការលើកកំពស់សិទ្ធិអប់រំក្នុងសាលារៀនដល់អ្នកពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន សហគមន៍ កុមារ ១០ភូមិ១០សាលាបឋមសិក្សា
- ចែកសម្ភារៈផ្សព្វផ្សាយ ការលើកកំពស់សិទ្ធិអប់រំក្នុងសាលារៀនដល់សលាបឋមសិក្សា៥៥សាលា
- បង្កើត និងពង្រឹងសមត្ថភាពដល់ក្រុមយុទ្ធជនថ្នាក់ខេត្តពីជំនាញComputer និង ថតរូបដើម្បីលើកកំពស់សិទ្ធិអប់រំក្នុងសាលារៀនការិយាល័យCTO
- សិក្សាស្រាវជ្រាវពីការលើកកំពស់សិទ្ធិអប់រំក្នុងសាលារៀនដល់សលាបឋមសិក្សា៥សាលាបឋមសិក្សា៥ ( សាលាបឋមសិក្សាត្នោត ពោធិវង្ស អូរទង ឈើស្លាប់ ព្រៃទទឹង)
- បង្កើតផែនការអភិវឌ្ឍសាលារៀនសាលាបឋមសិក្សា៥ ( សាលាបឋមសិក្សាត្នោត ពោធិវង្ស អូរទង ឈើស្លាប់ ព្រៃទទឹង)
- ការចុះពិនិត្យតាមដាន ផែនការអភិវឌ្ឍសាលារៀន ការរៀន និងបង្រៀនរបស់គណៈកម្មការទ្រទ្រង់សាលា
- ពង្រឹងសម្ថភាពគណៈកម្មការទ្រទ្រង់សាលា៥សាលា
- ប្រជុំឆ្លុះបញ្ចាំងរបស់គណៈកម្មការទ្រទ្រង់សាលា៥ សាលា
- ទស្សកិច្ចសិក្សារបស់ក្លិបកុមារទាក់សិទ្ធិកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន។
- យុទ្ធនាការចុះឈ្មោះចូលរៀនសាលាបឋមសិក្សា៧ ( សាលាបឋមសិក្សាត្នោត ពោធិវង្ស សំបួរមាស គោកគោ អូរទង ឈើស្លាប់ ព្រៃទទឹង)
- ទិញសៀវភៅបន្ថែមដាក់បណ្ណាល័យសាលាបឋមសិក្សា៥ ( សាលាបឋមសិក្សាត្នោត ពោធិវង្ស អូរទង ឈើស្លាប់ ព្រៃទទឹង)
- រៀបចំសួនកុមារ២សាលា នៅភូមិឈើស្លាប់ និងពោធិវង្ស

## ២-១-៥-វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិ២០១៧

ផែនការប្រតិបត្តិឆ្នាំ២០១៧បានបង្ហាញពីសកម្មភាពចំនួន 113 សកម្មភាពត្រូវអនុវត្ត ។ គិតត្រឹមខែធ្នូឆ្នាំ២០១៧ សកម្មភាពទាំងនេះបានបញ្ចប់ចំនួន 103 សកម្មភាព បន្តចំនួន 0 សកម្មភាព និងមិនបានអនុវត្តចំនួន 10 សកម្មភាព ។

### វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិឆ្នាំ២០១៧ (ថ្នាក់មន្ទីរ)

| ល.រ | អង្គភាព | សកម្មភាពសរុប | បានបញ្ចប់ | កំពុងអនុវត្ត | មិនទាន់អនុវត្ត |
|---|---|---|---|---|---|
| ១ | កា.រិ.បឋម(ផ្នែកបឋម) | 35 | 31 | 0 | 4 |
| ២ | កា.រិ. បឋម(ផ្នែកកុមារតូច) | 3 | 3 | 0 | 0 |
| ៣ | កា.រិ.មធ្យម | 17 | 11 | 0 | 6 |
| ៤ | កា.រិ.អកប | 6 | 6 | 0 | 0 |
| ៥ | កា.រិ.យុវជន និងកីឡា | 29 | 29 | 0 | 0 |
| ៦ | កា.រិ.ផែនការ | 6 | 6 | 0 | 0 |
| ៧ | កា.រិ.របប | 3 | 3 | 0 | 0 |
| ៨ | កា.រិ.អធិការ | 6 | 6 | 0 | 0 |
| ៩ | កា.រិ.គណនេយ្យ | 8 | 8 | 0 | 0 |
| **សរុប** | | **113** | **103** | **0** | **10** |

## ២-២-លទ្ធផលតាមអនុវិស័យ

### ២-២-១-អនុវិស័យ ការអប់រំកុមារតូច

**ក-លទ្ធផលសម្រេចបាន**

**ក-១-ការធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយ សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា**

ឆ្នាំសិក្សា២០១៧-២០១៨ សាលាមត្តេយ្យសិក្សារដ្ឋមាន ៩៧ សាលា (ក្នុងបឋម) កើន ២ សាលា សាលា ០៥មត្តេយ្យសិក្សាឯកជនមាន ថេរ សាលាមត្តេយ្យសិក្សាសហគមន៍មាន ១០១ កន្លែងថយ ២ កន្លែង ។

ថ្នាក់មត្តេយ្យសិក្សាគ្រប់ប្រភេទមាន ២២៥ ថ្នាក់ថេរក្នុងនោះ ៖

- មត្តេយ្យសិក្សារដ្ឋមាន ១១៧ ថ្នាក់ កើន ០៥ថ្នាក់
- មត្តេយ្យសិក្សាឯកជនមាន ០៧ ថ្នាក់ ថយ ០៣ថ្នាក់
- មត្តេយ្យសិក្សាសហគមន៍មាន ១០១ កន្លែង ថយ ០២កន្លែង

ចំនួនកុមារក្នុងកម្មវិធីអប់រំកុមារតូច ៖

- កុមារពី ០ទៅក្រោមអាយុ ៦ ឆ្នាំ ទទួលបានសេវាអប់រំ ៦៤៦៩ នាក់ស្មើនឹង ៤១% នៃកុមារសរុបចំនួន១៥៨១២នាក់ ។
- កុមារអាយុ ៣ឆ្នាំមាន ១២៧០នាក់ស្មើនឹង២៩% នៃចំនួនកុមារសរុបអាយុ៣ឆ្នាំ៤៦៤១ នាក់ ។
- កុមារអាយុ ៤ឆ្នាំសេវាអប់រំ ២១៧៤នាក់ស្មើនឹង៤៥នៃចំនួនកុមារសរុប% អាយុ៤ឆ្នាំ ៤៨៣៨ ។
- កុមារអាយុ៥ឆ្នាំ ទទួលបានសេវាអប់រំ៣០២៥នាក់ស្មើនឹង៤៨% នៃចំនួនកុមារអាយុ៥ឆ្នាំសរុប ៦៣៣៣ (ធៀបនិងចំណុចដៅ ESP៥៥% )
- ការអប់រំកុមារតូចតាមផ្ទះមាន១ក្រុង៤ស្រុក ២០ឃុំ/សង្កាត់ ៤០ ភូមិ ។ឪពុកម្ដាយអាណាព្យាបាល ចូលរួមចំនួន១០៣២ នាក់កុមារចំនួន ១៤៩៤ នាក់ស្រី ៧១៦ នាក់
- កុមារអាយុ៥ឆ្នាំ បានបញ្ចប់ការសិក្សា ថ្នាក់កម្រិតខ្ពស់ ២៨៧១ នាក់ ក្នុងនោះស្រី ១៤០៧ នាក់ ធៀបនឹងឆ្នាំចាស់ ថយ។

កុមារទទួលបានសេវាអប់រំកុមារតូចនៅតាមក្រុងស្រុក/ មានការកើនឡើងបន្តបន្ទាប់បើប្រៀបធៀបទៅនឹង ឆ្នាំសិក្សា2016-2017 ។ ប៉ុន្តែការកើនឡើងមានលក្ខណៈយឺតយ៉ាវនៅឡើយដោយ

សាការផ្តល់ធាតុចូលសម្រាប់ការពង្រីកសេវាអប់រំកុមារតូចនៅមានកម្រិត។ បុគ្គលិក ផ្នែកមត្តេយ្យមាន ២២៥នាក់ស្រី ២១៥ នាក់ស្មើនឹង97,87% ថេរ ក្នុងនោះបុគ្គលិក មត្តេយ្យរដ្ឋមាន ១១៧ នាក់ គ្រូបឋមសិក្សា៦៦ នាក់ស្រី៦៦នាក់ គ្រូកិច្ចសន្យា២នាក់ ស្រី ០២នាក់ស្រី(៧៧ មត្តេយ្យឯកជន០៧ នាក់ស្រី០៧នាក់)ថយ៣នាក់១មត្តេយ្យសហគមន៍ (០១នាក់ស្រី១០១នាក់ថយ០២នាក់ ការអប់រំកុមារតូចតាមផ្ទះមានចំនួន ៤០ភូមិដែលមានឪពុកម្តាយ កុមារចូលរួម ១០៣២ គ្រួសារប្រធានក្រុមម្តាយចំនួន១៩៣នាក់ ម្តាយបង្គោលចំនួន ៤០នាក់)។

## ក-២-ធានាភាពស័ក្តសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់

ការទទួលបានចំណេះដឹង និងសមត្ថភាព កុមារ

កុមារអាយុ ៥ឆ្នាំទទួលបាន ការអប់រំមានចំនួន ៣០២៥ នាក់ ធៀបឆ្នាំចាស់២០១៦-២០១៧ ការអប់រំមានចំនួន ២៨១១ នាក់ កើន ២១៤នាក់ ។

ការរៀបចំបរិស្ថានសិក្សា និងសម្ភារសិក្សា

- បានផលិតសម្ភារឧបទេសលើមុខវិជ្ជាបុរេគណិត ០១ កំប្លេ
- បានផលិតសម្ភារឧបទេសលើមុខវិជ្ជាបុរេសំណេរ ០១ កំប្លេ ដល់គ្រូមត្តេយ្យរដ្ឋ និងគ្រូមត្តេយ្យសហគមន៍
- បានចុះជួយរៀបចំថ្នាក់រៀនបានចំនួន៨ថ្នាក់
- បានចុះពិនិត្យតាមដានការបង្រៀន និងរៀន(មត្តេយ្យរដ្ឋចំនួន២០ថ្នាក់ មត្តេយ្យសហគមន៍ចំនួន១៥ថ្នាក់ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ៣៦ភូមិ)

ការអនុវត្តម៉ោង និង កម្មវិធីសិក្សា

- ថ្នាក់កម្រិតទាបចំនួន 50%
- ថ្នាក់កម្រិតមធ្យមចំនួន50%
- ថ្នាក់កម្រិតខ្ពស់ចំនួន 90%

## ក-៣-និងគ្រប់គ្រងនៅគ្រប់កម្រិត ការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ

ការបំប៉ន និងសិក្ខាសាលា

- ចូលរួមប្រជុំម៉ែ១នៅភូមិអូរគ្រវ៉ាន់ ក្រុងសំរោង
- ចូលរួមការប្រជុំបច្ចេកទេសបប្រចាំខែសម្រាប់កម្មវិធីមត្តេយ្យសិក្សាសហគមន៍នៅស្រុកត្រពាំងប្រាសាទ ស្រុកអន្លង់វែង ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

- មន្ត្រីមួយរូបចូលរួមវគ្គបំប៉នស្តីពីតួនាទីនិងភារកិច្ចគណៈកម្មការទ្រទ្រង់ថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅស្រុកត្រពាំងប្រាសាទ
- មន្ត្រីមួយរូបចូលរួមវគ្គបំប៉នស្តីពីការរៀបចំផែនការអប់រំថ្នាក់ខេត្តនៅស្រុកអន្លង់វែង
- ប៉នគ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន៣៤នាក់នៅស្រុកត្រពាំងប្រាសាទតាមស៊ូដា៣៥ថ្ងៃ

ការចុះពិនិត្យតាមដាន

- បានចុះពិនិត្យតាមដាន និងជួយលើការងារបច្ចេកទេស ដល់គ្រូមត្តេយ្យសហគមន៍ កម្មវិធីអប់រំកុមារតូចតាមផ្ទះ និងមត្តេយ្យរដ្ឋ ។

## ខ-ការវិភាគអំពីវឌ្ឍនភាពនៃសូចនាករផលសម្រេច

ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច

| លរ | ការអប់រំកុមារតូច | ជាក់ស្តែង 2016-17 | ចំណុចដៅ 2017-18 | ជាក់ស្តែង 2017-18 | ស្ថានភាព |
|---|---|---|---|---|---|
| 1 | ភាគរយកុមារអាយុ ៥ ឆ្នាំបានចូលរៀន | ៨៤% | ៥៥% | ៨៨% | → |
| 2 | ភាគរយកុមារអាយុ ៤ ឆ្នាំបានចូលរៀន | ៣៦% | ៤៥% | ៤៥% | ↑ |
| 3 | ភាគរយកុមារអាយុ ៣ ឆ្នាំបានចូលរៀន | ២១% | ៤០% | ២៩% | ↓ |
| 4 | ភាគរយសេវាអប់រំកុមារតូចដែលគោរពតាមស្តង់ដារ គុណភាព | NA | ៤០% | ១៦% | ↑ |
| 5 | ភាគរយសេវាអប់រំកុមារតូចដែលបានអនុវត្តតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ ៥ ឆ្នាំ ជាទៀងទាត់ | ២០% | ៤០% | ២៩% | ↑ |
| 6 | ភាគរយកុមារក្នុងសេវាគាំពារនិងអភិវឌ្ឍកុមារតូច ដែលមានស្ថានភាពអាហារូបត្ថម្ភ | NA | ៤០% | NA | ↑ |
| 7 | ភាគរយកុមារនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈទទួលបានថ្នាំទម្លាក់ព្រូន | ៩០% | ៣៨% | ៩០% | ↑ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ　→ អាចទទួលយកបាន　↓ សម្រេចមិនបានតាមគោលដៅ

## គ-បញ្ហាប្រឈម

- ខ្វះអាគារសិក្សាដាច់ដោយឡែកពីបឋម　៩៤សាលា
- ថ្នាក់មត្តេយ្យចំនួន ១១០ថ្នាក់មានសិស្សលើសនិយាម
- គ្រូបឋមជួយបង្រៀនថ្នាក់មត្តេយ្យ មិនមានបច្ចេកទេស ក្នុងការបង្រៀនចំនួន៦៦

- ខ្វះគ្រូបង្រៀនកម្រិតមត្តេយ្យសិក្សា ៦៦នាក់គ្រប់ក្រុង/ស្រុក
- ពិបាកក្នុងការប្រមូលរបាយការណ៍ពីមត្តេយ្យសហគមន៍
- មត្តេយ្យរដ្ឋសិស្សច្រើនមិនអាចពង្រីកបាន
- មាតាបិតាមួយចំនួន មិនបញ្ជូនកូនមកចុះឈ្មោះចូលរៀនដោយ សារជីវភាព ក្រីក្រ ទោះបីសាលាមានគោលការណ៍ជួយដល់កុមារជួបការលំបាកកុមារពិការ ក៏ដោយ
- ខ្វះសម្ភារប្រើប្រាស់សម្រាប់ថ្នាក់មត្តេយ្យសិក្សា ទូរឯកសារ តុកៅអី សម្រាប់កុមារ
- បន្ទប់រៀនគ្មានសុវត្ថិភាព និង មិនសមស្រប គ្មានកម្មវិធីបង្រៀនសម្រាប់ថ្នាក់ចម្រុះ
- នៅរដូវបង្កបង្កើនផល និងប្រមូលផលក្រុមគ្រួសារមួយចំនួនយកកូន ទៅទៅជាមួយ
- គ្រូមត្តេយ្យសហគមន៍ផ្លាស់ប្តូរញឹកញាប់ និងមានចំណេះដឹងមិនស្មើគ្នា
- ក្រុមម៉ែៗ អនុវត្តកម្មវិធីកុមារតូចមិនបានទៀងទាត់
- មត្តេយ្យសហគមន៍មិនបានប្រជុំបច្ចេកទេសប្រចាំខែ (គ្មានថវិកា)
- ក្រុមម៉ែៗគ្មានថវិកាសម្រាប់ប្រជុំប្រចាំខែ
- មត្តេយ្យសិក្សាសហគមន៍មិនបានបំប៉នបច្ចេកទេសគ្រប់កំណត់ និងគ្មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់
- ថ្នាក់មត្តេយ្យសិក្សាសហគមន៍(បង្រៀននៅរោងដោល សាលាឆទាន)
- បរិស្ថានក្នុង និងក្រៅថ្នាក់រៀនមិនទាន់សមស្របតាមគរុកោសល្យ

## ២-២-២- អនុវិស័យ ការអប់រំបឋមសិក្សា

### ក-លទ្ធផលសម្រេចបាន

### ក-១-ការធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយ សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០១៧២១សាលាបឋមសិក្សាមានចំនួន ២០១៨-៤ កើន ៤សាលា។ សាលារៀន មិនគ្រប់កម្រិត ២០សាលា នៅដដែល ។ សាលាកុមារមេត្រី (កម្រិតមធ្យម និងអភិវឌ្ឍ)ថយពី១២៥ សាលា មក៩៨សាលា ក្នុងឆ្នាំសិក្សា២០១៦២០១៧-។

ថ្នាក់រៀនមានចំនួន១៤៧៨ កើន ៣៩ថ្នាក់ ។ បន្ទប់រៀនមានចំនួន៩៥៧ ថយ ២៩៦បន្ទប់ (អគារសិក្សាថ្មីមិនទាន់ដំណើរការបាន)។

សិស្សបឋមសិក្សាមានចំនួន ៣៦៩៣៧,នាក់ ស្រី ១៧៧៣៥,នាក់ កើន០.០៧ ភាគរយ ។ អត្រាពិតចូលរៀនថ្មី ៨៨៧០.ភាគរយ ស្រី៨៨៤០.ភាគរយ ធៀបឆ្នាំ២០១៦ ២០១៧-កើន ៧៧.០ភាគរយ ស្រីកើន ៩៤០.ភាគរយ ចំណុចដៅ)ESP ១០០ភាគរយ ស្រី ១០០ភាគរយ។(

ប្រការនេះបញ្ជាក់ឱ្យឃើញថាការផ្សព្វផ្សាយការប្រមូលកុមាររៀននៅមិនទាន់ទូលំទូលាយ ដែលត្រូវទាមទារឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ចូលរួមផ្សព្វផ្សាយ និងបញ្ជូនកូនគ្រប់អាយុមកចូលរៀនព្រមទាំងប្រើប្រាស់ផែនទីសិក្សាឱ្យទៅជាប្រយោជន៍ក្នុងការប្រមូលកុមារចូលរៀន និងទាមទារបង្កើតសាលាថ្មីៗនៅតាមតំបន់ដាច់ស្រយាល និងតំបន់ភូមិកងទ័ព។

អត្រាពិតនៃការសិក្សា៨៩២០.ភាគរយ ស្រី៨៥២០.ភាគរយ ធៀបឆ្នាំសិក្សា ២០១៦ ២០១៧-ថយ១៣៨០.ភាគរយ ចំណុចដៅ)ESP ៩៨ ភាគរយ ស្រី ៩៨ ភាគរយ។ (

បុគ្គលិកអប់រំបឋមសិក្សាមានចំនួន១នាក់២២៦, ស្រី៥១៨នាក់ កើន៦៨នាក់ ស្មើនឹង ៥%២២. .៨១នាក់ ស្មើនឹង៨០៨នាក់ ស្រី៩៧៥។ បុគ្គលិកបង្រៀន៨៩ ភាគរយ កើន៣៩ នាក់ ។ គ្រូបង្រៀនពីរថ្នាក់ពីរវេន៣៦៦នាក់ កើន៥៨នាក់ និងគ្រូបង្រៀនថ្នាក់គួប២២៨នាក់ ស្រី២១៦នាក់ កើន ១២នាក់ ។

## ការអនុវត្តកម្មវិធីនានា

- **ការគ្រប់គ្រងថវិកាដំណើរការសាលារៀន**

  សាលារៀនចំនួន ២១០ បានទទួលថវិកាដំណើរការសាលារៀន។ សាលារៀននីមួយៗ មានការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ដែលមានការចូលរួមពីគណៈកម្មការទ្រទ្រង់សាលារៀន។ រាល់ចំណូលចំណាយមានតារាងតម្លាភាពបិទផ្សាយ។

  - ប្រការនេះ បានជួយឱ្យសាលារៀនមានលទ្ធភាពប្រមូលកុមារចូលរៀន និងមានការចូលរួមពីសហគមន៍កាន់តែប្រសើរឡើង។
  - កម្មវិធីស្បៀងអាហារនៅតាមសាលារៀន និងអាហារូបករណ៍ ឆ្នាំសិក្សា២០១៦-២០១៧ ។
  - កម្មវិធីស្បៀងអាហារនៅតាមសាលារៀន និងអាហារូបករណ៍ ឆ្នាំសិក្សា២០១៦-២០១៧កម្មវិធីស្បៀងអាហារនៅតាមសាលារៀនបានអនុវត្តក្នុងសាលាបឋមសិក្សា និងថ្នាក់មត្តេយ្យសិក្សា គ្រប់ក្រុងក្នុងខេត្ត ដែលគាំទ្រដោយកម្មវិធី ៥ស្រុកទាំង / ស្រី នាក់ ២៣០៥៦មានសិស្ស ១២៦ស្បៀងអាហារពិភពលោក។ សាលារៀនចំនួន នាក់ ទទួលអាហារពេលព្រឹក ១១២៨៥។ សាលារៀនចំនួន ១៤៧ មានសិស្ស ២នាក់ ទទួលអាហារូបករណ៍ជាសាច់ប្រាក់។ កម្មវិធីនេះគាំទ្រ១១៨៥នាក់ ស្រី១៦១, ដល់កុមារដែលមកពីគ្រួសារក្រីក្រ ទទួលការអប់រំប្រកបដោយសមធម៌។

- **ការអប់រំសុខភាព**

ការថែរក្សាអនាម័យ និងយកចិត្តទុកដាក់គាំទ្រផ្នែកសុវត្ថិភាព សុខភាព ត្រូវបានធ្វើឡើងជាប្រចាំដោយបានអប់រំសិស្សឱ្យមានទម្លាប់ ៖

- ហូបស្អាត ផឹកស្អាត រស់នៅស្អាត ការគ្រប់គ្រងបរិស្ថាន
- សាងសង់បង្គន់អនាម័យ កន្លែងលាងសម្អាតដែបន្ថែមបាន ០៩កន្លែង ក្នុងក្រុងសំរោង ចុងកាល់ បន្ទាយអំពិល និងស្រុកអន្លង់វែង
- គ្រប់សាលារៀនយល់ច្បាស់ពី អំពើហិង្សា ទណ្ឌកម្មលើកុមារដោយអនុវត្តតាមវិន័យបែបវិជ្ជមាន
- ការអប់រំ អំពីសុវត្ថិភាពសង្គម និងគ្រោះធម្មជាតិដូចជា (ច្បាប់ចរាចរ ខ្យល់ព្យុះ ទឹកជំនន់...)
- ហិបសង្គ្រោះបឋមត្រូវបានផ្តល់គ្រប់ចំនួនសាលារៀនក្នុងទូទាំងខេត្ត
- ផ្តល់ថ្នាំទម្លាក់ព្រូនបានគ្រប់សាលារៀន
- ចុះណែនាំការលក់នំចំណីអាហារតាមសាលារៀនបាន ២៦កម្រង
- បង្កើតការប្រកួតកីឡាសិស្សលើវិញ្ញាសាបាល់ទាត់ បាល់ទះ និងអត្តពលកម្ម ដែលមានកីឡាករ កីឡាការិនីចូលរួមចំនួន ៧០២នាក់
- បើកវគ្គបំប៉នសមត្ថភាពគ្រូអប់រំកាយ និងកីឡា និងបំប៉នស្តីពីការអនុវត្តសៀវភៅអប់រំកាយ និងកីឡាថ្នាក់ទី១ ដល់ថ្នាក់ទី៦
- ក្រុមប្រឹក្សាកុមារមានដំណើរការល្អ ៥៥%

ប្រការនេះធានាសុខភាព និងសុវត្ថិភាពដល់សិស្សានុសិស្សក្នុងការសិក្សាបានជាប់លាប់ និងជួយដល់ការលូតលាស់កាយសម្បទា និងសតិបញ្ញា។

ការងារសៀវភៅសិក្សាគោល

- **ការផ្គត់ផ្គង់សម្ភារៈសិក្សា**(សៀវភៅសិក្សាគោល)

%៩៥ភាសាខ្មែរចំនួនសៀវភៅកំពុងប្រើប្រាស់-
%៩៥គណិតវិទ្យាចំនួនសៀវភៅកំពុងប្រើប្រាស់-
%៩៥សិក្សាសង្គមចំនួនសៀវភៅកំពុងប្រើប្រាស់-
%៩៥វិទ្យាសាស្ត្រអនុវត្តចំនួនសៀវភៅកំពុងប្រើប្រាស់-

## ក-២-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

- អត្រាឡើងថ្នាក់ ៨០ ភាគរយ ស្រី៣០.៨៧៩០.ភាគរយ កើន ០៣.ភាគរយ។ អត្រាត្រួតថ្នាក់ ៧៥០.ភាគរយ ស្រី ៥៥០.ភាគរយ ថយ ០៥.ភាគរយ។ អត្រាបោះបង់ ៧២.ភាគរយ ស្រី ៦៥.ភាគរយ ថយ០២.ភាគរយ។
  - ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
  - ចាត់តាំងសមាសភាពអ្នកគ្រូ ទៅជានាយិកាសាលា
  - សាលារៀនបិទប្រកាសស្តីពីការទប់ស្កាត់អំពើហិង្សាលើកុមារគ្រប់រូបភាព
  - ការយកចិត្តទុកដាក់នឹងធានាឱ្យកុមារីបានទទួលលទ្ធភាពចូលរៀនដោយពេញលេញ ស្មើភាព និងទទួលការអប់រំប្រកបដោយគុណភាព ។

### ក.២.១ ការប្រៀបធៀបមធ្យមភាគឡើងថ្នាក់,ត្រួតថ្នាក់ ពេលទទួលអាហារូបករណ៍

| **បរិយាយ** | សរុប | ស្រី |
|---|---|---|
| អត្រាឡើងថ្នាក់ពេលទទួលអាហារូបករណ៍ ២០១៥-២០១៦ | 85 | 87 |
| អត្រាឡើងថ្នាក់ពេលទទួលអាហារូបករណ៍ ២០១៦-២០១៧ | 85.3 | 87.9 |
| **កើន/ថយ** | 0.3 | 0.9 |
| អត្រាត្រួតថ្នាក់ពេលទទួលអាហារូបករណ៍ ២០១៥-២០១៦ | 8 | 6 |
| អត្រាត្រួតថ្នាក់ពេលទទួលអាហារូបករណ៍ ២០១៦-២០១៧ | 7.5 | 5.5 |
| **កើន/ថយ** | -0.5 | -0.5 |
| មធ្យមភាគឡើងថ្នាក់ពេលទទួលអាហារូបករណ៍ ២០១៥-២០១៦ | 95.00 | 96.88 |
| មធ្យមភាគឡើងថ្នាក់ពេលទទួលអាហារូបករណ៍ ២០១៦-២០១៧ | 97.45 | 98.32 |
| **កើន/ថយ** | 2.45 | 1.44 |

ផ្អែកតាមទិន្នន័យខាងលើ យើងសង្កេតឃើញថា ពេលមានអាហារូបករណ៍ពីរឆ្នាំកន្លងមក អត្រាឡើងថ្នាក់មានសភាពកើនឡើង អត្រាត្រួតថ្នាក់មានការថយចុះ រីឯសិស្សជាប់មធ្យមភាគចុងឆ្នាំសិក្សា២០១៦មានការកើនឡើង នេះក៏បណ្តាលមកពីមូលហេតុមួយចំនួន ដូចជា ការចុះជួយ២០១៧-/របស់ក្រុមការងារមន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក លើការងារគ្រប់គ្រង ការជួយលើវិធីសាស្ត្របង្រៀន ការងារទំនាក់ទំនងជាមួយអ្នកអាណាព្យាបាលរបស់សិស្សក្រីក្រ និងការទប់ស្កាត់មានមិនប្រក្រតីតាមសាលារៀន។

តេស្តចុងឆ្នាំអនុវត្តបានគ្រប់ក្រុង។ល ៥ស្រុកទាំង/ទូផលតេស្តចុងឆ្នាំ សិស្សបានធ្វើតេស្ត ៣៩៤១,នាក់ ស្រី ១,៩៥៣នាក់ សិស្សជាប់តេស្តសរុប ១,២២៨នាក់ ស្មើនឹង ៣១០៦.ភាគរយ ស្រី

៤៨៧នាក់ ស្មើនឹង ៣៣៥២.ភាគរយ។ លទ្ធផលតេស្តដើមឆ្នាំសិក្សា២០១៧សិស្សបានធ្វើតេ ២០១៨- ស្តុ២៧៥៧,នាក់ ស្រី ៩៧៤នាក់ សិស្សជាប់តេស្តសរុប៥៤២នាក់ ស្មើនឹង ១៩៦៦.ភាគរយ ស្រី ១៧៩នាក់ ស្មើនឹង ១៨៣៨.ភាគរយ។ សរុបសិស្សជាប់តេស្តសរុបរួម ១៧៦៦.នាក់ ស្មើនឹង ៤០៦៧. ភាគរយ ក្នុងនោះស្រី ៦៦៦នាក់ ស្មើនឹង៤១៦៣.ភាគរយ ។ លទ្ធផលនេះត្រូវបានផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋាន ដើម្បីផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ។

ប្រការនេះ ទាមទារឱ្យក្រុម DTMT ជួយពង្រឹងការបង្រៀន និងរៀន ដោយផ្តោតលើការងារបច្ចេកទេស។

លំនាំនៃការកើនឡើង និងថយចុះនៃអត្រាលំហូរនៅបឋមសិក្សាមានសភាពប្រហាក់ប្រហែលគ្នាក្នុងខេត្ត តំបន់ជនបទ និងប្រជុំជន។

តារាងទី៤ ៖ អត្រាលំហូរសិស្សនៅបឋមសិក្សា រវាងឆ្នាំសិក្សា ភូមិសាស្ត្រ និង យេនឌ័រ

| | | អត្រាលំហូរ (សរុប) | | | អត្រាលំហូរ (ស្រី) | | | អត្រាលំហូរ (ប្រុស) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
| ២០១៦២០១៧- | ខេត្ត | 85.3 | 7.5 | 7.2 | 87.9 | 5.5 | 6.5 | 82.9 | 9.2 | 7.8 |
| | ប្រជុំជន | 84.4 | 8.8 | 6.8 | 87.2 | 6.7 | 6.0 | 81.8 | 10.8 | 7.4 |
| | ជនបទ | 85.7 | 6.9 | 7.4 | 88.2 | 5.1 | 6.7 | 83.4 | 8.6 | 8.0 |
| ២០១៥២០១៦- | ខេត្ត | 85 | 8 | 7 | 87 | 6 | 6 | 83 | 10 | 8 |
| | ប្រជុំជន | 80 | 10 | 10 | 83 | 8 | 9 | 76 | 13 | 11 |
| | ជនបទ | 87 | 7 | 6 | 89 | 6 | 5 | 85 | 9 | 6 |

អត្រាបញ្ចប់ការសិក្សាបឋមសិក្សាបានថយចុះ ២០៣.ភាគរយ ស្រី ១៩ ភាគរយ និងប្រុស១. ២០២.ភាគរយ។ប្រការនេះត្រូវទាមទារឱ្យថ្នាក់មូលដ្ឋានត្រូវពិនិត្យឱ្យបានច្បាស់លាស់ចំពោះលិខិតបញ្ជាក់កំណើតរបស់សិស្ស និងត្រូវធ្វើជំរឿនស្ថិតិឱ្យមានភាពជាក់លាក់។

| | អត្រាបញ្ចប់ការសិក្សា ២០១៦២០១៧- | | | អត្រាបញ្ចប់ការសិក្សា ២០១៧២០១៨- | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| ថ្នាក់ខេត្ត | 88 | 90 | 85 | 67.70 | 70.90 | 64.80 |

| | | | | | | |
|---|---|---|---|---|---|---|
| ប្រជុំជន | 86 | 84 | 88 | 67.60 | 73.70 | 61.90 |
| ជនបទ | 88 | 93 | 85 | 67.80 | 69.80 | 66.00 |

➢ **ការបណ្តុះបណ្តាល និង វិក្រឹតការគ្រូបង្រៀន**

- បើកវគ្គបំប៉ុនបច្ចេកទេសបង្រៀនថ្នាក់គួបដែលមានសិក្ខាមចូលរួមចំនួន ៨៤នាក់
- ពង្រាយគ្រូចេញថ្មី (៣៤ជំនាន់ទី)តាមបណ្តាក្រុង ស្រុកទាំងប្រាំក្នុងខេត្តចំនួន/៤៣ នាក់ ស្រី ២៣នាក់
- គរុសិស្សជំនាន់ទី៣៥ កំពុងបណ្តុះបណ្តាលនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាម ចំនួន ៤៣នាក់ ស្រី ២៧នាក់
- ប្រឡងជ្រើសរើសគ្រូបឋមសិក្សាសម្រាប់ជំនាន់ទី៣៦ ចំនួន ៥៥នាក់
- បំប៉ុនគ្រូបឋមសិក្សាវេនទី២ជំនាន់១០ ចំនួន ២៤នាក់ ស្រី ៥នាក់ និងវេនទី១ជំនាន់ទី ១១ ចំនួន ២៤នាក់ ស្រី ៥នាក់ ឱ្យទៅជាគ្រូកម្រិតមូលដ្ឋាន

➢ **ការងារបណ្ណាល័យ**

ស្តង់ដាបណ្ណាល័យបឋមសិក្សា បានដាក់ឱ្យអនុវត្តនៅតាមបណ្ណាល័យសាលារៀនក្នុងទូទាំងខេត្ត។ បណ្ណាល័យសរុបមាន ៥៤ ក្នុងនោះបណ្ណាល័យជាអគារមានចំនួន៣ កើន ១ , បន្ទប់បណ្ណាល័យមានចំនួន ៣៨ កើន ១១ , និងក្នុងទីចាត់ការមានចំនួន១៣ ថយ ១ ។ រៀបចំទិវាជាតិអំណាន នាថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៧ អនុវត្តបានចំនួន ៣ក្រុងស្រុក គឺក្រុង/សំរោង ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ដែលមានសិស្សានុសិស្សចូលរួមចំនួន ៤៩៧២,នាក់ ស្រី១២៣០,នាក់ លោកគ្រូ អ្នកគ្រូចំនួន/១៥០នាក់ ស្រី៦៨នាក់ សហគមន៍ ៤៨នាក់។

ប្រការនេះបានធ្វើឱ្យកុមារមានទម្លាប់ ក្នុងការអាន និងសិក្សាស្រាវជ្រាវបន្ថែម ព្រមទាំងមានការចូលរួមពីសហគមន៍កាន់តែប្រសើរឡើង។ ដូច្នេះយើងត្រូវពង្រឹងបន្ថែមទៀតចំពោះសាលារៀនដែលមិនបានអនុវត្តអំពីទិវាអំណាននេះ នាឆ្នាំបន្តបន្ទាប់។

➢ **ការពិនិត្យតាមដាន និងវាយតម្លៃ**

- ចុះអធិការកិច្ចជួយសាលារៀនបានចំនួន២០លើក ស្មើ៧៥សាលា ដោយផ្តោតលើការងារគ្រប់គ្រង និងការបង្រៀន
- ជំរុញ និងចុះជួយលើការបំពេញរបាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល

- ជំរុញ និងចុះជួយលើការបំពេញរបាយការណ៍អាហារូបករណ៍ និងពិនិត្យតាមដានពេលបើក អាហារូបករណ៍ជូនសិស្សក្រីក្រ

## ក-៣-ការលើកកម្ពស់ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង

ចូលរួម-សិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវទិន្នន័យគោល EMIS ឆ្លើយតបនឹងសូចនាករ SDG4(នៅខេត្តកំពត)

ចូលរួម-សិក្ខាសាលាស្តីពីការផ្សព្វផ្សាយឯកសារស្តង់ដានាយកសាលារៀន នៅខេត្តពោធិ) (សាត់

ចូលរួម-សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីស្តង់ដាសាលាបឋមសិក្សា នៅខេត្ត) (កំពង់ធំ

ចូលរួមសិក្ខាសាលាស្តីពីការរៀបចំទម្រង់ផ្សារភ្ជាប់រវាងផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់រាជ- (នៅខេត្តកំពត) ខ័ណ្ឌ និងសាលារៀន-ស្រុក-ខេត្ត ក្រុង-ធានី

ចូលរួមសិក្ខ-ាសាលាស្តីពីការពិនិត្យ និងកែសម្រួលលើការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៥/ថ្នាក់រាជធានី ២០១៧-ខេត្ត (នៅខេត្តកំពង់ឆ្នាំង)

(នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ) ចូលរួមវគ្គបំប៉នស្តីពីការអប់រំបរិយាបន្ន-

ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តង់ដាសាលាប-បមសិក្សា (នៅខេត្តព្រះវិហារ)

២០៣០ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ- (នៅខេត្តកំពង់ចាម) ស្តីពីការអប់រំនៅកម្ពុជា

ចូលរួមប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី និងសហគមន៍ចូលរួម-

អភិវឌ្ឍវិស័យអប់រំឆ្នាំសិក្សា២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា២០១៧នៅ) ២០១៨- (ខេត្តកំពង់ចាម

## ខ-ការវិភាគអំពីវឌ្ឍនភាពនៃសូចនាករផលសម្រេច

| | ការអប់រំបឋមសិក្សា | ជាក់ស្តែង 2016-2017 | ចំណុចដៅ 2017-2018 | ជាក់ស្តែង 2017-2018 | ស្ថានភាព |
|---|---|---|---|---|---|
| ១ | ភាគរយសាលាកុមារមេត្រី កម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ | 60.68 | 62 | na | |
| ២ | អត្រាពិតចូលរៀនថ្មី | 81 | 98 | 88.70 | ⇩ |
| | អត្រាពិតចូលរៀនថ្មី (ស្រី) | 79 | 98 | 88.40 | ⇩ |

| | | | | | |
|---|---|---|---|---|---|
| ៣ | អត្រាពិតនៃការសិក្សា | 98 | 95.50 | 84.20 | ⇩ |
| | អត្រាពិតនៃការសិក្សា (ស្រី) | 97 | 95.50 | 85.20 | ⇩ |
| ៤ | អត្រាបោះបង់ការសិក្សា | 7 | 5 | 7.20 | ⇩ |
| | អត្រាបោះបង់ការសិក្សា (ស្រី) | 6 | 5 | 6.50 | ⇩ |
| ៥ | អត្រាត្រួតថ្នាក់ | 8 | 4 | 7.50 | ⇩ |
| | អត្រាត្រួតថ្នាក់ (ស្រី) | 6 | 4 | 5.50 | ⇩ |
| ៦ | អត្រាបញ្ចប់ការសិក្សា | 88 | 86 | 67.70 | ⇩ |
| | អត្រាបញ្ចប់ការសិក្សា (ស្រី) | 90 | 86 | 70.90 | ⇩ |
| ៧ | ភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | 72.13 | 70 | 44.22 | ⇩ |
| ៨ | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | 80 | 82 | 81 | ⇨ |
| | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 83 | 82 | 84 | ⇧ |
| ៩ | ភាគរយសាលាបឋមសិក្សាមាន | | | | |
| | បង្គន់អនាម័យនិងទឹកស្អាត | 42 | 45 | 46.28 | ⇧ |
| | កន្លែងសម្អាតដៃ | 11.17 | 50% | 33.17 | ⇩ |
| | ប្រអប់សង្គ្រោះបឋម | 22.33 | 100% | 98.13 | ⇨ |
| ១០ | ចំនួនសិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា | 2161 | 2161 | 2161 | |

សម្គាល់:⇧សម្រេចបានតាមចំណុចដៅ⇨អាចទទួលយកបាន ⇩សម្រេចមិនបានតាមចំណុចដៅ

**គ-បញ្ហាប្រឈម**

- ការចុះជួយសាលារៀនរបស់ក្រុមពិនិត្យ និងបំប៉នថ្នាក់ក្រុង/ស្រុក (M & E) និងការប្រើប្រាស់ឧបករណ៍វាយតម្លៃសាលា និងថ្នាក់រៀនមានការលំបាក ។
- បណ្ណាល័យភាគច្រើនមិនត្រឹមត្រូវតាមស្តង់ដារ ខ្វះសៀវភៅ និងបន្ទប់សមរម្យ
- ការអនុវត្តកាលវិភាគ និងការអនុវត្តម៉ោងសិក្សាពុំទាន់បានត្រឹមត្រូវ
- ការរៀបចំបរិស្ថានសាលារៀនមិនទាន់ស្អាត និង សាលារៀនមានសុវត្ថិភាព
- សិស្សបោះបង់ការសិក្សា 7,2 % អត្រាត្រួតថ្នាក់7,5% នៅតែច្រើន នៅឆ្នាំ២០១៧-២០១៨
- ថវិកាធ្លាក់មកយឺតមិនទាន់ពេល(អាហាររូបករណ៍) ។
- ឯកសារទូទាត់ច្រើន ។

- នាយកសាលាមិនយល់ពីរបៀបទូទាត់ថវិកានិងរៀបចំរបាយការណ៍រីកចម្រើន មិនយល់ពីតារាងបញ្ជីតាមដានធនាគារ និង បេឡា ការបំពេញរបាយការណ៍ចំណូលចំណាយនិងរបាយការណ៍វឌ្ឍនភាព មិនទាន់ច្បាស់លាស់លើចំណុចមួយចំនួន ។
- មិនទាន់ច្បាស់ច្បាស់លើការធ្វើផែនការ អភិវឌ្ឍសាលារៀន ។
- នាយកមួយចំនួន មិនទាន់យលច្បាស់ ពីការបំពេញរបាយការណ៍ ប្រព័ន្ធត្រួតពិនិត្យតាមដានផ្អែកលើលទ្ធផល។
- គ្រូមួយចំនួនមិនធ្វើកិច្ចតែងការបង្រៀន ។
- មន្ត្រីការិយាល័យ អប់រំស្រុក ម្នាក់ទទួលបន្ទុកការងារច្រើន ផ្នែក ។

**២-២-៣-អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស**

**ក-លទ្ធផលសម្រេចបាន**

**ក-១-ការធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយ សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា**

ឆ្នាំសិក្សា ២០១៧-២០១៨ គ្រឹះស្ថានមធ្យមសិក្សាមាន ៣៧ ក្នុងនោះ អនុវិទ្យាល័យ ២៨ សាលា (សិស្សសរុប ៥២២៩នាក់ ស្រី២៦៤៧នាក់ និងបុគ្គលិកសរុប ២៣១ នាក់ ស្រី ៧៣នាក់ ) និង វិទ្យាល័យ ៩ ចែកចេញជា វិទ្យាល័យ ពីថ្នាក់ទី៧ ដល់ទី១២មាន ៧សាលា (សិស្សសរុប ៥៧៦៥នាក់ ស្រី២៩២៩នាក់ និងបុគ្គលិកសរុប ២៣៦ នាក់ ស្រី ៧៦នាក់ ) និងវិទ្យាល័យពីថ្នាក់ទី១០ ដល់ ទី១២ មាន ២សាលា (សិស្សសរុប ១៦១៣នាក់ ស្រី៨៣១ នាក់ និងបុគ្គលិកសរុប ៦១ នាក់ ស្រី១៥ នាក់ )។

- អនុវិទ្យាល័យចំនួន១ត្រូវបានបង្កើតថ្មី និងអនុវិទ្យាល័យ ២កន្លែងបានពង្រីកទៅជាវិទ្យាល័យ ក្នុងចំណោមវិទ្យាល័យទាំង៩ និង មាន វិទ្យាល័យធនធាន ១ ។
- គ្រប់ឃុំ/សង្កាត់ មានអនុវិទ្យាល័យ អនុវិទ្យាល័យ និងវិទ្យាល័យ មួយចំនួនទៀតនៅមានបញ្ហាខ្វះអគារសិក្សា ដូចជា អនុវិទ្យាល័យឈូក អនុវិទ្យាល័យគោកខ្ពស់ វិទ្យាល័យបន្ទាយអំពិល និង អនុវិទ្យាល័យរំចេក គ្មានអគារ រៀនក្នុងរោងដោល ។
- អនុវិទ្យាល័យចំនួន២៨ មានបង្គន់អនាម័យ និង២០មានទឹកស្អាតប្រើប្រាស់ ។
- វិទ្យាល័យចំនួន៩ មានបង្គន់អនាម័យ និង៨មានទឹកស្អាតប្រើប្រាស់ ។
- មធ្យមសិក្សាបឋមភូមិមានបុគ្គលិកអប់រំ ២៣១នាក់ ស្រី ៧៣នាក់ ថយ ៥៣នាក់ ស្រី២៥ ក្នុងនោះបុគ្គលិកបង្រៀន១៨៩នាក់ ស្រី៧២នាក់ កើន ៤៧នាក់ ស្រី ២២នាក់ និងបុគ្គលិកមិនបង្រៀន ៤២នាក់ ស្រី ១នាក់ ។
- មធ្យមសិក្សាទុតិយភូមិមានបុគ្គលិកអប់រំ ២៩៧នាក់ ស្រី ៩១នាក់ កើន៥២ នាក់ស្រី ២៥នាក់ ក្នុងនោះបុគ្គលិកបង្រៀន២៥៣នាក់ ស្រី៨០នាក់ កើន៤៧នាក់ ស្រី ២៥នាក់ និងបុគ្គលិកមិនបង្រៀន៤៤នាក់ ស្រី ១១ នាក់ ។
- សិស្សមធ្យមសិក្សាបឋមភូមិសរុប ៩០៥៨នាក់ ស្រី ៤៦១១នាក់ កើន៤៥៩នាក់ ស្រី១៥០នាក់
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៥៥,៧០ភាគរយ ស្រី៥៨,៧ ភាគរយ
- អត្រាឆ្លងភូមិសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ៨១,០០ភាគគរយ ស្រី៨៤,៣០ ភាគរយ

- សិស្សមធ្យមសិក្សាទុតិយភូមិសរុប៣៥៥២នាក់ស្រី១៧៩៦នាក់កើន៥១៧នាក់ស្រី២៦៨នាក់
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ១៨,៩០ភាគរយ ស្រី១៩,៦០ ភាគរយ ។
- អត្រាឆ្លងភូមិសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ៧២,២០ភាគរយ ស្រី៧២,២០ ភាគរយ ។

*ស្ថិតិមធ្យមសិក្សា ប្រៀបធៀបរវាងឆ្នាំសិក្សា ២០១៦-២០១៧និង២០១៧-២០១៨*

| បរិយាយ | ២០១៦-២០១៧ | ២០១៧-២០១៨ | កើន-ថយ |
|---|---|---|---|
| ***អនុវិទ្យាល័យ(ថ្នាក់ទី ៧ ដល់ ទី ៩ )*** | | | |
| សាលារៀន | 29 | 28 | -1 |
| ថ្នាក់រៀន | 139 | 139 | ថេរ |
| បន្ទប់រៀន | 153 | 143 | -10 |
| សិស្សសរុប | 6267 | 5229 | -1038 |
| សិស្សស្រី | 3245 | 2647 | -589 |
| បុគ្គលិកបង្រៀនសរុប | 236 | 189 | -47 |
| បុគ្គលិកបង្រៀនស្រី | 94 | 72 | -22 |
| បុគ្គលិកអប់រំសរុប | 284 | 231 | -53 |
| បុគ្គលិកអប់រំស្រី | 98 | 73 | -25 |
| ***វិទ្យាល័យ (ថ្នាក់ទី ៧ ដល់ ១២ )*** | | | |
| សាលារៀន | 5 | 7 | +2 |
| ថ្នាក់រៀន | 78 | 123 | +45 |
| បន្ទប់រៀន | 75 | 103 | +28 |
| សិស្សសរុប | 3829 | 5768 | +1939 |
| សិស្សស្រី | 1956 | 2929 | +973 |
| បុគ្គលិកបង្រៀនសរុប | 154 | 205 | +51 |
| បុគ្គលិកបង្រៀនស្រី | 42 | 70 | +28 |

| | | | |
|---|---|---|---|
| បុគ្គលិកអប់រំសរុប | 181 | 236 | +55 |
| បុគ្គលិកអប់រំស្រី | 49 | 76 | +27 |
| វិទ្យាល័យ(ថ្នាក់ទី១០ ១២) | | | |
| សាលារៀន | 2 | 2 | ថេរ |
| ថ្នាក់រៀន | 35 | 39 | +4 |
| បន្ទប់រៀន | 61 | 61 | ថេរ |
| សិស្សសរុប | 1538 | 1613 | +75 |
| សិស្សស្រី | 788 | 831 | +43 |
| បុគ្គលិកបង្រៀនសរុប | 52 | 48 | -4 |
| បុគ្គលិកបង្រៀនស្រី | 13 | 10 | -3 |
| បុគ្គលិកអប់រំសរុប | 64 | 61 | -3 |
| បុគ្គលិកអប់រំស្រី | 17 | 15 | -2 |

***ការអនុវត្តកម្មវិធីនានា***

**កម្មវិធីផ្តល់អាហារូបករណ៍ សិស្សក្រីក្រមធ្យមសិក្សា ( ឆ្នាំសិក្សា ២០១៧ -២០១៨)**

- កម្មវិធីអាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ បានគ្របដណ្តប់លើសាលារៀន២៤ ដែល មាន ចំនួន២១៣៧ នាក់ ស្រី ១២៧៣នាក់ គាំទ្រដោយថវិកាជាតិ ។
- កម្មវិធីបានផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាទុតិយភូមិបានគ្របដណ្តប់លើសាលារៀន ៤ ដែលមាន ចំនួន៣៥៨ នាក់ ស្រី ២១០ នាក់ គាំទ្រដោយថវិកាជាតិ ។

➢ ***ការអប់រំបំណិនជីវិត***

មន្ទីរអប់រំបានៈ ជំរុញការពង្រីកកម្មវិធីអប់រំបច្ចេកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សា មាន សាលា៥ បានអនុវត្ត លើផ្នែកកសិកម្ម (ត្រឡាច ត្រសក់ សណ្តែកគួ ត្រកួន ដែលឧបត្ថម្ភដោយ អង្គការ CIDO)ដូចជា អនុវិទ្យាល័យបន្សាយរាក់ វិទ្យាល័យតេជោសែនសំរោង អនុវិ. បុស្សូវ និងអនុវិ.ស្វាយរ៉ែកគុណពោធិវង្ស។

ជំរុញការអនុវត្តកម្មវិធីបំណិនជីវិត លើមុខវិជ្ជា គេហវិទ្យាប៉ុន្តែតាមគ្រឹះស្ថានមធ្យមសិក្សាទាំងអស់ សិក្សាតែទ្រឹស្តីប៉ុណ្ណោះ ។ នៅវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ បានអនុវត្តមុខវិជ្ជា កុំព្យូទ័រ ។

មន្ទីរបានទទួល ឯកសារ រៀន និងបង្រៀន ផ្នែកអប់រំបំណិនជីវិត ២៣ប្រធានបទ ស្មើ ៩០ ក្បាល

➢ ***ការងារតម្រង់ទិសវិជ្ជាជីវៈ***

មន្ទីរអប់រំបាន ៖បញ្ជូនមន្ត្រីជំនាញ និងនាយកសាលាចំនួន ០១នាក់ ឱ្យទៅចូលរួម វគ្គបំប៉នគ្រូបង្គោលស្តីពី ការប្រើប្រាស់ឯកសារការអប់រំតម្រង់ទិសវិជ្ជាជីវៈសម្រាប់មធ្យមសិក្សាបឋមភូមិ ។

កម្មវិធីនេះ បានជួយតម្រង់ទិសសិស្សឱ្យស្គាល់មុខរបរ ចេះជ្រើសរើសមុខរបរ និងគន្លងសិក្សាទៅ ថ្ងៃអនាគតបានត្រឹមត្រូវស្របតាមចំណង់ចំណូលចិត្ត សមត្ថភាព និងឧបនិស្ស័យរបស់ខ្លួន ។

## ក-២-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់

- អត្រាឡើងថ្នាក់ នៅមធ្យមសិក្សាបឋមភូមិ កើន២ភាគរយ និងមធ្យមសិក្សាទុតិយភូមិ កើន ៥,៧ ភាគរយ ។
- អត្រាត្រួតថ្នាក់ នៅមធ្យមសិក្សាបឋមភូមិ ថយ ០,៦ ភាគរយ និងមធ្យមសិក្សាទុតិយភូមិ ថយ ០,៥% ។
- អត្រាបោះបង់ការសិក្សា នៅមធ្យមសិក្សាបឋមភូមិ ថយ១,៤ ភាគរយ និងមធ្យមសិក្សាទុតិយភូមិ ថយ ៥,១ ភាគរយ ។

*អត្រាលំហូរសិស្ស នៅមធ្យមសិក្សា រវាង ឆ្នាំសិក្សា ២០១៥-២០១៦ និង២០១៦-២០១៧*

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | | | មធ្យមសិក្សាទុតិយភូមិ | | | |
|---|---|---|---|---|---|---|---|---|
| | 2015-2016 | | 2016-2017 | | 2015-2016 | | 2016-2017 | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អត្រាឡើងថ្នាក់ | 76.0% | 76.8% | 78% | 78,7% | 80.6% | 82.7% | 86,3% | 80,00% |
| អត្រាត្រួតថ្នាក់ | 4.3% | 2.6% | 3,7% | 2,6% | 1.8% | 1.1% | 1,3% | 0,7% |
| អត្រាបោះបង់ | 19.7% | 20.6% | 18,3% | 18,7% | 17.6% | 16.2% | 12,5% | 17,5% |
| អត្រាឆ្លងភូមិសិក្សា | 79.9% | 82.9% | 81,00% | 84,3% | 66.0% | 66.5% | 72,2% | 72,2% |
| អត្រារួមនៃការសិក្សា | 55.7% | 58.7% | 4,8% | 44,4% | 18.9% | 19.6% | 17,2% | 18% |

- ផលធៀបសិស្សគ្រូនៅមធ្យមសិក្សាបឋមភូមិកើនពី២៦ ទៅ ២៨ និង២៦ ទៅ២៩ នៅមធ្យមសិក្សាទុតិយភូមិ
- ផលធៀបសិស្ស-ថ្នាក់រៀនថេរនៅមធ្យមសិក្សាបឋមភូមិ ៤៥ និងថយពី៤៧ មក ៤៦ នៅមធ្យមសិក្សាទុតិយភូមិ
- ផលធៀបសិស្ស-បន្ទប់រៀន នៅមធ្យមសិក្សាបឋមភូមិកើនពី៤១ មក ៤៥ និងកើនពី៣៩ មក ៤៥ នៅមធ្យមសិក្សាទុតិយភូមិ ។

*ផលធៀបសំខាន់ៗនៅមធ្យមសិក្សារវាងឆ្នាំសិក្សា ២០១៦-២០១៧ និង២០១៧-២០១៨*

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | មធ្យមសិក្សាទុតិយភូមិ | |
|---|---|---|---|---|
| | 2016-2017 | 2017-2018 | 2016-2017 | 2017-2018 |
| ផលធៀបសិស្ស - គ្រូ | 26 | 28 | 26 | 29 |

| | | | | |
|---|---|---|---|---|
| ផលធៀបសិស្ស-ថ្នាក់រៀន | 45 | 45 | 47 | 46 |
| ផលធៀបសិស្ស-បន្ទប់រៀន | 41 | 37 | 39 | 45 |

លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សា *( ឆ្នាំសិក្សា ២០១៦ -២០១៧ )*

- បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ចំនួន **១៦៩៣** នាក់ស្រី **៨៨៩** នាក់ ស្មើនឹង**៩០.៤៥% ស្រី ៩០.៩០%** ធៀបឆ្នាំចាស់កើន ៣.៧៧% ស្រី ០.៧០% ។
- បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន **៨៣៦** នាក់ ស្រី **៤១៤** នាក់ ស្មើនឹង ៨៨,**៩៤%** ស្រី៩២,៦២% % ធៀបឆ្នាំចាស់កើន១០.៥៣ % ស្រី១០.២២ % (ចំណាត់ថ្នាក់លេខ៣ ទូទាំងប្រទេស)។
- ចំពោះបេក្ខជនទទួលបាននិទ្ទេស A មានចំនួន ០០នាក់ ស្រី០០នាក់ និទ្ទេស Bមានចំនួន១១ នាក់ស្រី០៤នាក់ និទ្ទេស C មានចំនួន ៧០នាក់ ស្រី ៣៧នាក់ និទ្ទេស Dមានចំនួន ១៦៧ នាក់ ស្រី៩០នាក់ និង និទ្ទេស Eមានចំនួន ៥៨៨ នាក់ ស្រី ២៨៣នាក់ ។

លទ្ធផលការប្រឡងជ្រើសរើសសិស្សពូកែមន្ទីរអប់រំបាន៖ រៀបចំប្រឡងជ្រើសរើសសិស្សពូកែទូទាំងខេត្ត ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី ៩ និងទី១២ និងជ្រើសរើសជ័យលាភី បាន ៦នាក់ ស្រី ០១ នាក់ លើ ចំនួនបេក្ខជនសិស្សពូកែ ថ្នាក់ ក្រុង/ស្រុក សរុប ១៣១នាក់ ស្រី៦៦ នាក់ នៅមណ្ឌលប្រឡង វិទ្យាល័យហ៊ុន សែន ឧត្តរមានជ័យ ក្រុងសំរោង ដែលក្នុងមួយមុខវិជ្ជា និងមួយកម្រិតថ្នាក់ជ្រើសរើសបាន ១នាក់ ។

ចំពោះលទ្ធផល គឺ ផ្នែកអក្សរសិល្ប៍ គណិតវិទ្យា ថ្នាក់ទី១២ បានទៅ វិ.ហ៊ុន សែនឧត្តរមានជ័យ ផ្នែក រូបវិទ្យាថ្នាក់ទី ១២ គណិតវិទ្យា ថ្នាក់ទី៩ បានទៅ វិទ្យាល័យអន្លង់វែង ផ្នែក រូបវិទ្យាថ្នាក់ទី៩ បានទៅ អនុវិទ្យាល័យសំរោង និងផ្នែកអក្សរសិល្ប៍ ថ្នាក់ទី៩ បានទៅអនុវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រីយ៍ ។

ដឹកនាំសិស្សពូកែចំនួន០៦នាក់ ស្រី០១នាក់ ទៅចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសនៅមណ្ឌលវិទ្យាល័យ ព្រះមុនីវង្ស ខេត្តបាត់ដំបង នាសម័យប្រឡង ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៧ ។

ការអនុវត្តកម្មវិធីសិក្សាមន្ទីរអប់រំបាន ៖

- ណែនាំឱ្យបង្រៀនអត្ថបទអក្សរសិល្ប៍ នៅតាមគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- ជំរុញការបញ្ជ្រៀបការអប់រំការប្រឆាំងអំពើពុករលួយនៅមធ្យមសិក្សាបឋមភូមិ
- ជំរុញការបង្រៀនសរសេរតាមអាននៅមធ្យមសិក្សាបឋមភូមិ
- ជំរុញការរៀន និងបង្រៀន ដោយផ្តោតការយកចិត្តទុកដាក់លើផ្នែក កុំព្យូទ័រ ពិសោធន៍ វិទ្យាសាស្ត្រ និងបណ្ណាល័យ វិទ្យាល័យ ធនធាន (វិ.ហាស ឧត្តរមានជ័យ )
- ការអនុវត្តកម្មវិធីសិក្សា ៩៨ភាគរយ នៅថ្នាក់ទី ៩ កម្រិត ថ្នាក់ដទៃទៀត ពី ៩៥ទៅ ៩៧ ភាគរយ និងថ្នាក់ទី ១២ ស្មើ១០០ភាគរយ ។

## ការផ្គត់ផ្គង់សៀវភៅសិក្សាគោល

- ○ មធ្យមសិក្សាបឋមភូមិ(ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩) ក្នុងឆ្នាំសិក្សា២០១៦-២០១៧បាន ទទួលសៀវភៅសិក្សាគោលចំនួន ១៤៧៨៥ក្បាល លើមុខវិជ្ជា ភាសខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម ។
- ○ មធ្យមសិក្សាទុតិភូមិ(ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២) ក្នុងឆ្នាំសិក្សា២០១៦-២០១៧ បាន ទទួល សៀវភៅសិក្សាគោលចំនួន ៣១៦០ ក្បាល លើមុខវិជ្ជា ភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម រូបវិទ្យា គីមី ជីវវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា សេដកិច្ច និង ICT
- ○ ការងារបណ្ណាល័យៈសាលាចំនួន២ លើ ៣១សាលា បានរៀបចំបណ្ណាល័យ និងបាន រៀបចំ សិស្សចូលអានដូចជាវិទ្យាល័យតេជោសែនសំរោង វិទ្យាល័យ ហ៊ុនសែន ឧត្តរ មានជ័យ ។

## ក-៣-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្តោតលើកលទ្ធផលមន្ទីរអប់រំបានៈ

- ○ ចុះពិនិត្យតាមដានការប្រឡងឆមាស និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

ការអភិវឌ្ឍសមត្ថភាព

- បានបញ្ជូន មន្ត្រី ចំនួន០១នាក់ ស្រី០១នាក់ ទៅចូលរួមវគ្គបំប៉ន ស្តីពី មូលដ្ឋានគ្រឹះ នៃការ គ្រប់គ្រងនិងបែងចែកធនធានអប់រំនៅខេត្តកំពត ។
- បានបញ្ជូន មន្ត្រី ចំនួន០១នាក់ ស្រី០០នាក់ ទៅចូលរួមវគ្គបំប៉ន ស្តីពី ការរៀបចំផែនការ តាម អនុវិស័យសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅខេត្តកំពង់ចាម។
- បានបញ្ជូន មន្ត្រី ចំនួន០១នាក់ ស្រី០១នាក់ ទៅចូលរួមវគ្គបំប៉ន ស្តីពី ការរៀបចំទម្រង់ផ្សារ ភ្ជាប់រវាងផែនការប្រតិបត្តិប្រចាំឆ្នាំ ថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន នៅ ខេត្តកំពត។
- បានបញ្ជូន មន្ត្រី ចំនួន០២នាក់ ស្រី០១នាក់ ទៅចូលរួមសិក្ខាសាលា ស្តីពី ការងារបណ្ណាល័យ និងស្តង់ដារបណ្ណាល័យសាលាមធ្យមសិក្សា នៅខេត្តបាត់ដំបង។
- បានបញ្ជូន មន្ត្រី ចំនួន០១នាក់ ស្រី០០នាក់ ទៅចូលរួមសិក្ខាសាលា ស្តីពី គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា នៅខេត្តកំពង់ចាម។
- បានបញ្ជូន មន្ត្រី ចំនួន០២នាក់ ស្រី០១នាក់ ទៅចូលរួមសិក្ខាសាលា ស្តីពីរបៀបទូទាត់ថវិកា ការរៀបចំផែនការ និងការគ្រប់គ្រងដំណើរការប្រតិបត្តិអគារធនធាន និងសាលាមធ្យមសិក្សា បណ្តាញ នៅខេត្តពោធិ៍សាត់ ។

## ខ-ការវិភាគអំពីវឌ្ឍនភាពនៃសូចនាករផលសម្រេច

### ការវិភាគសូចនាករផលសម្រេច

| III | ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ជាក់ស្តែង 2016-17 | ចំណុចដៅ 2017-18 | ជាក់ស្តែង 2017-18 | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី ១៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| 1 | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 19,7% | 18% | 18.3% | ↑ |
| | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ស្រី) | 20,6% | 19% | 18,7% | → |
| 2 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 43,9% | 50,5% | 44,80% | ↑ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ស្រី) | 47,3% | 48,5% | 47,4% | ↑ |
| 3 | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 17,9% | 12% | 12,5% | ↑ |
| | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ(ស្រី) | 17,2% | 14% | 17,5% | ↑ |
| 4 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 15,2% | 18,5% | 12,2% | ↑ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ(ស្រី) | 15,80% | 19% | 18% | ↑ |
| 5 | អត្រាឆ្លងភូមិសិក្សាពីបឋម ចូល ម.បឋមភូមិ | 79,9% | 82,5% | 81.00% | ↑ |
| | អត្រាឆ្លងភូមិសិក្សាពីបឋមចូល ម.បឋមភូមិ(ស្រី) | 82,9% | 84% | 84.30% | ↑ |
| 6 | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ | 66,00% | 73,5% | 72.20% | ↑ |
| | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ(ស្រី) | 66,5% | 73% | 72.20% | ↑ |
| 7 | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 31,50% | 35% | 32.60% | ↑ |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ស្រី) | 34,5% | 36% | 36,10% | ↑ |
| 8 | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 11,2% | 14% | 12.40% | ↓ |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ(ស្រី) | 11,8% | 14% | 13.40% | → |
| 9 | ភាគរយសិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ | 20.0% | 23% | 23.0% | ↑ |
| 10 | ភាគរយសិស្សមធ្យមសិក្សាទុតិយភូមិទទួលអាហារូបករណ៍ | 10.0% | 10% | 10.0% | ↑ |
| 11 | សាលាមធ្យមសិក្សាមានបង្គន់អនាម័យ | | | | |

| | | | | | |
|---|---|---|---|---|---|
| | មធ្យមសិក្សាបឋមភូមិ | 80.0% | 95% | 90.0% | ↑ |
| | មធ្យមសិក្សាទុតិយភូមិ | 100.0% | 100% | 100.0% | ↑ |
| 12 | សាលាមធ្យមសិក្សាមានទឹកស្អាត | | | | |
| | មធ្យមសិក្សាបឋមភូមិ | 40.0% | 75% | 45.0% | ↓ |
| | មធ្យមសិក្សាទុតិយភូមិ | 65.0% | 80% | 70.0% | ↓ |
| **គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់** | | | | | |
| | N/A | | | | |

**គ-បញ្ហាប្រឈម**

- ខ្វះអគារសិក្សានៅ អនុវិទ្យាល័យឈូក អនុវិទ្យាល័យគោកខ្ពស់ និងវិទ្យាល័យបន្ទាយអំពិល
- អនុវិទ្យាល័យរំចេក គ្មានអគារសិក្សា រៀនពោងដោល
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្ភារបង្រៀន និងរៀន គ្រូឯកទេសតាមមុខវិជ្ជាមួយចំនួន ជាពិសេស មុខវិជ្ជា អង់គ្លេស មិនទាន់ឆ្លើយតបតាមតម្រូវការ
- ការបោះបង់ការសិក្សានៅមធ្យមសិក្សានៅមានកម្រិតខ្ពស់(បឋមភូមិ 18.3% និង ១២.៥% ទុតិយភូមិ)
- សាលា ស្ថិតនៅឆ្ងាយពីផ្ទះរបស់សិស្ស (ជាពិសេសវិទ្យាល័យបន្ទាយអំពិល អំពិល និងអនុវិទ្យាល័យ បេង ឈូក គោកខ្ពស់ ) ។
- ខ្វះទីកន្លែងស្នាក់នៅ (អន្តេវាសិកដ្ឋាន សម្រាប់គ្រូ សិស្ស) នៅស្រុកបន្ទាយអំពិល
- ខ្វះអគារសិក្សានៅ អនុវិ. ឈូក,អនុវិ.គោកខ្ពស់ អនុវិ.ប្រាសាទបី ។
- គ្រូបង្រៀនខុសឯកទេស វិទ្យាល័យអំពិល បេង អនុវិទ្យាល័យឈូក និងអនុ.គោកឪឡោក(របាយម៉ោង បង្រៀនមិនស្មើគ្នា)
- សិស្សលើសនិយាម ពិបាកក្នុងការបង្រៀន និងរៀន (គ្មានគុណភាព និងប្រសិទ្ធភាព ,វិ.អំពិល, បន្ទាយអំពិល, អនុវិ.ឈូក ) ។
- មិនបានអនុវត្ត ការប្រជុំក្រុមបច្ចេកទេស
- មិនអនុវត្តការប្រើប្រាស់សៀវភៅពិនិត្យតាមដាន
- ខ្វះសៀវភៅសិក្សាគោល (ថ្នាក់ទី ៩ នៅ អនុវិ.បេង. អនុវិ-ឈូក. អនុវិ-គោកខ្ពស់ វិ.បន្ទាយអំពិល និងថ្នាក់ទី១០-១២
- វិ.អំពិល វិ.បន្ទាយអំពិល( វិទ្យាសាស្ត្រសង្គម ) ភាសាអង់គ្លេស គ្រប់កម្រិត

## ២-២-៤-អនុវិស័យការអប់រំក្រៅប្រព័ន្ធ

### ក-លទ្ធផលសម្រេចបាន

### ក-១-ការធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយ សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា

ថ្នាក់អក្ខរកម្មប្រើប្រាស់ថវិការដ្ឋ (ធៀបឆ្នាំ២០១៤-២០១៥ )

| លរ | ឈ្មោះក្រុង/ស្រុក | ចំនួនថ្នាក់ | ឆ្នាំ២០១៥-២០១៦ | | | | ចំនួនថ្នាក់ | ឆ្នាំ២០១៦-២០១៧ | | | | កើនថយ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រូ | | ចំនួនសិស្ស | | | ចំនួនគ្រូ | | ចំនួនសិស្ស | | | |
| | | | សរុប | ស្រី | សរុប | ស្រី | | សរុប | ស្រី | សរុប | ស្រី | | |
| ១ | សំរោង | ០៤ | ០៤ | ០០ | ១០៥ | ៨៦ | ០៤ | ០៤ | ០០ | ៥៧ | ១៩ | ↓ | |
| ២ | ចុងកាល់ | ០៤ | ០៤ | ០២ | ៧៥ | ៥៣ | ០៣ | ០៣ | ០២ | ៧៣ | ៥៥ | → | |
| ៣ | បន្ទាយអំពិល | ០៧ | ០៧ | ០២ | ១២៦ | ៨៥ | ០៦ | ០៦ | ០១ | ១០៧ | ៦៧ | ↓ | |
| ៤ | អន្លង់វែង | ០៤ | ០៤ | ០០ | ៨៦ | ៦០ | ០៤ | ០៤ | ០៣ | ១០៦ | ៧៥ | ↑ | |
| ៥ | ត្រពាំងប្រាសាទ | ០៦ | ០៦ | ០២ | ១៥០ | ១០១ | ០៦ | ០៦ | ០៣ | ១៥២ | ១០៦ | ↑ | |
| សរុប | | ២៥ | ២៥ | ០៧ | ៥៤២ | ៣៨៥ | ២៣ | ២៣ | ០៩ | ៤៩៥ | ៣២២ | ↓ | |

មជ្ឈមណ្ឌលសិក្សាសហគមន៍បណ្ណាល័យនិង មណ្ឌលអាន

- មជ្ឈមណ្ឌលសិក្សាសហគមន៍សរុបមានចំនួន៤កន្លែងបានដំណើរការ៤កន្លែងគឺស្រុកត្រពាំងប្រាសាទស្រុកបន្ទាយអំពិល និងស្រុកចុងកាល់
- បណ្ណាល័យ ១កន្លែង មិនដំណើរការ
- មានមណ្ឌលអានចំនួន០៩កន្លែងត្រូវបានបិទទ្វារមិនដំណើរការ

| លរ | ឈ្មោះក្រុង-ស្រុក | មសស | មណ្ឌលអាន | បណ្ណាល័យ | ប្រៀបធៀបឆ្នាំ២០១៤-២០១៥(កើន-ថយ) |
|---|---|---|---|---|---|
| ១ | សំរោង | ០ | ០០ | ០ | |
| ២ | ចុងកាល់ | ០១ | ០១ | ០ | -មសសដំណើរការលើជំនាញកាត់ដេរ<br>-មណ្ឌលអានថយចុះ រុះរើគ្មានអ្នកគ្រប់គ្រង |
| ៣ | បន្ទាយអំពិល | ០២ | ០ | ០ | -មសសដំណើរការលើជំនាញកាត់ដេរ<br>-មណ្ឌលអានត្រូវបានបិទទ្វារទាំងស្រុង |
| ៤ | អន្លង់វែង | ០ | ០១ | ០ | -មណ្ឌលអាននៅដដែល(មិនដំណើរការ) |
| ៥ | ត្រពាំងប្រាសាទ | ០១ | ០២ | ០១ | -បណ្ណាល័យ និងមណ្ឌលអានមិនដំណើរការ |
| សរុប | | ០៤ | ០៤ | ០១ | -មសស៤កន្លែងដំណើរ<br>-មណ្ឌលអាននៅសល់(ខូចខាតទាំងស្រុង)<br>-បណ្ណាល័យនៅដដែល(បិទទ្វា) |

**ជំនាញមុខរបរ**

| ឈ្មោះក្រុង/ស្រុក | ឆ្នាំសិក្សា២០១៥-២០១៦ | | | | ឆ្នាំសិក្សា២០១៦-២០១៧ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | ចូលរៀន | | បញ្ចប់ | | ចូលរៀន | | បញ្ចប់ | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| ចុងកាល់ | ១៨ | ១២ | ១២ | ១២ | ៣៣ | ១៦ | ២៣ | ១២ | ↑ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បន្ទាយអំពិល | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ១៣ | ០៨ | ០៥ | ↓ |
| ត្រពាំងប្រាសាទ | ២៥ | ១៦ | ២៥ | ១៦ | ៣៣ | ២០ | ២៧ | ១៧ | ↑ |
| សរុប | ៥៩ | ៤៤ | ៥៣ | ៤៤ | ៨២ | ៤៩ | ៥៨ | ៣៤ | → |

## ការងារបំពេញវិជ្ជាក្រៅម៉ោងធ្វើការ

| ឈ្មោះសាលា | ឆ្នាំសិក្សា២០១៥-២០១៦ | | | | | | | ឆ្នាំសិក្សា២០១៥-២០១៦ | | | | | | | កើនថយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់ | ម.បឋមភូមិ | | ម.ទុតិយភូមិ | | សិស្សសរុប | | ថ្នាក់ | ម.បឋមភូមិ | | ម.ទុតិយភូមិ | | សរុប | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| បំពេញវិជ្ជាខេត្ត | ១ | ១៦ | ២ | ៤៦ | ១៥ | ៦២ | ១៨ | ១ | ២៤ | ៤ | ១០៧ | ២៦ | ១៣១ | ៣០ | ↑ |

## លទ្ធផលប្រឡងសញ្ញាបត្រ

| កម្រិតថ្នាក់ | ឆ្នាំសិក្សា២០១៥-២០១៦ | | | | | ឆ្នាំសិក្សា២០១៦-២០១៧ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | បេក្ខជនមកប្រឡង | | ប្រឡងជាប់ | | ភាគរយ | បេក្ខជនមកប្រឡង | | ប្រឡងជាប់ | | ភាគរយ |
| | សរុប | ស្រី | សរុប | ស្រី | | សរុប | ស្រី | សរុប | ស្រី | |
| បឋមភូមិ | ១២ | ០០ | ០៧ | ០០ | ៥៨.៣៣% | ២៤ | ០៤ | ២២ | ០៤ | ៩១.៦៦% |
| ទុតិយភូមិ | ៤២ | ១៣ | ៣១ | ១៩ | ៦២% | ៩១ | ២២ | ៥៦ | ១៦ | ៦៤.៣៦% |
| ស្វ័យរិនមបភ | 0 | 0 | 0 | 0 | | 0 | 0 | 0 | 0 | |
| ស្វ័យរិនមទភ | ២៩ | ០៨ | ០៦ | 0 | ២០,៦៨% | ១៦ | ០៤ | ១៣ | ០៤ | ៩២.៨៥% |
| សរុបរួម | ៨៣ | ២១ | ៤៤ | ១៩ | ៥៣,០១% | ១៣១ | ៣០ | ៨៩ | ២៤ | ៦៧,៩៣% |

## កម្មវិធីសមមូល

| ឈ្មោះក្រុង/ស្រុក | ឆ្នាំសិក្សា២០១៥-២០១៦ | | | | ឆ្នាំសិក្សា២០១៦-២០១៧ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | ចូលរៀន | | បញ្ចប់ | | ចូលរៀន | | បញ្ចប់ | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| សំរោង | ៥៦ | ២៧ | ៤៦ | ២៥ | ៦០ | ៣២ | ៣៤ | ២៤ | → |
| ចុងកាល់ | ១៣ | ៦ | ១៣ | ៦ | ០៨ | ០៥ | ០៨ | ០៥ | ↓ |
| បន្ទាយអំពិល | ២៧ | ៤ | ២៥ | ៣ | ៣០ | ០០ | ២៧ | ០០ | ↑ |
| អន្លង់វែង | ៣៩ | ១៩ | ២៨ | ១៣ | ៤២ | ១០ | ៣៧ | ១០ | ↑ |
| ត្រពាំងប្រាសាទ | ៤១ | ៣១ | ២៦ | ២០ | ៤៣ | ២៩ | ២៦ | ១៨ | → |
| សរុប | **១៧៦** | **៨៧** | **១៣៨** | **៦៧** | **១៨៣** | **៧៦** | **១៣២** | **៥៧** | → |

## កម្មវិធីចូលរៀនឡើងវិញ

| ឈ្មោះក្រុង/ស្រុក | ឆ្នាំសិក្សា២០១៥-២០១៦ | | | | ឆ្នាំសិក្សា២០១៦-២០១៧ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | ចូលរៀន | | បញ្ជូនចូលរៀល | | ចូលរៀន | | បញ្ជូនចូលរៀល | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| សំរោង | ៧២ | ១៦ | ៤៦ | ១៤ | ៩៩ | ៣១ | ៦៧ | ២៣ | ↑ |
| ចុងកាល់ | ៩១ | ៤៣ | ៩១ | ៤៣ | ៧១ | ៣០ | ៤៤ | ២០ | ↓ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បន្ទាយអំពិល | ១៦៧ | ៧៦ | ១៩៨ | ៦៩ | ១១៩ | ៤៧ | ៩២ | ៣៩ | ↓ |
| អន្លង់វែង | ២៦៦ | ១០៨ | ២៥២ | ១០២ | ៩៨ | ៣៦ | ៩០ | ៣៥ | ↓ |
| ត្រពាំងប្រាសាទ | ០ | ០ | ០ | ០ | ៤៧ | ១២ | ២៩ | ១០ | ↑ |
| សរុប | **៥៩៦** | **២៣៨** | **៥៣៧** | **២២៨** | **៤៣៩** | **១៥៦** | **៣២២** | **១២៧** | ↓ |

**សាលារៀនឯកជន**

| ឈ្មោះក្រុង/ស្រុក | ឈ្មោះសាលាឯកជន | ជំនាញ | ផ្សេងៗ |
|---|---|---|---|
| ក្រុងសំរោង | -វែលឃឹម<br>-ខេមរអង្គរ<br>-អាត់វេនទីស្ទ<br>-ហេឡូអាមេរិចកាំង<br>-ស៊ីអ៊ីអេស<br>-សុខរ៉ាន់ប៊ីយេ<br>-គ្រីនវ៉េ<br>-អន្តរជាតិអូស្មាច់<br>-ខេអាយអឹមអូរស្មាច់ | -ភាសាអង់គ្លេស -មត្តេយ្យ<br>-ភាសាអង់គ្លេស -មត្តេយ្យ<br>-ភាសាអង់គ្លេស -កុំព្យូទ័រ<br>-ភាសាអង់គ្លេស -មត្តេយ្យ<br>-ភាសាអង់គ្លេស -កុំព្យូទ័រ<br>-ភាសាអង់គ្លេស -កុំព្យូទ័រ<br>-ភាសាអង់គ្លេស<br>-ភាសាអង់គ្លេស -មត្តេយ្យ<br>-ភាសាអង់គ្លេស -ថៃ<br>-ភាសាអង់គ្លេស | |
| ស្រុកចុងកាល់ | -ឡៃហ្គោល<br>-អន្តរជាតិកម្ពុជាអាស៊ាន | -ភាសាអង់គ្លេស -កុំព្យូទ័រ<br>-ភាសាអង់គ្លេស -កុំព្យូទ័រ | |
| ស្រុកបន្ទាយអំពិល | -គ្មាន | | |
| ស្រុកអន្លង់វែង | -លាង មានបណ្ឌុះវិជ្ជា<br>-អន្តរជាតិកម្ពុជាអាស៊ាន<br>-ពន្លឺវិជ្ជា | -ចំណេះទូទៅ-ភាសាអង់គ្លេស<br>-ភាសាអង់គ្លេស -កុំព្យូទ័រ<br>-ចំណេះទូទៅ | |
| ស្រុកត្រពាំងប្រាសាទ | -បណ្ដុះវិជ្ជាត្រពាំងប្រាសាទ<br>-អន្តរជាតិសៀមរាបអាមេរិចកាំង<br>-អប់រំបេសសកម្ម ពីម៉ែកម្ពុជា | -ចំណេះទូទៅ<br>- អង់គ្លេស-កុំព្យូទ័រ<br>-ភាសារចិន -កុំព្យូទ័រ | |

## ក-២-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់

## ខ-ការវិភាគអំពីវឌ្ឍនភាពនៃសូចនាករផលសម្រេច

បានផ្តល់សម្ភារដំណើរការកម្មវិធីអប់រំក្រៅប្រព័ន្ធមានដូចជាកម្មវិធីអក្ខរកម្ម កម្មវិធីសមមូល និងកម្មវិធីបង្កើនប្រាក់ចំណូលដើម្បីដំណើរការការរៀននិងបង្រៀនប្រកបដោយគុណភាពនិងប្រសិទ្ធភាព។

- ○ បានដំណើរការកម្មវិធីសមមូលបឋមសិក្សាឆ្នាំទី១ និងទី២ចំនួន១០ថ្នាក់នៅគ្រប់ក្រុង/ស្រុក មានសិស្សចូលរៀន១៨៣នាក់ ស្រី៧៦នាក់។
- ○ បានបើកវគ្គបំប៉នគ្រូអក្ខរកម្មកិច្ចសន្យាស្តីពីវិធីសាស្ត្របង្រៀនមនុស្សពេញវ័យចំនួន៥ថ្ងៃដែលមានគ្រូ ២៤នាក់ ស្រី ០៩ នាក់
- ○ បានដំណើរការកម្មវិធីអក្ខរកម្ម ចំនួន២៣ថ្នាក់ នៅគ្រប់ក្រុង/ស្រុក មានសិស្សចូលរៀន ៤៣៤ នាក់ ស្រី ១៥៦ នាក់។
- បានដំណើរការ កម្មវិធីបង្កើនប្រាក់ចំណូលចំនួន ០៦ ថ្នាក់ នៅ ០៣ស្រុក ( ចុងកាល់ បន្ទាយអំពិលនិងត្រពាំងប្រាសាទ) មានសិស្សចូលរៀន ៨២ នាក់ ស្រី ៤៩នាក់ ។
- ○ បានបើកវគ្គសិក្ខាសាលាស្តីពីគុណភាពគ្រូកម្មវិធីចូលរៀនឡើងវិញឆ្នាំ ២០១៧ចំនួន០៣ថ្ងៃ ដែលមានសិក្ខាកាមសរុប ២៤នាក់ស្រី០៧ នាក់ មកពីគ្រប់ក្រុង/ស្រុក
- ○ បានដំណើរការកម្មវិធីចូលរៀនឡើងវិញចំនួន២៤ថ្នាក់នៅគ្រប់ក្រុង/ស្រុកដែលមានសិស្សសរុប៤៣៤នាក់ ស្រី១៥៦នាក់
- ○ បានបើកវគ្គសិក្ខាសាលាការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធថ្នាក់ក្រុង/ស្រុកនិងឃុំ/សង្កាត់ចំនួន ០២ថ្ងៃ ដែលមាន សិក្ខាកាមចូលរួម ៥៨នាក់
- ○ បានចុះត្រួតពិនិត្យតាមដានគ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធនៅតាមក្រុង/ស្រុកចំនួន០២ដង ក្នុង ១ក្រុង/ស្រុក

**ការវិភាគសូចនាករផលសម្រេច**

| IV | ការអប់រំក្រៅប្រព័ន្ធ | ជាក់ស្តែង 2015-16 | ចំណុចដៅ 2016-17 | ជាក់ស្តែង 2016-17 | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី ១៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា** | | | | | |
| 1 | ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | 311 | 450 | 371 | ↓ |
| 2 | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | 176 | 190 | 183 | → |
| 3 | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ | 4 | 5 | 4 | → |
| 4 | ភាគរយកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញនិងបានបញ្ជូនទៅក្នុងប្រព័ន្ធ | 90 | 95 | 89 | ↓ |
| 5 | ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ | 52 | 70 | 58 | → |
| **គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់** | | | | | |
| 6 | ក្រុង/ស្រុករៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | 0 | 0 | 0 | → |

សម្គាល់: ↑សម្រេចបានតាមចំណុចដៅ →អាចទទួលយកបាន ↓ សម្រេចមិនបានតាមគោលដៅ

**គ-បញ្ហាប្រឈម**

- ប្រជាជនមិនទាន់យល់ និងស្គាល់កម្មវិធីអប់រំក្រៅប្រព័ន្ធបានច្បាស់
- ពិបាកប្រមូលសិស្សចូលរៀន(នៅរាយប៉ាយមិនគ្រប់និយាមថ្នាក់)
- អាជ្ញាធរដែនដីមួយចំនួនមិនជួយជម្រុញ និងមិនយកចិត្តទុកដាក់លើការងារអប់រំក្រៅប្រព័ន្ធ
- ថវិកាដំណើរការកម្មវិធីចូលរៀនឡើងវិញមានភាពយឺតយ៉ាវ (គ្មានថវិកាក្នុងបេឡាមន្ទីរ)

- សិស្សបោះបង់ការសិក្សាច្រើន(រវល់ដោះស្រាយជីវភាព)
- របាយការណ៍របស់គ្រូ ការិយាល័យអប់រំក្រុង/ស្រុកមានភាពយឺតយ៉ាវ

## ២-២-៥- អនុវិស័យ ការអភិវឌ្ឍយុវជន

**ក-លទ្ធផលសម្រេចបាន**

**ក-១-ការធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយ សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា**

➢ **ការងារយុវជន និងសុខភាពសិក្សា៖**

**ការរៀបចំក្រុមប្រឹក្សាកុមារ និងយុវជន៖**

- គ្រូបង្គោលថ្នាក់ស្រុក សាលារៀន ១៨៦ នាក់ បានលើកកម្ពស់សមត្ថភាព ស្តីពីការងារក្រុមប្រឹក្សាយុវជន -កុមារ និងសកម្មភាពក្លឹបសិក្សាមុខវិជ្ជា ។
- ក្រុមប្រឹក្សាកុមារ សរុបមានចំនួន ២៣៩ មាន ៨៥៥ សាខា ៥,១៣០ អនុសាខា មានសមាជិក២៣,៨៨១ នាក់ ក្នុងនោះ ស្រី ១២,០០៥ នាក់ សមាជិកដែលមានសកម្មភាពល្អចំនួន ១៩,៩៨៦ នាក់ ក្នុងនោះស្រី១០,៥៥៨ នាក់ ស្មើនឹង ៨៤ % និងក្រុមប្រឹក្សាយុវជន សរុបមានចំនួន០៧ មាន៦៨ សាខា ៤០៨ អនុសាខា សមាជិកសរុបចំនួន ៣,០៣៥ នាក់ ស្រី ១,៥២៨ នាក់ មានសកម្មភាពល្អ ចំនួន ២,៨៣៣ នាក់ ក្នុងនោះស្រី ១,៤២០ នាក់ ស្មើនឹង ៩៣% ។
- ចុះពិនិត្យតាមដានកែលម្អការងារក្រុមប្រឹក្សាយុវជន-កុមារ នៅតាមសាលារៀនចំនួន ១២ លើក ស្មើនឹង៣៦សាលា
- ចុះពិនិត្យតាមដាន និងប្រជុំណែនាំដល់យុវជនស្ម័គ្រចិត្ត ចំនួន ៣ ស្រុក(ស្រុកបន្ទាយអំពិល ស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ) មានយុវជនសរុប ៨៧នាក់ ស្រី ២៣នាក់
- ដឹកនាំក្រុមប្រឹក្សាយុវជន និងកុមារ ចូលរួមទស្សនកិច្ចសិក្សា ចំនួន ០២ ដងលើប្រធានបទ" ការថែរក្សាសម្បត្តិវប្បធម៌បេតិកភ័ណ្ឌជាតិ " នៅ ខេត្តសៀមរាប មានចំនួនសរុប ១២ នាក់ ស្រី ០៦ នាក់ ។
- ដឹកនាំនាយក នាយករងទទួលបន្ទុកក្រុមប្រឹក្សាកុមារ(ក្រុងសំរោង និងស្រុកចុងកាល់ ) ចូលរួមទស្សនកិច្ចសិក្សានៅសាលាបឋមសិក្សាវត្តបូព៌សរុប ២៥ នាក់ ស្រី ០១ នាក់ ។
- រៀបចំបោះជំរំយុវជន ថ្នាក់ខេត្តលើក២ ក្រោមប្រធានបទ " យុវជន និងសហគមន៍ " អ្នកចូលរួមមានចំនួន១៦៦ នាក់ ស្រី ៦៣ នាក់នៅពហុកីឡដ្ឋានខេត្តចំនួន ០៣ថ្ងៃ
- ចូលរួមបោះជំរំយុវជន ថ្នាក់ជាតិ លើកទី ១៩ ក្រោមប្រធានបទ " យុវជន ដើម្បីសន្តិភាព និងវឌ្ឍនភាព " បានចូលរួមចំនួន ១៣ នាក់ ស្រី ០៣ នាក់ នៅខេត្តកំពង់ធំ ។
- បានផ្ញើប័ណ្ណសរសើរ ដល់ក្រុមប្រឹក្សាយុវជន កុមារ ដែលរៀននៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន ២៥០នាក់
- ប្រតិភូ និងសិស្ស ១នាក់ បានចូលរួមប្រជុំផ្លាស់ប្តូរបទពិសោធ យុវជនអាស៊ីប៉ូព៌ា ចំនួន ១២ ប្រទេស នៅប្រទេសជប៉ុន រយៈពេល ០៩ថ្ងៃ ។
- ថ្នាក់ដឹកនាំយុវជន០២រូប ចូលរួមវគ្គ សហគ្រិនភាព រយៈពេល ០៣ថ្ងៃ នៅខេត្តសៀមរាប
- បើកវគ្គបណ្តុះបណ្តាល ស្តីពី "ប្រឹក្សាអាជីព និងតម្រង់ទិសការសិក្សា " ដល់សិស្សានុសិស្ស ចំនួន ៥០០នាក់ នៅ
- វិទ្យាល័យហ៊ុន សែន ឧត្តរមានជ័យ និងអនុវិទ្យាល័យសំរោង ។
- បើកវគ្គផ្សព្វផ្សាយអប់រំ ពីគ្រោះថ្នាក់ នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមគ្រឹះស្ថានសិក្សា ដែលមានប្រធាន និងមន្ត្រីការិ.អយកក្រុង ស្រុក នាយក នាយករង និងសិស្សានុសិស្សតាមវិទ្យាល័យចំនួន ១៧៥នាក់
- សាលាបឋមសិក្សា និងអនុវិទ្យាល័យមានចំនួន ២៣៩ គណៈកម្មាធិការប្រតិបត្តិ ( កើន ជាងឆ្នាំមុន ០៥ គណៈកម្មាធិការប្រតិបត្តិដោយដកចេញ សាលាបឋមសិក្សាដែលមានមិន គ្រប់កម្រិត ថ្នាក់) ។ វិទ្យាល័យចំនួន ០៧ គណៈកម្មាធិការប្រតិបត្តិ មានចំនួនកើនជាង ឆ្នាំចាស់ ០១អង្គភាព ។

- ក្រុមប្រឹក្សាកុមារ-យុវជន នៅតាមសាលារៀនបានរៀបចំបោះឆ្នោតជ្រើសរើស គណៈកម្មាធិការប្រតិបត្តិ **១០០%**។
- នៅតាមសាលានីមួយៗបានរៀបចំតារាងបង្ហាញពីនិមិត្តសញ្ញា រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា ពីតួនាទីភារកិច្ចរបស់សាខា អនុសាខា ខ្លឹមសារ នៃការអនុវត្តចលនាប្រឡងប្រណាំង៣ល្អ និងប្រតិទិនការងារប្រចាំឆ្នាំ ។ មានតាំងរូបអប់រំមួយចំនួនដូចជា ៖ របៀបសំពះរបស់ខ្មែរ កម្រងសិទ្ធិទាំងបួនរបស់កុមារ ពាក្យស្លោក និងសុភាសិតអប់រំ ពីចលនា ៣ល្អ ពិសេស គឺផែនការសកម្មភាព ។

➢ **ការអប់រំផ្សព្វផ្សាយ:**

ខ្លឹមសារដែលបានលើកយកមកផ្សព្វផ្សាយមាន:

- សេចក្តីណែនាំលេខ **៤០៦** អយក.សណន ស្តីពីការលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តចលនាប្រឡងប្រណាំងរបស់កុមារ និងយុវជន ( កូនល្អ សិស្សល្អ មិត្តល្អ ) ។
- អត្ថន័យ **០១ មិថុនា** ទិវាកុមារអន្តរជាតិ និង **១២ សីហា** ទិវាយុវជនអន្តរជាតិ ។
- រៀបចំទិវា ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ នៅគ្រប់សាលារៀនបឋម និងមធ្យម ទូទាំងខេត្ត
- ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ កាមរោគ និងសុខភាពបន្តពូជ ។
- ជំពូកទី២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងជំពូកទី៣ ស្តីពីបញ្ញាទូទៅ នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារខ្លឹមសារខាងលើនេះ មានការចូលរួមពីសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ តាមរយៈកម្មវិធីបញ្ជ្រាបបំណិនជីវិត ការប្រជុំផ្សព្វផ្សាយពេលគោរពទង់ជាតិ និងតាមរយៈ គ្រូបង្គោល ដែលបានបណ្តុះបណ្តាលកន្លងមក ។

➢ **ការអនុវត្តចលនា ៣ល្អ:**

- បានរៀបចំចងក្រងឯកសារជំនួយស្មារតី ស្តីពីខ្លឹមសារលម្អិត នៃចលនា ៣ ល្អ តារាងវាយតម្លៃ ផ្តល់ពិន្ទុដល់អង្គភាព និងបុគ្គលដែលមានស្នាដៃ ។
- គ្រប់គណៈកម្មាធិការប្រតិបត្តិបានបន្តផ្សព្វផ្សាយ និងបំផុសចលនានេះ នៅតាមសាខា និងអនុសាខា
- ការប្រជុំវាយតម្លៃ ត្រូវបានអនុវត្តចាប់ពីថ្នាក់អនុសាខា ដល់ថ្នាក់គណៈកម្មាធិការប្រតិបត្តិ ដោយបានការឯកភាពពីលោកនាយកសាលា ឬ លោកនាយករងទទួលបន្ទុកការងារយុជន ដែលជាប្រធានក្រុមប្រឹក្សាភិបាល រួចរាយការណ៍មកការិយាល័យយុវជន និងកីឡា ដើម្បីធ្វើការបូកសរុប តាមរយៈការិយាល័យ អប់រំ យុវជន និងកីឡាក្រុង/ស្រុក។
- អង្គភាពចូលរួមអនុវត្តចលនា ៣ល្អ មានដូចខាងក្រោម ៖

  ១. អង្គភាពសរុបចំនួន **២៤៦** ក្នុងនោះមាន ៖
  - ក្រុមប្រឹក្សាកុមារចំនួន **២៣៩** អង្គភាព
  - សាខាចំនួន **៨៥៥** សាខា
  - អនុសាខាចំនួន **៥,១៣០** អនុសាខា
  - ក្រុមប្រឹក្សាយុវជន ចំនួន **០៧** អង្គភាព
  - សាខាចំនួន **៦៨** សាខា
  - អនុសាខាចំនួន **៤០៨** អនុសាខា

  ២. សមាជិកក្រុមប្រឹក្សាកុមារ ដែលទទួលបានស្នាដៃសរុបចំនួន **១៩,៩៨៦** នាក់ ក្នុងនោះស្រី **១០,៥៥៨** នាក់ លើចំនួនសិស្ស **២៣,៨៨១** នាក់ ក្នុងនោះស្រី **១២,០០៥** នាក់
  - សមាជិកទទួលស្នាដៃ ១ល្អ ចំនួន **១០,៤៤២** នាក់ ស្រី **៥,៧៤២**នាក់
  - សមាជិកទទួលស្នាដៃ ២ល្អ ចំនួន **៩,១៩៤** នាក់ ស្រី **៤,៣៣២** នាក់
  - សមាជិកទទួលស្នាដៃ ៣ល្អ ចំនួន **១,៦៦៦** នាក់ ស្រី **១,៥២៨** នាក់

  ៣. សមាជិកក្រុមប្រឹក្សាយុវជន ដែលទទួលបានស្នាដៃសរុបចំនួន **២,៨៣៣** នាក់ ក្នុងនោះស្រី **១,៤២០** នាក់ លើ

ចំនួនសិស្ស **៣,០៣៥** នាក់ ក្នុងនោះស្រី **១,៥២៨** នាក់

- សមាជិកទទួលស្នាដៃ ១ល្អ ចំនួន ១,០៩២ នាក់ ស្រី ៥៧៧ នាក់
- សមាជិកទទួលស្នាដៃ ២ល្អ ចំនួន ៧៩៩ នាក់ ស្រី ៥៧៩ នាក់
- សមាជិកទទួលស្នាដៃ ៣ល្អ ចំនួន **៣៩៤** នាក់ ស្រី **១៩០** នាក់

## ក-២-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់

➢ **សកម្មភាពកុមារ និង យុវជន:**

**សកម្មភាពក្រុមប្រឹក្សាកុមារ និងយុវជន**

- សមាជិកក្រុមយុវជនក្រៅសាលា ចំនួន **១២** នាក់ ស្រី **០៦** នាក់ ចូលរួមធ្វើទស្សនកិច្ចសិក្សា ពីសម្បត្តិវប្បធម៌ជាតិនិងចូលរួមធ្វើការងារស្ម័គ្រចិត្តក្នុងសហគមន៍តាមរយៈកម្មវិធីរបស់នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន ចំនួន ០២ លើក នៅខេត្តរតនគិរី និងខេត្តសៀមរាប
- ប្រជុំបូកសរុបការងារក្រុមប្រឹក្សាកុមារ និងយុវជន នៅក្រុងសំរោង និងស្រុកបន្ទាយអំពិល
- ក្រុមប្រឹក្សាយុវជនវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ និងវិទ្យាល័យ អន្លង់វែង បានប្រារព្ធពិធីរំលឹកគុណគ្រូ
- ក្រុមប្រឹក្សាយុវជន និងយុវជនស្ម័គ្រចិត្ត ដែលបានចូលរួមបោះជំរំយុវជន ថ្នាក់ខេត្ត លើកទី២ បានចូលរួមសម្អាតទីធ្លាសាធារណៈ និងវត្តប្រាសាទរាជាសំរោង
- ក្រុមប្រឹក្សាយុវជន កុមារ តាមសាលារៀន បានចូលរួម ពិធីបុណ្យជាតិផ្សេងៗ កម្មវិធីសង្គម និងសម្អាតបរិស្ថានសាលារៀន
- ក្រុមប្រឹក្សាយុវជន កុមារចំនួន ៤៧នាក់ស្រី១៥នាក់ នៅក្រុងសំរោង បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីមូលដ្ឋានគ្រឹះនៃការប្រើប្រាស់ឧបករណ៍តន្ត្រីព្យាណូ ។

➢ **សកម្មភាពកាយរឹទ្ធិជាតិកម្ពុជា**

សមាជិកកាយរឹទ្ធិដែលនៅសល់បច្ចុប្បន្ន ៖

- សមាជិកកិត្តិយស **០៣** នាក់ ស្រី **០១** នាក់
- មេដឹកនាំកាយរឹទ្ធិ **៣២៥** នាក់ ស្រី **៦៥** នាក់
- កាយរឹទ្ធិ **១,៧៣៤** នាក់ ស្រី **៩៥៣** នាក់
- កាយរឹទ្ធិប្អូន **៨៥០** នាក់ ស្រី **៤៥៤** នាក់
- សរុបរួមចំនួន **២,៩១២** នាក់ ស្រី **១,៤៧៣** នាក់
- សមាជិកកាយរឹទ្ធិចំនួន **៣០០**នាក់ ចូលរួមសម្អាតតាមសួនច្បារ មាត់បឹងស្មោរ នៅក្នុងក្រុងសំរោង
- បំពាក់កន្សែងដល់នវដឹកនាំកាយរឹទ្ធិជាតិកម្ពុជា ថ្នាក់ក្រុង/ស្រុកចំនួន **១៩**នាក់ ស្រី **៥**នាក់
- ដឹកនាំយុវជនកាយរឹទ្ធិ ៥០ នាក់ចូលរួមទិវាជាតិ ស្តីពីការជួញដូរមនុស្ស
- ដឹកនាំក្រុមកាយរឹទ្ធិ និងកាយរឹទ្ធិប្អូន ចំនួន១៥០ នាក់ ស្រី ៥០នាក់ ចូលរួមទិវាពលកម្ម អន្តរជាតិ
- ដឹកនាំកាយរឹទ្ធិ ចំនួន ៨០នាក់ ចូលរួមទិវាឯករាជ្យជាតិ លើកទី ៦៤
- ដឹកនាំយុវជនកាយរឹទ្ធិ ៥០ នាក់ ចូលរួមពិធីបំពាក់កន្សែងដល់នវដឹកនាំកាយរឹទ្ធិជាតិកម្ពុជា
- ថ្នាក់ដឹកនាំកាយរឹទ្ធិ ចំនួន១៦ នាក់ ស្រី ០នាក់ បានចូលរួមមហាសន្និបាតវិសាមញ្ញកាយរឹទ្ធិជាតិកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នៅរាជធានីភ្នំពេញ ។
- ចូលរួមសម្អាតទីធ្លាសាធារណៈ និងវត្តអារាម ពេលមានពិធីបុណ្យប្រពៃណីជាតិនានា
- ពង្រឹងក្រុមល្បាតឱ្យធ្វើសកម្មភាព ដែលជាអំពើល្អក្នុងឯកសណ្ឋានកាយរឹទ្ធិ

- សមាជិកកាយរឹទ្ធិចំនួន ០២ នាក់ ស្រី ០០ នាក់ បានទទួលអាហារូបករណ៍ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ។

➢ **ចលនាយុវជនកាកបាទក្រហម**

នៅតាមវិទ្យាល័យ អនុវិទ្យាល័យ និងបឋមសិក្សាមាន ៖

- ទីប្រឹក្សាចំនួន ២៦ នាក់ ស្រី ០៤ នាក់
- យុវជនកាកបាទក្រហមចំនួន **៤១៦** នាក់ ស្រី **២៨៣** នាក់

- មន្ត្រីទំនាក់ទំនងកាកបាទក្រហមនៅមន្ទីរអយកខ ចំនួន **០២** នាក់ និងទីប្រឹក្សាចំនួន **២៦** នាក់ បានចូលរួមវគ្គបំប៉នស្តីពីការប្រើប្រាស់ និងវិធីសាស្ត្រសង្គ្រោះបឋម នៅសាខាកាកបាទក្រហមខេត្ត

- យុវជនកាកបាទក្រហមទាំងអស់ តាមសាលាគោលដៅបាន ទទួលការបណ្តុះបណ្តាលពីរបៀបសង្គ្រោះបឋម គ្រោះថ្នាក់ពីមីន និងគ្រាប់មិនទាន់ផ្ទុះគ្រឿងញៀន សុខភាពបន្តពូជ មេរោគអេដស៍/ជំងឺអេដស៍ ច្បាប់ចរាចរណ៍ ដើម្បីឱ្យគេយកចំណេះដឹង ទាំងនេះទៅផ្សព្វផ្សាយ និងអប់រំបន្តដល់មិត្តភក្តិនិងសហគមន៍របស់គេផ្ទាល់ ។

- សមាជិកកាកបាទចំនួន ០២ នាក់ ស្រី ០១ នាក់ បានទទួលអាហារូបករណ៍ បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ។

➢ **ការងារអនុវត្តបាន:**

- សាលាបឋមសិក្សានិងអនុវិទ្យាល័យបានរៀបចំក្រុមប្រឹក្សាកុមារ ចំនួន **២៣៩** សាលា លើ **២៣៩** សាលា ស្មើ **១00%**
- វិទ្យាល័យបានរៀបចំក្រុមប្រឹក្សាយុវជន **១00%** ( **៧សាលា លើ៧សាលា** )
- រៀបចំបំពាក់កន្សែងដល់នដឹកនាំកាយរឹទ្ធិ បាន **១៩នាក់** ស្រី **៥** នាក់
- រៀបចំប័ណ្ណសរសើរដល់ក្រុមប្រឹក្សាកុមារ យុវជន នៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន **២៥០**នាក់
- ប្រជុំបូកសរុបការងារយុវជន កុមារ នៅក្រុងសំរោង និងស្រុកបន្ទាយអំពិល

➢ **ការងារមិនបានអនុវត្ត:**

- ការប្រជុំបូកសរុបចលនា ៣ល្អ ថ្នាក់ខេត្ត ថ្នាក់ក្រុង/ស្រុក និងថ្នាក់សាលារៀន
- ការរៀបចំក្លឹបសិក្សារបស់ក្រុមប្រឹក្សាយុវជន និងកុមារតាមសាលារៀន
- ការរៀបចំវគ្គបំប៉នដល់សមាជិកក្រុមប្រឹក្សាកុមារ និងយុវជនតាមសាលារៀន
- ចេញលិខិតសរសើរដល់អង្គភាពដែលមានស្នាដៃល្អ

**ក-៣- ការងារមជ្ឈមណ្ឌលយុវជន:**

➢ **ការងារអនុវត្តបាន:**

- បានប្រជុំជាមួយថ្នាក់ដឹកនាំខេត្ត ដើម្បីស្នើសុំដីសាងសង់មជ្ឈមណ្ឌលយុវជន
- បានបញ្ជូនយុវជនក្រៅសាលាទៅចូលរួមទស្សនកិច្ចសិក្សានៅខេត្តសៀមរាប និងរតនគីរី
- បានបើកវគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះ នៃការប្រើប្រាស់ឧបករណ៍តន្ត្រីព្យាណូ

➢ **ការងារមិនបានអនុវត្ត:**

- ការស្នើសុំដីដើម្បីសាងសង់មជ្ឈមណ្ឌលពុំទាន់បានលទ្ធផល

**ខ. ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំ សម្រាប់ធ្វើវិមជ្ឈការ**

- ចូលរួមសិក្ខាសាលាស្តីពី " ការតម្រង់ទិសអំពីការរៀបចំបង្កើតក្រុមប្រឹក្សាជាតិ ដើម្បីអភិវឌ្ឍយុវជន ក្រសួង ស្ថាប័ន និងរាជធានីខេត្ត នៅរាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាពិនិត្យឡើងវិញនូវផែនការ និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០១៨ - ២០២០ នៅរាជធានភ្នំពេញ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី " តួនាទីយុវជន នៅកន្លែងធ្វើការ " រយៈពេល០៣ថ្ងៃ នៅខេត្តបាត់ដំបង

## គ-ការវិភាគអំពីវឌ្ឍនភាពនៃសូចនាករផលសម្រេច

- **ការវិភាគសូចនាករផលសម្រេច**

| VI | ការអភិវឌ្ឍយុវជន | ជាក់ស្តែង 2016-2017 | ចំណុចដៅ 2017-2018 | ជាក់ស្តែង 2017-2018 | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា | | | | | |
| 1 | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | | N/A | | N/A |
| 2 | ចំនួនយុវជនដែលទទួលការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត | 47 | 77 | | ↑ |
| 3 | ចំនួនមជ្ឈមណ្ឌលយុវជន | 1 | 1 | | → |
| 4 | ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯង ក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ | 10 | 47 | | ↑ |
| 5 | ភាគរយសិស្សថ្នាក់ទី៤-៩ ចូលរួមក្នុងក្រុមប្រឹក្សាកុមារ | 100% | 100% | | → |
| 6 | ភាគរយសិស្សថ្នាក់ទី១០-១២ ចូលរួមក្នុងក្រុមប្រឹក្សាយុវជន | 100% | 100% | | → |
| 7 | ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ | 300 | 466 | | ↑ |

## ឃ-បញ្ហាប្រឈម

- គ្មានកញ្ចប់ថវិកាសម្រាប់ប្រជុំបូកសរុបពាល្អ
- ខ្វះការគាំទ្រពីគ្រូទទួលបន្ទុកថ្នាក់ ដែលជាអ្នកអនុវត្តផ្ទាល់
- ខ្វះមន្ត្រីជំនាញសម្រាប់អនុវត្តសកម្មភាព ( ថ្នាក់ខេត្ត ថ្នាក់ក្រុង/ស្រុក និងសាលារៀន )
- សមត្ថភាពគណៈកម្មាធិការប្រតិបត្តិនៅមានកម្រិត ( ពុំធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាល )
- ពុំទទួលបានគ្រឿងឥស្សរិយយសកាយរឹទ្ធិ ដើម្បីបំពាក់ដល់នវកាយរឹទ្ធិ តាមគ្រឹះស្ថានសិក្សា
- ការស្នើសុំដីសម្រាប់សាងសង់មជ្ឈមណ្ឌលពុំទាន់បានសម្រេច
- ខ្វះខាតសម្ភារបច្ចេកទេស សម្រាប់ប្រើប្រាស់ក្នុងមជ្ឈមណ្ឌលបណ្តោះអាសន្ន

## ២-២-៦-អនុវិស័យ ការអប់រំកាយ និងកីឡា

### ក-លទ្ធផលសម្រេចបាន

### ក-១-ការធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយ សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា

➢ **ការងារអប់រំកាយ និងកីឡា**

- នៅគ្រប់គ្រឹះស្ថានបឋមសិក្សា បានទទួលសៀវភៅសិក្សាគោលពីថ្នាក់ទី ១ ដល់ទី ៦

នៅគ្រប់គ្រឹះស្ថានបឋមសិក្សា ទាំងអស់ទូទាំងខេត្ត បានបញ្ចូលកម្មវិធីអប់រំកាយ ក្នុងកាលវិភាគរួមរបស់ខ្លួន ( **មួយសប្ដាហ៍ ពីរម៉ោង** ) ដើម្បីឱ្យសិស្សហ្វឹកហាត់ជាប្រចាំ ក្នុងគោលបំណងធ្វើឱ្យរាងកាយរបស់សិស្សមានភាពមាំមួន និងរឹងប៉ឹងល្អប្រសើរ ព្រមទាំងមានចំណងមិត្តភាព និងសាមគ្គីភាព ។

- នៅគ្រប់គ្រឹះស្ថានមធ្យមសិក្សាទាំងអស់ទូទាំងខេត្ត បានបញ្ចូលកម្មវិធីអប់រំកាយកីឡា ក្នុងកាលវិភាគរួមរបស់ខ្លួន ( **មួយសប្ដាហ៍ ពីរម៉ោង** ) ដើម្បីឱ្យសិស្សហ្វឹកហាត់ជាប្រចាំ ដែលមានវិញ្ញាសាជាច្រើនដូចជាៈ បាល់ទាត់ បាល់ទះ បាល់បោះ និងកីឡាអត្តពលកម្មមួយចំនួន ដើម្បីសុខភាពរាងកាយ និងដើម្បីចូលរួមប្រកួតថ្នាក់ខេត្ត និងទូទាំងប្រទេស

  - បើកវគ្គបំប៉នសមត្ថភាព គ្រូអប់រំកាយ និងកីឡា នៅតាមគ្រឹះស្ថានសិក្សា ចំនួន **៦៤**នាក់ ស្រី **០៣**នាក់
  - បើកវគ្គបំប៉ន ការប្រើប្រាស់សៀវភៅសិក្សាគោលពីថ្នាក់ទី១ ដល់ទី ៦ ចំនួន **៤៥**នាក់ ស្រី **០៩**នាក់
  - យុវជនស្ម័គ្រចិត្តមកពីប្រទេស (អង់គ្លេស អាឡឺម៉ង់ អូស្ត្រាលី និងអេស្ប៉ាញ ) បានមកជួយបង្ហាត់ក្រុមកីឡាបាល់ទាត់ តាមរយៈអង្គការវិថីបៃតងកម្ពុជា តាមរយៈអ្នកស្ម័គ្រចិត្តជប៉ុន ( af SPLE ) បានចុះមករៀបចំទិវាអប់រំកាយ និងកីឡាតាមគ្រឹះស្ថានសិក្សាក្នុងស្រុកចុងកាល់ និងក្រុងសំរោង ហើយនឹងបន្តទៅស្រុកដទៃៗទៀត

➢ **ការចូលរួម និងរៀបចំប្រកួតផ្សេងៗ**

- ចូលរួមប្រកួតកីឡាបាល់ទាត់ពានរង្វាន់សម្ដេច លើកទី **១១** ថ្នាក់តំបន់ ដោយ ខេត្តឧត្តរមានជ័យ ស្ថិតនៅតំបន់កណ្ដាល មានខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ដែលមានកីឡាករចូលរួមចំនួនសរុបចំនួន **៣០** នាក់ ដោយខេត្តឧត្តរមានជ័យឡើងដល់ជុំទី ៤ វគ្គ ១/៨ ។
- រៀបចំការប្រកួតកីឡាសិស្សបឋម-មធ្យមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្ត ដែលមានកីឡាករ-កីឡាការិនី ចូលរួមសរុបចំនួន **៧០២** នាក់ ស្រី **៣៤២** នាក់ ។
- រៀបចំការប្រកួតកីឡាមហាជនថ្នាក់ខេត្ត ដែលមានកីឡាករចូលរួមចំនួន **៣២៤** នាក់ ស្រី **១២៦** នាក់

- ចូលរួមប្រកួតកីឡាសិស្សមធ្យមសិក្សា ជ្រើសរើសជើងឯកថ្នាក់ជាតិ នៅខេត្តកំពង់ចាម ដែលមានកីឡាករ -ការិនី ចូលរួម សរុបចំនួន **៩៥** នាក់ ស្រី **៤០** នាក់ ( ទទួលបានមេដាយមាស **៣** ប្រាក់ **៣** ចំណាត់ថ្នាក់លេខ **២**ទូទាំងប្រទេស )
- ចូលរួមប្រកួតកីឡាសិស្សបឋមសិក្សា ជ្រើសរើសជើងឯកថ្នាក់ជាតិ នៅរាជធានីភ្នំពេញ ដែលមានកីឡាករ -ការិនី ចូលរួមសរុបចំនួន **៤២** នាក់ ស្រី **២១** នាក់ (ឡើងដល់វគ្គ ៤ក្រុមចុងក្រោយទាំងអស់ )។
- រៀបចំការប្រកួតកីឡាដើម្បីទាំងអស់គ្នា ជ្រើសរើសជើងឯកថ្នាក់ខេត្ត ដែលមានកីឡាករ-កីឡាការិនី ចូលរួមសរុបចំនួន **៤៤៧** នាក់ ស្រី **២៤** នាក់ ។

  - ចូលរួមប្រកួតកីឡាទាញព្រ័ត្រ ពានរង្វាន់ភូមិភាគ លើកទី ១ ឆ្នាំ២០១៧ នៅខេត្តក្រចេះ ដែលមានកីឡាករចូលរួមសរុប ១០ នាក់
  - រៀបចំប្រកួតទូក" ង " ជ្រើសរើសជើងឯកថ្នាក់ខេត្តដែលមានទូកសរុប ១៦កីឡាករចូលរួមសរុបចំនួន **៤៣២នាក់**
  - បានចូលរួមប្រកួតមិត្តភាពកម្ពុជា ថៃ ក្នុងកម្មវិធីយុវជន និងគ្រឿងញៀន ដែលមានកីឡាករចូលរួមចំនួន **៥៦នាក់** ស្រី **១៣ នាក់** ( ទទួលបានចំណាត់ថ្នាក់លេខ ១ ផ្នែកប៉េតង់បុរស និងនារី )

## ក-២-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់

➢ **ការងារសុខភាពសិក្សា**

➢ **ការអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុក**

មន្ទីរអប់រំ យុវជន និងកីឡាបានណែនាំឱ្យក្រុង/ស្រុកទាំង ៥ ព្រមទាំងគ្រឹះស្ថានសិក្សាទាំងអស់រៀបចំគណៈកម្មការទទួលបន្ទុកការងារសុខភាពសិក្សាប្រចាំអង្គភាពរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងការងារសុខភាពសិក្សា និងមានការទទួលខុសត្រូវខ្ពស់ ចំពោះការងារដែលថ្នាក់លើប្រគល់ជូន ៖

- គ្រឹះស្ថានសិក្សាទាំងអស់ បានទទួលថ្នាំទម្លាក់ព្រូនមួយឆ្នាំ **០២ ដង** គឺក្នុងកំឡុងខែ **វិច្ឆិកា និងខែឧសភា**
- គ្រឹះស្ថានសិក្សាចំនួន២៤៦ បានទទួលហិបសង្គ្រោះបឋមពីនាយកដ្ឋានសុខភាពសិក្សា ១០០%
- គ្រឹះស្ថានសិក្សាមានកន្លែងលាងដៃចំនួន **៧៧** កន្លែងទូទាំងខេត្ត
- គ្រឹះស្ថានសិក្សាដែលទទួលកម្មវិធីអាហារពេលព្រឹកចំនួន **១៦២** សាលា
- គ្រឹះស្ថានសិក្សាដែលបានចូលរួមវគ្គសង្គ្រោះបឋមចំនួន **១៨៤** សាលា ស្មើ **៧៥ %**
- ចុះពិនិត្យតាមដានស្តីពីការអប់រំបង្ការជំងឺគ្រុនចាញ់ នៅតាមសាលាបឋម-មធ្យមសិក្សា នៅស្រុកអន្លង់វែង និងត្រពាំងប្រាសាទ (**០៣ ថ្ងៃ**)

➢ **ការផ្សព្វផ្សាយលិខិតរបស់ក្រសួង**

- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានផ្សព្វផ្សាយលិខិតលេខ **៤១៦៧** អយក.សស ស្តីពីការផ្លាស់ប្តូរកាលបរិច្ឆេទនៃការផ្តល់ថ្នាំទម្លាក់ដង្កូវព្រូនដល់បុគ្គលិកអប់រំ និងអ្នកសិក្សា គ្រប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគ្រឹះស្ថានសិក្សាទាំងអស់ ដើម្បីអាចមានលទ្ធភាពទទួលបានថ្នាំទម្លាក់ដង្កូវព្រូនគ្រប់ៗគ្នា ។

- ផ្សព្វផ្សាយសេចក្តីណែនាំ លេខ **៣១** អយក.សណន ស្តីពី " ការអនុវត្តវិធានការការពារ និងថែទាំសុខភាពភ្នែក នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន "

- ផ្សព្វផ្សាយសេចក្តីណែនាំ លេខ **១៨** អយក.សណន ស្តីពី " ការលើកកម្ពស់សុវត្ថិភាព ចំណីអាហារ និងអាហារប្រកបដោយសុខភាព នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទូទាំងខេត្ត "

- ផ្សព្វផ្សាយសេចក្តីណែនាំ លេខ **៣៣** អយក.សណន ស្តីពី " ការបន្តការអនុវត្តកម្មវិធីសិក្សាពីប្រធានបទអប់រំសុខភាព នៅតាមគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ "

- ចុះពិនិត្យតាមដានការងារសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាក្នុងក្រុង / ស្រុកទាំង៥ បាន **២១** សាលា ។

➢ **ការអភិវឌ្ឍសម្ភារប្រើប្រាស់**

- បានចំណាយថវិកាកម្មវិធីចំនួន **៥,០០០,០០០ រៀល** ដើម្បីទិញសម្ភារដាក់ក្នុងហិបសង្គ្រោះបឋម សម្រាប់សាលាចំនួន **៥០** ទូទាំងខេត្ត ដែលជួបការលំបាកខ្លាំង

- បានសហការជាមួយអង្គការ **វិថីបៃតងកម្ពុជា** ដើម្បីចុះចែកសម្ភារសុខភាពមាត់ធ្មេញ នៅតាមគ្រឹះស្ថានសិក្សាក្នុងក្រុងសំរោង ចំនួន ១១ សាលា សិស្សសរុប ២០៣៤ នាក់ ស្រី ១០១០នាក់

## ខ-លទ្ធផលធៀបនឹងទិសដៅសន្និបាតឆ្នាំ២០១៧

### ខ.១- ការងារអប់រំកាយ និងកីឡា

➢ **ការងារអនុវត្តបាន:**

- បានបញ្ចូលការងារអប់រំកាយ និងកីឡា ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់
- បានចូលរួមប្រកួតកីឡាគ្រប់កម្មវិធីទាំងអស់ដែលក្រសួងរៀបចំ
- បានចូលរួមប្រកួតជាលក្ខណៈមិត្តភាពកម្ពុជា -ថៃ
- បានរៀបចំការប្រកួតកីឡាថ្នាក់ខេត្ត និងថ្នាក់ក្រុង/ស្រុក

- បានរៀបចំប្រកួតកីឡាដើម្បីទាំងអស់គ្នា ជ្រើសរើសជើងឯក ថ្នាក់ខេត្តប្រចាំឆ្នាំ២០១៧

➢ **ការងារមិនបានអនុវត្ត:**

- គ្មានខ្ទង់ថវិកាសម្រាប់ជួសជុលហេដ្ឋារចនាសម្ព័ន្ធកីឡាតាមគ្រឹះស្ថានសិក្សា
- សហព័ន្ធមិនអនុញ្ញាតឱ្យចូលរួមប្រកួតបាល់ទាត់យុវជន អាយុក្រោម១៤ និង១៦ឆ្នាំ

## ខ.៤ ការងារសុខភាពសិក្សា

➢ **ការងារអនុវត្តបាន:**

- បានរៀបចំគណៈកម្មការទទួលបន្ទុកសុខភាពសិក្សាចាប់ពីថ្នាក់ខេត្ត ក្រុង/ស្រុករហូតដល់ថ្នាក់គ្រឹះស្ថានសិក្សា
- បើកវគ្គបំប៉នសមត្ថភាពដល់មន្ត្រីទទួលបន្ទុកការងារសុខភាពតាមក្រុងស្រុកនិងតាមគ្រឹះស្ថានសិក្សាបានចំនួន **១៨៤** នាក់ ស្មើនឹង **៧៥%**
- គ្រូ -សិស្សបានលេបថ្នាំទម្លាក់ដង្កូវព្រូន មួយឆ្នាំសិក្សា **ពីរដង**
- ចុះជួយសិស្សដែលពុលចំនួន **១១**នាក់ ស្រី **៥**នាក់ នៅសាលាបឋមសិក្សាសាលារ៉ាំង ក្នុងស្រុកបន្ទាយអំពិល
  - គ្រប់គ្រឹះស្ថានសិក្សាទាំងអស់មានហិបសង្គ្រោះបឋម ដែលបានទទួលការឧបត្ថម្ភពីនាយកដ្ឋានសុខភាព
  - សាងសង់បង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃ បានចំនួន ០៩ សាលា នៅក្រុងសំរោង ស្រុកអន្លង់វែង បន្ទាយអំពិល និង ស្រុកចុងកាល់ ។

➢ **ការងារមិនបានអនុវត្ត:**

- មិនបានបើកវគ្គបំប៉នសមត្ថភាពដល់មន្ត្រីទទួលបន្ទុកសុខភាពសិក្សាមិនទាន់បានគ្រប់គ្នា
- ការផ្គត់ផ្គង់សម្ភារ ដាក់ក្នុងហិបមិនទាន់បានគ្រប់គ្រាន់តាមតម្រូវការ
- ការពិនិត្យតាមដានមិនទាន់បានគ្រប់សាលា និងតាមតម្រូវការ

## ខ-ការវិភាគអំពីវឌ្ឍនភាពនៃសូចនាករផលសម្រេច

| VII | ការអប់រំកាយ និងកីឡា | ជាក់ស្តែង 2015-2016 | ចំណុចដៅ 2016-2017 | ជាក់ស្តែង 2016-2017 | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា | | | | | |
| 1 | ចំនួនគ្រូអប់រំកាយ និងកីឡាបណ្តុះបណ្តាលក្នុងមួយឆ្នាំ | 2 | 3 | | ↑ |
| 2 | ទីលានកីឡាត្រូវកែលម្អ | | | | |
| | ពហុកីឡដ្ឋានខេត្ត | 1 | 1 | | → |
| | វិទ្យាល័យ និងអនុវិទ្យាល័យនានា | | N/A | | N/A |
| 3 | គ្រឹះស្ថានមធ្យមសិក្សា | | | | |
| | ទីលានបាល់ទាត់១០ | | N/A | | N/A |
| | ទីលានបាល់បោះ១៥ | | N/A | | N/A |
| | ទីលានបាល់ទះ២០ | | N/A | | N/A |
| គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |

❖ សម្គាល់ : ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

**គ-បញ្ហាប្រឈម**

- ពុំមានកញ្ចប់ថវិកាសម្រាប់ជួសជុលហេដ្ឋារចនាសម្ព័ន្ធកីឡាតាមគ្រឹះស្ថានសិក្សា
- ខ្វះគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡាតាមគ្រឹះស្ថានសិក្សា
- ការចុះពិនិត្យតាមដានការលក់ដូរនំចំណីតាមគ្រឹះស្ថានសិក្សាពុំបានញឹកញាប់
- ខ្វះសម្ភាររូបវន្តសុខភាពសិក្សា (អណ្តូងទឹក អាងស្តុកទឹក បង្គន់អនាម័យ កន្លែងលាងសម្អាតដៃទូទាំងខេត្ត )

## ២-២-៧- ការងារផែនការ និង គ្រប់គ្រងចំណាយ

**ក-លទ្ធផលសម្រេចបាន**

### ក-១-ការងារផែនការ

- បានរៀបចំផែនការកម្មវិធីការងារប្រចាំឆ្នាំ២០១៧
- បានប្រជុំក្រុមបច្ចេកទេសចម្រុះវិស័យអប់រំប្រចាំឆ្នាំ២០១៧
- បានធ្វើផែនការថវិកាតាមកម្មវិធីឆ្នាំ២០១៧
- បានធ្វើផែនការវិនិយោគបីឆ្នាំរំកិលសម្រាប់២០១៨ជូនសាលាខេត្តឧត្តរមានជ័យ
- បានចូលរួមធ្វើផែនការសមាហរណកម្មថ្នាក់ខេត្តក្រុង-ស្រុកនិងឃុំសង្កាត់ឆ្នាំ២០១៧
- បានធ្វើផែនការតម្រូវការចំណាយថវិកាUNICEFប្រចាំឆ្នាំ២០១៧
- បានធ្វើផែនការតម្រូវការស្បៀងអាហារពេលព្រឹកសម្រាប់សាលាបឋមសិក្សា១៣១ សាលា ឆ្នាំ២០១៧ ក្នុងនោះកម្មវិធីអាហារតាមសាលារៀនប្រើកសិផលពីសហគមន៍២១
- បានធ្វើផែនការតម្រូវការអាគារសិក្សាសម្រាប់ឆ្នាំ២០១៧ និង ២០១៨
- បានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧
- បានរៀបចំរបាការណ៍ វឌ្ឍនភាពផែនការយុទ្ធសាស្ត្រវិស័យ អប់រំ ២០១៥-២០១៧
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាវិស័យអប់រំ២០១៧.២០១៩

### ក-២-ការងារស្ថិតិអប់រំ

- បានបញ្ជូនតារាងជំរឿនស្ថិតិសាលារៀនប្រចាំឆ្នាំ២០១៦-២០១៧ទៅក្រុង-ស្រុកនិងសាលារៀន៣២៩ សាលា
- បានប្រមូលតារាងជំរឿនស្ថិតិសាលារៀនប្រចាំឆ្នាំចំនួន ៣២៩ សាលា និងក្រុង-ស្រុកទាំង៥ ធ្វើការពិនិត្យផ្ទៀងផ្ទាត់ចងក្រងតារាងជំរឿនស្ថិតិចំនួន ៣២៩សាលារួចបញ្ជូនទៅនាយកដ្ឋានផែនការ(ការិ.EMIS)
- បានប្រមូលតារាងពិន្ទុសិស្សតាមមុខវិជ្ជា ប្រចាំឆ្នាំចំនួន ២៣៧ សាលា និងក្រុង-ស្រុកទាំង៥ ធ្វើការពិនិត្យផ្ទៀងផ្ទាត់ចងក្រងតារាងជំរឿនសម្រង់ពន្ទុសិស្សតាមមុខវិជ្ជាចំនួន ២៣៧សាលា រួចបញ្ជូនទៅនាយកដ្ឋានផែនការ(ការិ.EMIS)
- មានស្ថិតិសាលារៀនថ្នាក់-សិស្សនិងគ្រូសម្រាប់ប្រើប្រាស់ក្នុងមន្ទីរ និងបែងចែង ដល់ក្រុង/ស្រុក និងអ្នកពាក់ព័ន្ធ ។

- បានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យអប់រំ។

**ក-៣-ការកសាងសមត្ថភាពមន្ត្រី**

- បានបើកវគ្គបំប៉នការបំពេញតារាងជំរឿនស្ថិតិសាលា និងតារាងពិន្ទុសិស្ស និងការកសាងផែនការប្រចាំឆ្នាំដល់មន្ត្រីក្រុង/ស្រុក និងសាលារៀន
- បានប្រជុំក្រុមបច្ចេកទេសចម្រុះវិស័យអប់រំប្រចាំត្រីមាស
- បានបើកវគ្គបំប៉នការងារ ផែនការ ផែនការប្រតិបត្តិ របាយការណ៍សមិទ្ធកម្ម របាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ ។

**ក-៤-ការងាររបាយការណ៍**

- បានធ្វើរបាយការណ៍សំណង់អគារសិក្សាជូនក្រសួងនិងម្ចាស់ជំនួយ
- បានធ្វើរបាយការណ៍វឌ្ឍនភាពវិស័យអប់រំប្រចាំឆមាសទី១ឆមាសទី២និងចុងឆ្នាំ
- បានធ្វើរបាយការណ៍បូកសរុបការងារស្ថិតិក្នុងការអនុវត្តរយៈពេល០១ឆ្នាំកន្លងមកជូនការិយាល័យEMISនាយកដ្ឋានEMIS
- បានធ្វើរបាយការណ៍ប្រើប្រាស់ស្បៀង តាមសាលារៀនជូនកម្មវិធី WFP
- បានធ្វើរបាយការណ៍បូកសរុបចំណាយថវិកា UNICEF
- បានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និង ប្រចាំឆ្នាំ
- បានចូលរួមធ្វើរបាយការណ៍សន្និបាតប្រចាំឆ្នាំ ២០១៦-២០១៧ នៅតាមក្រុងស្រុក។

**ក-៥-ការងារពិនិត្យតាមដាន**

- បានចុះជួយណែនាំបន្ថែមដល់ក្រុង/ស្រុកនិងសាលារៀនដែលជួបការលំបាកក្នុងការបំពេញតារាងជំរឿនស្ថិតិប្រចាំឆ្នាំ
- បានចុះប្រមូលតារាងសម្រង់ពិន្ទុសិស្សនៅបឋមសិក្សានិងមធ្យមសិក្សាពីតាមក្រុងស្រុក/ដែលមានការយឺតយ៉ាវ ៥ទាំង
- បានចុះប្រមូលតារាងជំរឿនស្ថិតិពីក្រុង-ស្រុកនិងសាលារៀនដែលមានការយឺតយ៉ាវ
- បានចុះពិនិត្យតាមដានការគ្រប់គ្រងនិងប្រើប្រាស់ស្បៀងអាហារពេលព្រឹកនៅតាមសាលា

**ខ-បញ្ហាប្រឈម**

- ការិយាល័យអប់រំស្រុកធ្វើរបាយការណ៍យឺត
- នាយកសាលាមានការលំបាករៀបចំផែនការអភិវឌ្ឍសាលារៀន និងរបាការណ៍សមិទ្ធកម្ម
- ការបំពេញរបាយការណ៍ ស្ថិតិពុំទាន់បានត្រឹមត្រូវ និងបញ្ជូនមកការិ. អយកក្រុងមិន បានទាន់ ពេល ( ដើមឆ្នាំ កណ្ដាលឆ្នាំ និងចុងឆ្នាំ )
- សាលារៀបចំផែនការអភិវឌ្ឍន៍ពុំទាន់បានសមស្របទៅតាមស្ថានភាពជាក់ស្តែងដែលជាចំណុចអវិជ្ជមាន

- ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំពុំទាន់មានលក្ខណល្អប្រសើរ(មន្ត្រីទទួលបន្ទុកនៅមានកម្រិត និងពុំទាន់មានបទពិសោធន៍
- អគារសិក្សាមួយចំនួនពុំទាន់សមរម្យ
- សាលារៀនចំនួន ០១ ពុំទាន់មានបង្គន់អនាម័យគឺសាលាស្រះព្រិច
- សាលានៅខ្វះតុសិស្សអង្គុយ
- នាយកសាលាពុំសូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងសៀវភៅសិក្សាគោល និពិនិត្យតាមដាន ជា ប្រចាំ ។
- ខ្វះកន្លែងទុកដាក់សៀវភៅ
- ការគ្រប់គ្រងសៀវភៅមិនទាន់បានល្អ និងត្រឹមត្រូវនៅឡើយ ការប្រមូល និងរាប់ចុងឆ្នាំសិក្សាមានការខូចនិងបាត់បង់សៀវភៅច្រើន
- ការផ្តល់ជូនសៀវភៅតាមមុខវិជ្ជា មិនបានតាមតម្រូវការ និងទាន់ពេល

## ២-២-៨- ការងាររដ្ឋបាល បុគ្គលិក និងបណ្ណុះបណ្តាល

### ក-លទ្ធផលសម្រេចបាន

### ក-១-ការងាររដ្ឋបាល

- ទទួលបានលិខិតចូលគ្រប់ប្រភេទ ពីក្រសួងនិងអង្គភាពពាក់ព័ន្ធបានចំនួន ១១៥០ ច្បាប់ បានចេញលិខិតចំនួន ២៨៥៨ ច្បាប់(លិខិតឧទ្ទេសនាម ៦៩៤ ច្បាប់ )
- សហការជាមួយអាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធរៀបចំពិធីបុណ្យជាតិ-អន្តរជាតិ និងរៀបចំពិធីផ្សេងៗ
- ពង្រឹងការងារសណ្តាប់ធ្នាប់និងការគោរពបទបញ្ជាផ្ទៃក្នុងរបស់មន្ត្រីអប់រំក្នុងអង្គភាព
- បានអនុវត្តការចុះវត្តមានបុគ្គលិកប្រចាំថ្ងៃ
- ធ្វើរបាយការណ៍បូកសរុបការងារប្រចាំអឌ្ឍមាន ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំជូនសាលាខេត្ត និងអង្គភាពពាក់ព័ន្ធ បានទាន់ពេលវេលា ។
- ធ្វើសំណើសុំគ្រឿងឥស្សរិយយសការងារប្រចាំឆ្នាំជូនបុគ្គលិកអប់រំចំនួន ១៨៦ នាក់ ទង់ជ័យលាភី ១៣ អង្គភាព ។
- ធ្វើសំណើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ ជូនសប្បុរសជន និងអង្គការដែលបានជួយវិស័យអប់រំ ក្នុងខេត្ត ចំនួន ១៣ គ្រឿង លិខិតថ្លែងអំណរគុណចំនួន ១៩ ច្បាប់ ពីក្រសួង
- មន្ទីរចេញប័ណ្ណសរសើរ និងលិខិតថ្លែងអំណរគុណដល់សប្បុរសជន ចំនួន១០ ច្បាប់
- ចូលរួមពិធីសម្ពោធអាគារសិក្សាថ្មី ចំនួន ០៨ សាលា
- ផ្សព្វផ្សាយលិខិតបទដ្ឋាននានា តាមអង្គភាពពាក់ព័ន្ធ បានទាន់ពេលវេលា
- រៀបចំទុកដាក់ឯកសារតាមការណែនាំ របស់ក្រសួង
- ធ្វើសំណើសុំប្រើប្រាស់ត្រាមូលចំនួន ៣៦ សាលា ទៅក្រសួងអប់រំ យុវជន និងកីឡា

## ក-២-ការងារបុគ្គលិក

- បុគ្គលិកអប់រំសរុប ១៨៩០ នាក់ ស្រី ៧២៤ នាក់ ស្មើនឹង ៣៨,៣១ % (កើន ៣២ នាក់ ស្រី ៣១ នាក់ )ក្របខ័ណ្ឌ មត្តេយ្យ ៤៩ នាក់ ស្រី ៤៧ នាក់ ស្មើ ៩៦,00% ក្របខ័ណ្ឌ បឋម ១១៦២ នាក់ ស្រី ៤៧៩ នាក់ ៤១,00% ក្របខ័ណ្ឌមូលដ្ឋាន ៥០៨ នាក់ ស្រី ១៦៧ នាក់ ស្មើ ៣៣,00% ក្របខ័ណ្ឌអបរំកាយកីឡា ២៩ ស្រី ០៥ ស្មើ ១៧,00 % កម្រិតឧត្តម ១៣៤ស្រី ២៥ នាក់ ស្មើ ១៩,00 % ក្របខ័ណ្ឌ ធិការបឋម ០១ នាក់ ស្រី ០០ នាក់ ក្របខ័ណ្ឌបារាំង-ខ្មែរ ០៥ ស្រី ០១ នាក់ ស្មើ ២០%
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានប្រើប្រាស់មន្ត្រីកិច្ចសន្យាចំនួន០៦ នាក់ ស្រី ០២ នាក់
- គ្រូជាប់កិច្ចសន្យាចំណេះទូទៅចំនួន ២៣ នាក់ ពីរវេន ៣៧០ នាក់ គួបពីកម្រិត ២២៤ នាក់ គួបបីកម្រិត ០៣នាក់ ។
- បុគ្គលិកនៅក្រៅក្របខ័ណ្ឌដើមចំនួន ៥ នាក់ ស្រី ០៥ នាក់
- បុគ្គលិកចូលនិវត្តន៍ចំនួន ០៧ នាក់ ស្រី ០០ នាក់ ក្នុងឆ្នាំ២០១៧
- ធ្វើសំណើសុំតែងតាំងស៊ប់ជូនគ្រូគ្រប់កម្រិតក្របខ័ណ្ឌចំនួន ៩៧ នាក់ ស្រី ៥១ នាក់
- ស្នើសុំតែងតាំងស៊ប់ប្តូរប្រភេទក្របខ័ណ្ឌ ចំនួន ២៥ នាក់ ស្រី ០៦ នាក់
- អនុញ្ញាតច្បាប់លំហែមាតុភាពចំនួន ៩៨ នាក់
- អនុញ្ញាតច្បាប់ព្យាបាលជំងឺចំនួន ១៥ នាក់ ស្រី ០៧ នាក់
- បុគ្គលិកអប់រំទំនេរគ្មានបៀវត្ស ចំនួន ០៣ នាក់ស្រី០២នាក់
- បុគ្គលិកអប់រំផ្លាស់ប្តូរទីកន្លែងបម្រើការងារឆ្លងខេត្ត ចំនួន ១៣ នាក់ ស្រី ០៤ នាក់
- បុគ្គលិកផ្លាស់ប្តូរកន្លែងបម្រើការងារក្នុងខេត្ត ចំនួន ៥០ នាក់ ២៥ នាក់
- បុគ្គលិកដាក់ពាក្យសុំចូលបម្រើការងារវិញចំនួន ០១ នាក់ ស្រី ០១ នាក់
- ចាត់បុគ្គលិកពង្រាយ និងផ្លាស់ចូលពីក្រៅខេត្ត ចំនួន ១០ នាក់ ស្រី ០៤ នាក់
- ធ្វើសំណើសុំលុបឈ្មោះបុគ្គលិកបោះបង់ចំនួន ០៦ នាក់ ស្រី ០១ នាក់
- បុគ្គលិកមរណៈភាពចំនួន ០៣ នាក់ ស្រី ០០ នាក់
- បានចុះពិនិត្យតាមដាន ការងារក្របខ័ណ្ឌ ការបង្រៀនពីរថ្នាក់ពីពេល គួប និងកិច្ចសន្យា តាមសាលារៀនបានចំនួន ៨១ សាលា (ក្នុងនោះប្រើប្រាស់ថវិកាគម្រោង០៣សាលា )
- ធ្វើសំណើសុំតែងតាំងមន្ត្រីគ្រប់គ្រង ប្រធាន-អនុប្រធានការិយាល័យ និងនាយក-នាយករងនៅតាមអង្គភាព ចំនួន ២៨ នាក់ ស្រី ០១ នាក់ ទៅសាលាខេត្ត
- បុគ្គលិកអប់រំ ០១ នាក់ នៅបន្តជាប់ឃុំឃាំងក្នុងពន្ធនាគារខេត្ត ឧត្តរមានជ័យ
- ធ្វើតម្រូវការគ្រូគ្រប់កម្រិត ប្រចាំឆ្នាំ និងឆ្នាំបន្ទាប់ ជូនក្រសួងអប់រំ យុវជន និងកីឡា
- ធ្វើផែនការយុទ្ធសាស្ត្រថវិកា២០១៩ -២០២១ និងផែនការថវិកាប្រចាំឆ្នាំ២០១៧
- បានទទួលប្រកាសតម្លើងកាំប្រាក់បុគ្គលិកអប់រំឆ្នាំ២០១៦ចំនួន១៣៥៣នាក់ស្រី ៤២៦នាក់

- ស្នើសុំតម្លើងកាំប្រាក់ជូនបុគ្គលិកអប់រំឆ្នាំ២០១៨ ចំនួន ១៤២២ នាក់ ស្រី ៤៦៣ នាក់ទៅក្រសួងអប់រំ យុវជន និងកីឡា ។
- ទទួលបានប្រកាសតម្លើងថ្នាក់បុគ្គលិកឆ្នាំ២០១៧ ចំនួន ១៥៥ នាក់ ស្រី ៧៣ នាក់
- បានចេញលិខិតករណីសុំច្បាប់ព្យាបាលជំងឺនិងលំហែមាតុភាព ទៅតាមក្រុង-ស្រុក ដើម្បីផ្សព្វ-ផ្សាយដល់បុគ្គលិកអប់រំ ។
- កម្រងសំណួរបុគ្គលិកអប់រំ (សម្រាប់នាយក ) ១ ឆ្នាំ ២ដង ពី ចំនួនអាគារ សិស្ស បុគ្គលិក
- កម្រងសំនួរសម្រាប់បុគ្គលិកអប់រំ ទូទៅ ១ឆ្នាំ ១ ដង ( ពីស្ថានភាពព័ត៌មានរបស់បុគ្គលិកម្នាក់ៗ ប្រចាំឆ្នាំ) ។
- បញ្ចូលទិន្នន័យគ្រូចេញថ្មី ចំនួន ៥៥ នាក់ ស្រី ៣១ នាក់ និងផ្លាស់-ពង្រាយចូល ១០ នាក់ ស្រី ០៤ នាក់ ។
- កែសម្រួល បុគ្គលិកផ្លាស់ចេញ-ចូល ចូលនិវត្តន៍ ទំនេរគ្មានបៀវត្ស លុបឈ្មោះ តែងតាំងដូរប្រភេទ ក្របខ័ណ្ឌ តែងតាំងស៊ប់ក្នុងក្របខ័ណ្ឌ ស្តីបន្ទោស ការលើកសរសើរ កាំប្រាក់ទៅក្នុង ប្រពន្ធ័ទិន្នន័យ ។
- ប្រែប្រួលស្ថានភាពបុគ្គលិកអប់រំ និងស្ថានភាពគ្រួសារមន្ត្រីរាជការ (កូន ប្រពន្ធ ប្រាក់បំណាច់ផ្សេងៗ ) ប្រចាំខែបានទាន់ពេលវេលា ។
- ផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនបុគ្គលិកអប់រំ និងមន្ត្រីកិច្ចសន្យាបានទាន់ពេលវេលា ។

## ក-៣-ការងារបណ្តុះបណ្តាល

- ប្រឡងជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សានៅក្នុងខេត្ត មានបេក្ខជនសរុប ៩១៧ នាក់ ស្រី ៥៤៩ នាក់ មត្តេយ្យ ៩៩ នាក់ ស្រី ៩៧ នាក់ ជាប់ជាស្ថាពរ ៥០ នាក់ ស្រី ៣៣ នាក់ ក្នុងនោះមត្តេយ្យ០៥ នាក់ស្រី ០៥ នាក់ ។
- បញ្ជូនសំណុំលិខិតសុំបេក្ខជនទៅប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាននៅខេត្តបាត់ដំបង ចំនួន នាក់ ៥៦៧ ស្រី ៣១៧ នាក់ ជាប់ស្ថាពរ ១១ នាក់ ស្រី ។
- បញ្ជូនគ្រូបឋមនិងមត្តេយ្យដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ទៅបំប៉នជាគ្រូបង្រៀនកម្រិតមូលដ្ឋានរយៈពេលខ្លីនៅមជ្ឈមណ្ឌលភូមិភាគបាត់ដំបង ចំនួន ២៤ នាក់ ស្រី ០៥ នាក់ ។
- គ្រូបន្តការសិក្សា នៅវិទ្យាស្ថានជាតិអប់រំ ចំនួន ០២ នាក់ ស្រី ០១ នាក់ ។
- គ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ១៦ នាក់ ស្រី ០៤ នាក់ ប្រឡងជាប់ជាគ្រូបង្រៀនកម្រិតឧត្តមតាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ ។
- បេក្ខជនខេត្ត ឧត្តរមានជ័យប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន (១២+២ ) និងបណ្តុះបណ្តាលនៅខេត្តបាត់ដំបងចំនួន ១១ នាក់ ស្រី ០៤ នាក់ ។

## ខ-បញ្ហាប្រឈម

### ខ-១-ការងាររដ្ឋបាល

- ការរៀបចំលិខិតរដ្ឋបាល ការិយាល័យក្នុងមន្ទីរ ក្រុង-ស្រុក មិនទាន់បានសមស្រប (មូលហេតុះមន្ត្រីមិនបានឆ្លងកាត់វគ្គបំប៉នរយៈពេលខ្លីពីកិច្ចការរដ្ឋបាល អ្នកបានចូលរួមវគ្គត្រឹមតែ ពី០៣នាក់ ទៅ ០៥នាក់ ) ។
- ការទុកដាក់ឯកសាររដ្ឋបាល មិនទាន់បានសមស្របតាមការណែនាំ របស់ក្រសួង ។

### ខ-២-ការងារបុគ្គលិក

- ការបើកប្រាក់របស់គ្រូបង្រៀន នៅថ្នាក់ មានការលំបាក មូលហេតុ ះមិនទាន់មានទូរ ATM គ្រប់ក្រុង-ស្រុក គឺស្រុកត្រពាំងប្រាសាទ ស្រុកអន្លង់វែង ស្រុកបន្ទាយអំពិល ។
- ការពង្រាយគ្រូ មិនទាន់តាមចំណុចដៅ ប្រាក់លើកទឹកចិត្តនៅមានកម្រិតទាប មិនអាចទៅបម្រើការនៅសាលាជួបការលំបាក និងកើតថ្មី ។
- ការចុះពិនិត្យតាមដានសាលា ការងារប្រើប្រាស់ក្របខ័ណ្ឌ (កិច្ចសន្យា គួប ពីរថ្នាក់ពីរពេល ) មិនបានគ្រប់អង្គភាព ។
- ខ្វះគ្រូបង្រៀនកម្រិតឧត្តម (ឯកទេស សេដ្ឋកិច្ច អង់គ្លេស ជីវវិទ្យា ផែនដី ភូមិ-ប្រវត្តិ រូបគីមី និងសីលធម៌ ពលរដ្ឋ ) សរុប30នាក់ ។
- ខ្វះគ្រូបង្រៀនកម្រិតមូលដ្ឋាន( ឯកទេសភាសាបរទេស ជីវផែនដី អប់រំ កាយកីឡា )
- ខ្វះគ្រូបឋម និងមត្តេយ្យសិក្សា សរុប 370នាក់ មត្តេយ្យ 105នាក់ ។

### ខ-៣-ការងារបណ្តុះបណ្តាល

- គ្រូបង្រៀនមួយចំនួនតូចមិនទាន់មានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- គ្រូបង្រៀននៅតាមព្រំដែនដាច់ស្រយាល មិនមានលទ្ធភាពអភិវឌ្ឍសមត្ថភាព ឬ បន្តការសិក្សា យកកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រខ្ពស់ជាងក្របខ័ណ្ឌ ។
- គ្រូបង្រៀន មួយចំនួនពុំមានចំណេះដឹងលើជំនាញមូលដ្ឋាន ICT និងភាសាអង់គ្លេស ។
- គ្រូបង្រៀនថ្នាក់ទី៤ ដល់ថ្នាក់ទី៦ បានបំប៉នភាសាអង់គ្លេស សម្រាប់អនុវត្តកម្មវិធីសិក្សាថ្មីផ្នែកភាសាអង់គ្លេសមានរយៈពេលខ្លី និងមិនបានគ្រប់គ្រូដែលបង្រៀនថ្នាក់ទី៤ ដល់ទី៦ ។

## ២-២-៩- ការិយាល័យ គណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

### ក- វឌ្ឍនភាព

#### ក-1-លទ្ធផលសម្រេចបាន

**ការងារគ្រប់គ្រងថវិកា កម្មវិធីឆ្នាំ២០១៧**

-ប្រជុំធ្វើណែនាំពីនិតិវិធីរៀបចំផែនការយុទ្ធសាស្ត្រថវិកា(BSP) ២០១៨-២០២០ ដល់ការិយាល័យជំនាញ នៃអង្គភាពថវិកា ។

-ប្រជុំធ្វើណែនាំពីនិតិវិធីរៀបចំគម្រោងថវិកាឆ្នាំ២០១៨ តាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ នៃអនុវិស័យទាំង៦ ។

-មានការផ្សព្វផ្សាយ អនុក្រឹត្យ ប្រកាសអន្តរក្រសួង ប្រកាស សារាចរណែនាំ និងលិខិតបទដ្ឋានផ្សេងៗ ដើម្បីគាំទ្រក្នុងការអនុវត្ត របស់អង្គភាពថវិកា ។

-អង្គភាពថវិកាជាអ្នករៀបចំប្រមូលឯកសារចំណូល ចំណាយ និងលិខិតយុត្តិការផ្សេងៗ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ និងការទូទាត់(ជូនថ្នាក់មូលដ្ឋាន និងអង្គភាពអនុវត្ត)

-ការអនុវត្តកិច្ចលទ្ធកម្ម ចំនួន៥គម្រោងក្នុងឆ្នាំ២០១៧ (សម្រេចបាន ១០០%)

-មន្ទីរអប់រំខេត្តឧត្តរមានជ័យ បាននិយ័តផ្ទៃក្នុងតាមកម្មវិធីនីមួយៗ(ពិសេសជំពូក៦២ )

-ថវិកាដំណើរការសាលាបើកទាន់ពេលនៃត្រីមាន និងបៀវត្សបើកចុងខែនីមួយៗ

-ពង្រឹងបន្ថែមលើកិច្ចបញ្ជិកាទាំង៦មុខ និងនិតិវិធីការគ្រប់គ្រងសម្ភារទ្រព្យសម្បត្តិរដ្ឋ ការជម្រះសម្ភារ បរិក្ខាបច្ចេកទេស សង្ហារឹម ដែលខូចប្រើប្រាស់មិនកើតចេញពីបញ្ជីសារពើភ័ណ្ឌ និងណែនាំពីមាតិកាថវិកាថ្មី(ប្រកាសលេខ ៥២៣) ដល់ការិយាល័យក្រុង/ស្រុក និងសាលារៀន ។

-បានបំប៉នស្តីពីពង្រឹងសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធការគ្រោងថវិកានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ទូទាំងប្រទេស និងរបាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ឆ្ពោះទៅការប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឲ្យមានតម្លាភាព គណនេយ្យភាព ប្រសិទ្ធិភាព និងអនុវត្តទាន់ពេលវេលា ស្របតាមកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ។

-មន្ទីរបានជម្រះ សម្ភារបរិក្ខាបច្ចេកទេស និងសង្ហារឹម ដែលខូចប្រើប្រាស់មិនកើត ចេញពីបញ្ជីសារពើភ័ណ្ឌ ក្នុងការិយាល័យក្រោមឱវាទមន្ទីរ (តាមតារាងកើន ថយ ឆ្នាំ២០១៦ )។

-ក្នុងឆ្នាំ២០១៨ក្រសួងអប់រំ និងក្រសួងសហវ បានសម្រេចផ្តល់ថវិកាជូន២,៥លានរៀល/១សាលា ដោយបន្ថែមលើប្រការអន្តរក្រសួងលេខ៥០៨ ដែលបានអនុវត្តកន្លងមក និងផ្តល់ថវិកាជូនក្រុង/ស្រុកពី១២លានរៀល ទៅ ២៤លានរៀល/១ក្រុង.ស្រុកឆ្នាំ២០១៨ ។

**ចំណូល**

ចំណូលពីការបង់សិទ្ធិប្រឡងក្នុងឆ្នាំសិក្សា២០១៦-២០១៧ **សរុប= ៦,៥៨០,៥០០៛**

-សិទ្ធិប្រឡងសិស្សមធ្យមសិក្សាបឋមភូមិចំនួន ១,៩៤១ នាក់ សរុប=១,៩៤១,០០០៛

-សិទ្ធិប្រឡងសិស្សមធ្យមសិក្សាទុតិយភូមិចំនួន ១.៤០០ នាក់ សរុប=១,៤៧៧,០០០៛

-ការបង់សិទ្ធិប្រឡងបឋម និងមត្តេយ្យសិក្សាចំនួន១,៥៨១ នាក់ សរុប= ៣,១៦២,០០០៛

**ស្ថានភាពឥណទានក្នុងឆ្នាំ ២០១៧ ៖**

**ថវិកាកម្មវិធី**

-ថវិកាជំពូក ៦០ ការទិញ សរុប = ២,០៣៨,៥០០,០០០៛

-ថវិកាជំពូក ៦១ សេវាកម្ម សរុប = ២,៣៦៨,៥០០,០០០៛

-ថវិកាជំពូក៦៤ បន្ទុកបុគ្គលិក សរុប = ៣២,៣៨៨,០១៥,០០០៛

-ថវិកាជំពូក៦២ អត្ថប្រយោជន៍សង្គម សរុប = ១,៩៦៥,៩០០,០០០៛

**សរុប =៣៨,៧១២,៧១៥,០០០៛**

**សម្រាប់ថវិកាជំនួយក្នុងឆ្នាំ២០១៧ (ដែលឆ្លងកាត់តាមរយៈមន្ទីរ)**

-គម្រោងថវិកា SIG ឆ្នាំ២០១៥ -២០១៧ សរុប = $334,908,56

-គម្រោងថវិកា UNICEF ឆ្នាំ២០១៦-២០១៧ សរុប = $19,717.5

-គម្រោងថវិកា WFP ឆ្នាំ២០១៣-២០១៧ សរុប = $1,626,510.85

**សរុប = $1,981,136,91**

**ស្ថានភាពថវិកាកម្មវិធីក្នុងឆ្នាំ២០១៧**

-ស្ថានភាពចំណាយ និងបោះផ្សាយអាណត្តិទូទាត់ ( ថវិកាកម្មវិធី )

ថវិកាបើកចេញពីរតនាគារខេត្ត គិតមកដល់ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៧

សរុប**៣៧,៣១០,៤២៣,០៥១**រៀល ស្មើនឹង **៩៦,៦៣%** នៃឥណទានសរុបប្រចាំឆ្នាំ ២០១៧

ក្នុងឆ្នាំ ២០១៧ នេះការអនុវត្តចំណាយនិងទូទាត់អាណត្តិជាក់ស្តែងប្រចាំឆ្នាំ សរុបចំនួន: **៣៧,២០៣,៦៨០.៨៥១** រៀល ស្មើនឹង **៩៦,០៩%** នៃឥណទានសរុបប្រចាំឆ្នាំ ២០១៧ និងត្រូវបង់ចូលថវិការដ្ឋវិញចំនួន: **១០៦,៧៤២,២០០** រៀល(សល់ពីប្រឡង,ដំណើរការសាលារៀន,អាហារូបករណ៍សិស្សក្រីក្រ និងបៀវត្សគ្រូបង្រៀនអសកម្មមួយចំនួន/ប្រាក់តំបន់ដាច់ស្រយាលគ្រូផ្ទេរចេញ) ។

## ក-2. លទ្ធផលធៀប និងទិសដៅឆ្នាំ២០១៧

| ល.រ | បរិយាយ | ២០១៦ | ២០១៧ | កើន-ថយ | កើន(+)ថយ(-)% |
|---|---|---|---|---|---|
| ១ | ចំណូលសិទ្ធិប្រឡង និងផ្សេងៗ | 9,003,250 | 6,580,500 | -2,422,750 | -26,9% |
| ២ | សាច់ប្រាក់ដកបាន (ថវិកាកម្មវិធី) | 31,769,361,523 | 37,310,423,051 | 5,541,061,528 | 17.44% |
| ៣ | ថវិកាចំណាយជាក់ស្តែង (ថវិកាកម្មវិធី) | 31,646,450,217 | 37,703,680,851 | 5,557,230,634 | 17.56% |
| ៤ | សល់បង់សំណេសចំណាយចូលថវិការដ្ឋ | 87,457,700 | 106,742,200 | 19,284,500 | 22,2% |

**ក-៣- បញ្ហាប្រឈម**

ការរៀបចំកញ្ចប់ថវិកានៃមាតិកាថវិកា មិនស៊ីជាគ្នាជាមួយកម្មវិធី អនុកម្មវិធី/សកម្មភាព

- តាមអង្គភាពនីមួយទទួលការងារច្រើនពីនាយកដ្ឋានហួសពីសមត្ថភាពរបស់ និងទំហំការងារលើសពីសមត្ថភាពរបស់ខ្លួន (នាំឱ្យការចំណាយ -ទូទាត់មានការយឺតយ៉ាវ)

- អនុវិស័យ នៃសកម្មភាពនៅតាមអង្គភាពនីមួយៗ មិនទាន់សហការគ្នាបានល្អ និងផែនការ
- សកម្មភាពប្រែប្រួលភ្លាមៗ បន្ទាប់គ្រោងថវិការួចហើយ
- ប្រាក់បំណាច់ម៉ោងបន្ថែមមានការយឺតយារ (កម្មវិធីថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា)
- ការរៀបចំឯកសារ/ទូទាត់ បង្គន់អានាម័យមិនទាន់បានត្រឹមត្រូវតាមនិតិវិធីសាកសួរថ្លៃ
- អង្គភាពចំណាយមានចំនួនច្រើន តែការបូកសរុប និងការទូទាត់នៅអង្គភាពថវិកា (ពិបាកក្នុងការប្រមូលឯកសារទូទាត់ ថវិកាមួយចំនួនត្រូវបញ្ចូលតាមលេខគណនី)តាមមូលដ្ឋានអនុវត្ត ។
- ថវិកាដែលចំណាយមិនទាន់ឆ្លើយតបនិងលទ្ធផល(សិស្សបោះបង់,ការបង្រៀនរៀនរបស់គ្រូ និងលទ្ធផលការសិក្សារបស់សិស្ស,សហគមន៍ចូលរួមនៅមានកម្រិត.........)
- តាមក្រុង/ស្រុក និងសាលារៀន មិនទាន់បានធ្វើប័ណ្ណកម្មសិទ្ធិម្ចាស់អចលនវត្ថុ
- សម្ភារបរិក្ខាបច្ចេកទេស និងសង្ហារឹមមិនបានជម្រះ ចេញពីបញ្ជីសារពើភ័ណ្ឌ (ទាមទាការចូលរួមពីរសាលា,ការិ.ក្រុង/ស្រុក,ការិយាល័យជំនាញ.....)។

## ២-២-១០- ការិយាល័យ អធិការកិច្ច

### ក- ស្ថានភាព

បានចុះអធិការកិច្ចតាមកាលកំណត់ នៅតាមសាលារៀនសរុបចំនួន៣១សាលា (បឋមសិក្សា២៧សាលា និងមធ្យមសិក្សាបឋមភូមិ០៣ និងវិទ្យាល័យ០១) ថ្នាក់រៀនចំនួន៩៣ថ្នាក់ និងគ្រូបង្រៀនចំនួន៩៣នាក់ សកម្មភាពដើម្បីប្រមូលព័ត៌មានមកវិភាគ និងចងក្រងជារបាយការណ៍តាមរយៈ៖

- សង្កេតសកម្មភាពអនុវត្តផ្ទាល់ និង សមិទ្ធផលជាក់ស្តែង: ការបង្រៀន បរិស្ថាន ការរៀបចំតុបតែងទីចាត់ការ ថ្នាក់រៀន ការទុកដាក់ឯកសារ សម្ភារៈ អនាម័យ...
- ពិនិត្យឯកសារផ្សេងៗ: ការងាររដ្ឋបាលនាយក រដ្ឋបាលថ្នាក់ រដ្ឋបាលគ្រូ (របាយការណ៍កំណត់ហេតុ ផែនការ ស្ថិតិ ទិន្នន័យ បំណែងចែកភារកិច្ច រចនាសម្ព័ន្ធ គណៈកម្មការ ក្រុមប្រឹក្សា បញ្ជីវត្តមានគ្រូ/សិស្ស បញ្ជីពិន្ទុ ...)
- សម្ភាសន៍ នាយក គ្រូ សិស្ស និងសហគមន៍: ផ្តោតទៅលើបួនចំណុចសំខាន់ៗគឺ ការដឹកនាំ/គ្រប់គ្រង ការបង្រៀន និងរៀន លទ្ធផលសិក្សារបស់សិស្ស និងស្វ័យវាយតម្លៃសាលារៀន
- បូកសរុបរបាយណ៍ការអធិការកិច្ចតាមកាលកំណត់ជូនថ្នាក់ដឹកនាំមន្ទីរ និងក្រសួង(នា.ធគអ)
- ធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៨ ចំនួន០២សាលា នាយក០២នាក់ គ្រូ០៨នាក់ ស្រី០១នាក់ និង សិស្ស៦០នាក់ ស្រី៣២នាក់ នៅអនុវិទ្យាល័យគោកស្លាន ស្រុកចុងកាល់ និងអនុវិទ្យាល័យត្រពាំងប្រីយ៍ ស្រុកអន្លង់វែង។
- ធ្វើតេស្តវង្វាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ(PISA-D) ចំនួន០៦សាលា នាយក០៦នាក់ គ្រូ ១២៧ នាក់ និងសិស្ស ២៣៨ នាក់ នៅអនុវិទ្យាល័យចំនួន០២ គឺអនុវិទ្យាល័យត្រពាំងប្រីយ៍ ស្រុកអន្លង់វែង និងអនុវិទ្យាល័យទួលតាសេក ស្រុកត្រពាំងប្រាសាទ និងវិទ្យាល័យចំនួន០៤គឺវិទ្យាល័យតេជោសែនសំរោង វិទ្យាល័យ.ហស៊ុនឧត្តមានជ័យ ក្នុងក្រុងសំរោងវិទ្យាល័យ បន្ទាយអំពិល ក្នុងស្រុកបន្ទាយអំពិល និង វិទ្យាល័យ អន្លង់វែង ក្នុងស្រុកអន្លង់វែង ។

- ចុះពិនិត្យថ្នាក់មត្តេយ្យក្នុងបឋមសិក្សា បានចំនួន ១៤សាលា ស្មើនិង១៤ថ្នាក់
- ចុះពិនិត្យ សាលាឯកជនបានចំនួន ៦សាលា នៅស្រុកអន្លង់វែង និងត្រពាំងប្រាសាទ
- ចុះអធិការកិច្ច និងសម្របសម្រួលសកម្មភាពប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍សរុបចំនួន ០៩ កម្រង ស្មើ៦២សាលា មានគ្រូចូលរួមសរុប២៧០នាក់ ក្នុងនោះក្រុងសំរោងមាន: កម្រងបន្សាយរាក់ កម្រងបុស្សស្បូវ និងកម្រងថ្នល់បត់ ស្រុកចុងកាល់មានកម្រងពង្រ ស្រុកបន្ទាយអំពិលមាន: កម្រងគោកខ្ពស់ កម្រងបេង ស្រុកអន្លង់វែងមាន: កម្រងថ្លាត និង ស្រុកត្រពាំងប្រាសាទមានកម្រងត្រពាំងប្រាសាទ និងកម្រងទំនប់ខ្នុរ ។

**តារាងប្រៀបធៀបលទ្ធផលចុះអធិការកិច្ចតាមការកំណត់ឆ្នាំសិក្សា២០១៥-២០១៦និងឆ្នាំសិក្សា២០១៦-១៧**

**១-លទ្ធផលចុះអធិការកិច្ច ធៀប និងសាលា / ថ្នាក់ /គ្រូ សរុបទូទាំងខេត្ត**

| អធិការកិច្ច | ឆ្នាំ២០១៥-២០១៦ | | ឆ្នាំ២០១៦-២០១៧ | | ភាគរយ កើន/ថយ | មូលហេតុ |
|---|---|---|---|---|---|---|
| | បរិមាណ | ភាគរយ | បរិមាណ | ភាគរយ | | |
| សាលារៀន | ២០ | ៨,៤៣ | ៣១ | ១២,៦០ | ៤,១៧ | - មានថវិកាសមស្រប<br>-មានមន្ត្រីចូលថ្មីបន្ថែមសម្រាប់ចុះអធិការកិច្ច |
| ថ្នាក់រៀន | ៦០ | ៣,៦៨ | ៩៣ | ៥,៤៩ | ១,៨១ | |
| គ្រូបង្រៀន | ៦០ | ៣,៤៣ | ៩៣ | ៥,១៤ | ១,៧១ | |

**២-លទ្ធផលចុះអធិការកិច្ច សាលា / ថ្នាក់ /គ្រូ ធៀបនិងផែនការ**

| អធិការកិច្ច | ឆ្នាំ២០១៥-២០១៦ | | ឆ្នាំ២០១៦-២០១៧ | | ភាគរយ កើន/ថយ | មូលហេតុ |
|---|---|---|---|---|---|---|
| | បរិមាណ | ភាគរយ | បរិមាណ | ភាគរយ | | |
| សាលារៀន | ២០ | ៤៥ | ៣១ | ៨១,៥៧ | ៣៦,៥៧ | - មានថវិកាសមស្រប<br>-មានមន្ត្រីចូលថ្មីបន្ថែមសម្រាប់ចុះអធិការកិច្ច |
| ថ្នាក់រៀន | ៦០ | ៤៥,៤៥ | ៩៣ | ៨១,៥៧ | ៣៦,១២ | |
| គ្រូបង្រៀន | ៦០ | ៤៥,៤៥ | ៩៣ | ៨១,៥៧ | ៣៦,១២ | |

**ខ-ការអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ពិមជ្ឈការ ៖**

ការិយាល័យអធិការកិច្ចបានរៀបចំបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយស្តីពីលទ្ធផលអធិការកិច្ច និងលទ្ធផលតេស្តថ្នាក់ជាតិ ថ្នាក់ទី៦ និងថ្នាក់ទី៨ ដល់ការិយាល័យជំនាញ (បឋម,មធ្យម) DTMT និងនាយកសាលា ចំនួន៥២ នាក់រយៈពេល២ ថ្ងៃ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ។

**គ- បញ្ហាប្រឈម**

- ការអនុវត្តសកម្មភាពការងារមិនបានតាមផែនការកំណត់(ថវិកាអនុវត្តមិនបានគ្រប់សកម្មភាព)
- ខ្វះមន្ត្រីក្របខ័ណ្ឌជាអធិការ ដើម្បីជួយការងារអធិការកិច្ច ។

## ៣-អនុសាសន៍ និង ទិសដៅ ឆ្នាំសិក្សា ២០១៧.២០១៨

ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ទាំងបញ្ហាប្រឈមតាមអនុវិស័យ និង បញ្ហាប្រឈមលក្ខណ:អន្តរ អនុវិស័យ និង ផ្អែកលើបទពិសោធន៍កន្លងមក មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មានទិសដៅរបស់ ខ្លួនដូចខាង ក្រោម ៖

## ៣-១-ទិសដៅតាមអនុវិស័យ

### ៣-១-១-អនុវិស័យ ការអប់រំកុមារតូច

- ✓ បន្តប្រមូលកុមារអាយុ ៥ ឆ្នាំ ក្នុងការអប់រំកុមារតូច នៅគ្រប់រូបភាពឱ្យបាន ៥៥%
- ✓ កុមារអាយុពី៤ក្នុងការអប់រំកុមារតូច នៅគ្រប់រូបភាពឱ្យបាន ៤៥%
- ✓ កុមារអាយុពី៣ក្នុងការអប់រំកុមារតូច នៅគ្រប់រូបភាពឱ្យបាន ៣០%
- ✓ ពង្រឹងការអនុវត្តការចុះពិនិត្យតាមដាននៅតាមសាលារៀន
- ✓ ស្នើសុំថវិកាUNICEF និងថវិកា PB ដើម្បីគាំទ្រកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងមត្តេយ្យសិក្សាសហគមន៍
- ✓ បន្តសហការជាមួយដៃគូ អង្គការ អាជ្ញាធរភូមិសង្កាត់ សហគមន៍ មាតាបិតា អាណា-យុំ-ព្យាបាល
- ✓ ពង្រឹងការ គ្រប់គ្រងស្ថិតិ ទិន្នន័យព័ត៌មាន កុមារមានអាយុពី ០ដល់ក្រោម ៦ឆ្នាំ ។
- ✓ បន្តពង្រីកថ្នាក់មត្តេយ្យក្នុងសាលាបឋមសិក្សា ។
- ✓ បន្តកែលម្អបរិស្ថានសាលារៀន ឱ្យទៅជាទីមេត្រីរបស់កុមារ ដោយសហការជាមួយអាជ្ញាធ-មាតាបិតាអាណាព្យាបាលកុមារគណ:កម្មការទ្រទ្រង់សាលារៀន រមូលដ្ឋានសហគមន៍
- ✓ បន្តជួយការងារ បច្ចេកទេស ការផលិត និងប្រើប្រាស់ សម្ភារ ដល់គ្រូមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសហគមន៍ និងកម្មវិធីអប់រំតាមផ្ទះ ។
- ✓ ជំរុញគ្រូបង្រៀនមត្តេយ្យឱ្យសហការជាមួយឪពុកម្តាយ អាណាព្យាបាលជួយបង្រៀន កូននៅផ្ទះស្របតាមកម្មវិធីមត្តេយ្យសិក្សារដ្ឋ ។
- ✓ បំប៉នគ្រូបឋមបង្រៀនថ្នាក់មត្តេយ្យពីបច្ចេកទេសបង្រៀន និងរៀនអោយគ្រប់ស្តង់ដារ១៥ថ្ងៃ ។

### ៣-១-២-អនុវិស័យ ការអប់រំបឋមសិក្សា

- ✓ បង្កើនអត្រាពិតចូលរៀនថ្មី និងអត្រាពិតនៃការសិក្សាឱ្យសម្រេចបានតាមចំណុចដៅ
- ✓ បង្កើនអត្រាបញ្ចប់បឋមសិក្សា តាមសាលាក្នុងក្រុង/ស្រុកឱ្យសម្រេចបានតាមចំណុចដៅ
- ✓ បន្តជំរុញការអនុវត្តម៉ោងសិក្សាឱ្យបានត្រឹមត្រូវ ការរៀបចំរដ្ឋបាលថ្នាក់ កិច្ចតែងការបង្រៀន និងបញ្ជីស្នាមផ្សេងៗ។
- ✓ ពង្រឹងការគ្រប់គ្រងតាមសាលារៀនដោយផ្តោតលើះ

  1.ផែនការអភិវឌ្ឍសាលារៀន

  2.ការគ្រប់គ្រងវត្តមាន

3.ការប្រជុំបច្ចេកទេស

4.ការបង្រៀនថ្ងៃព្រហស្បតិ៍

5.ការបំពេញរបាយការណ៍ផ្សេងៗ

6.ការប្រើប្រាស់ថវិកា។

## ៣-១-៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និង អប់រំបច្ចេកទេស

- ✓ ទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្សត្រឹម18%សម្រាប់បឋមភូមិ និង ទុតិយភូមិ 16%
- ✓ ជំរុញការអនុវត្តពេលម៉ោងសិក្សាឱ្យបានត្រឹមត្រូវនៅមធ្យមសិក្សា
- ✓ បន្តការអនុវត្តកម្មវិធីអាហារូបករណ៍ សិស្ស ក្រីក្រ
- ✓ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីធានាគុណភាពអប់រំ
- ✓ ជំរុញការប្រឡង និងការបង្រៀន សរសេរតាមអាននៅមធ្យមសិក្សាបឋមភូមិ
- ✓ ពង្រឹងការប្រឡង ការគ្រប់គ្រង ការបង្រៀន និងរៀន ឱ្យមានកិច្ចតែងការបង្រៀន សម្ភារឧបទ្ទេស
- ✓ ជំរុញ និងពង្រឹងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅសាលាមធ្យមសិក្សា
- ✓ ជំរុញ និងពង្រឹងការប្រជុំបច្ចេកទេសនៅតាមសាលាមធ្យមសិក្សា
- ✓ ពង្រឹងការបង្រៀនគណិតវិទ្យានិងវិទ្យាសាស្ត្រ
- ✓ ចុះអធិការកិច្ចតាមសាលារៀន ពីការងារគ្រប់គ្រង ការងារបង្រៀន និងរៀន និងការងារបរិស្ថានសាលារៀន ។

## ៣-១-៤ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

- ✓ បើកដំណើរការកម្មវិធីសមមូលបឋមសិក្សាចំនួន១០ថ្នាក់នៅឆ្នាំ២០១៨។
- ✓ បើកវគ្គបំប៉នវិធីសាស្ត្របង្រៀនមនុស្សពេញវ័យដល់គ្រូអក្ខរកម្មចំនួន២០នាក់ រយៈពេល ០៥ ថ្ងៃ (ធ្វើនៅក្រុងសំរោង និងស្រុកអន្លង់វែង)។
- ✓ បើកដំណើរការថ្នាក់អក្ខរកម្មចំនួន២០ថ្នាក់នៅឆ្នាំ២០១៨។
- ✓ បើកដំណើរការកម្មវិធីបង្កើនប្រាក់ចំណូលចំនួន០៧ថ្នាក់ក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន០៤ កន្លែងនៅស្រុកចុងកាល់ បន្ទាយអំពិល និងត្រពាំងប្រាសាទ។
- ✓ បើកវគ្គបំប៉នគ្រូកម្មវិធីចូលរៀនឡើងវិញចំនួន២៣នាក់រយៈពេល០២ថ្ងៃ។
- ✓ បើកដំណើរការកម្មវិធីចូលរៀនឡើងវិញចំនួន២៣ថ្នាក់នៅឆ្នាំ២០១៨។
- ✓ ចុះត្រួតពិនិត្យកម្មវិធីរបស់ការិយាល័យឱ្យបានគ្រប់ក្រុង/ស្រុក។
- ✓ ចុះអធិការកិច្ចតាមសាលា ពីការងារគ្រប់គ្រង ការងារបង្រៀន និងរៀន
- ✓ ពង្រឹងការងារគ្រប់គ្រងលើកម្មវិធីអប់រំក្រៅប្រព័ន្ធឱ្យកាន់តែមានប្រសិទ្ធិភាព និងនិរន្តរភាពដើម្បីឱ្យសម្រេចបានតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំឆ្នាំ២០១៦-២០២០។ បន្តបើកដំណើរការកម្មវិធីអក្ខរកម្ម សមមូលបឋមសិក្សា ចូលរៀនឡើងវិញ និងបង្កើនប្រាក់ចំណូលឱ្យបានគ្រប់ក្រុង/ស្រុកដើម្បីបង្កើនចំណេះដឹងនិង ជីវភាពប្រជាជនក្នុងខេត្តឧត្តរមានជ័យឱ្យកាន់តែប្រសើរឡើង ។

## ៣-១-៥ អនុវិស័យ ការអភិវឌ្ឍយុវជន

- ✓ ផលិតឯកសារ រូបភាពសម្រាប់អប់រំ ដែលពាក់ព័ន្ធនឹងការងារក្រុមប្រឹក្សាកុមារ និងយុវជន ដើម្បីផ្តល់ជូនតាមសាលាសម្រាប់បិទផ្សព្វផ្សាយ និងជាសម្ភារសម្រាប់បង្រៀន។
- ✓ ប្រជុំបូកសរុបចលនា ៣ល្អ ថ្នាក់ខេត្ត ថ្នាក់ក្រុង/ស្រុក និងថ្នាក់សាលារៀន
- ✓ រៀបចំក្លឹបសិក្សារបស់ក្រុមប្រឹក្សាយុវជន និងកុមារតាមសាលារៀន
- ✓ បើកវគ្គបំប៉នដល់សមាជិកក្រុមប្រឹក្សាកុមារ និងយុវជនតាមសាលារៀន
- ✓ ចេញលិខិតសរសើរដល់អង្គភាពដែលមានស្នាដៃល្អ
- ✓ ការប្រជុំបូកសរុបចលនា ៣ល្អ ថ្នាក់ខេត្ត ថ្នាក់ក្រុង/ស្រុក និងថ្នាក់សាលារៀន
- ✓ បន្តផ្សព្វផ្សាយខ្លឹមសារស្តីពីកម្មវិធីអប់រំបំណិនជីវិតដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ផលប៉ះពាល់នៃការប្រើ
- ✓ ប្រាស់ គ្រឿងញៀន គ្រឿងស្រវឹង អំពើហឹង្សា និងមេរោគអេដស៍ ជំងឺអេដស៍ នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ
- ✓ បន្តពង្រឹងក្រុមប្រឹក្សាយុវជន និងកុមារតាមគ្រឹះស្ថានសិក្សា
- ✓ បង្កើត និងជំរុញ ក្លឹបសិក្សារបស់ក្រុមប្រឹក្សាយុវជនតាមសាលារៀន
- ✓ រៀបចំវគ្គបំប៉នដល់សមាជិកក្រុមប្រឹក្សាកុមារ និងយុវជនតាមសាលារៀន
- ✓ ចេញលិខិតសរសើរដល់សមាជិក និងអង្គភាពដែលមានស្នាដៃល្អ
- ✓ បន្តការងារប្រឹក្សាអាជីពតាមរយៈវេទិកាការសិក្សា និងការងារ
- ✓ បង្កើនសកម្មភាពការងារយុវជនស្ម័គ្រចិត្ត

## ៣-១-៦ អនុវិស័យ ការអប់រំកាយ និងកីឡា

- ✓ បញ្ចូលការងារអប់រំកាយ និងកីឡា ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់
- ✓ បន្តរៀបចំការប្រកួតកីឡាថ្នាក់ខេត្តនិងថ្នាក់ក្រុង/ស្រុក
- ✓ បន្តការចូលរួមប្រកួតកីឡាគ្រប់កម្មវិធីទាំងអស់ដែលក្រសួងរៀបចំ
- ✓ ចូលរួមប្រកួតជាលក្ខណៈមិត្តភាពកម្ពុជា -ថៃ
- ✓ បន្តរៀបចំការប្រកួតកីឡាដើម្បីទាំងអស់គ្នា ជ្រើសរើសជើងឯក ថ្នាក់ខេត្ត ប្រចាំឆ្នាំ
- ✓ បន្តផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា
- ✓ សម្រិតសម្រាំងកីឡាករឆ្នើមតាមរយៈការប្រកួតកីឡាសិស្ស និងមហាជន និងប្រកួតជើងឯកថ្នាក់ជាតិ
- ✓ ពង្រឹងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយ ក្នុងម៉ោងសិក្សា នៅតាមគ្រឹះស្ថានសិក្សា
- ✓ ពង្រឹងសមាគមកីឡា ក្លឹបកីឡា នៅតាមគ្រឹះស្ថានសិក្សា និងក្របខ័ណ្ឌ
- ✓ អភិវឌ្ឍធនធានមនុស្សផ្នែកអប់រំកាយ និងកីឡាត្រៀមលក្ខណៈឆ្ពោះទៅឆ្នាំ ២០២៣
- ✓ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តអប់រំកាយ និងកីឡា

## ៣-២- ទិសដៅឆ្លងអនុវិស័យ

### ៣-២-១-ការងាររដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល

- ✓ បន្តអនុវត្តការពង្រាយគ្រូ ដែលស្ម័គ្រចិត្ត អនុវត្តការបែងចែកគ្រូចេញថ្មី ឱ្យដល់សាលាខ្វះគ្រូ និងកើតថ្មី ។
- ✓ បន្តចុះពិនិត្យតាមដានការងារក្របខ័ណ្ឌ (គ្រូចេញថ្មី បង្រៀនពីរវេន គួប និងជាប់កិច្ចសន្យា )
- ✓ បន្តពង្រឹងការងារគ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំឱ្យស្របតាមនិយាម និងការណែនាំរបស់ក្រសួង ។
- ✓ ពង្រឹងការចរាចរលិខិតចេញ-ចូល តាមច្រកចេញចូលតែមួយ អោយមានប្រសិទ្ធិភាព ។
- ✓ ពង្រឹងការអនុវត្តការចុះវត្តមានប្រចាំថ្ងៃរបស់បុគ្គលិកសិក្សា ។
- ✓ ពង្រឹងការរៀបចំទុកដាក់ និងគ្រប់គ្រងលិខិតបទដ្ឋាននានា តាមការណែនាំរបស់ក្រសួង ។
- ✓ ជ្រើសរើស រៀបចំការប្រឡងគ្រូបឋម និងមត្តេយ្យសិក្សា និងមធ្យមសិក្សាតាមតួលេខក្រសួងផ្តល់ឱ្យ ។
- ✓ ជ្រើសរើស និងអនុវត្ត ការជ្រើសរើសគ្រូមូលដ្ឋានតាមប្រព័ន្ធពន្លឿន ទៅជាគ្រូបង្រៀនកម្រិតឧត្តម នៅតាមវិទ្យាល័យខ្វះគ្រូឯកទេស ។
- ✓ បន្តអនុវត្តជ្រើសរើសគ្រូបឋម-មត្តេយ្យសិក្សាមានសញ្ញាបត្រទុតិយភូមិ ទៅបំប៉នជាគ្រូបង្រៀនកម្រិតមូលដ្ឋាន នៅអនុវិទ្យាល័យ តាមការណែនាំរបស់ក្រសួង ។
- ✓ ប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីពេល គួប និងកិច្ចសន្យា
- ✓ គ្រូបឋមជួយបង្រៀនថ្នាក់មត្តេយ្យសិក្សា
- ✓ បន្តអនុវត្តការបង្រៀនម៉ោងបន្ថែម នៅសាលាខ្វះគ្រូ

### ៣-២-២-ការងារផែនការ និង គ្រប់គ្រងជំនួយ

- ✓ បន្តពង្រឹងការគ្រប់គ្រង ការរៀបចំផែនការ ការរៀបចំរបាយការណ៍ និងស្ថិតិ អប់រំ នៅតាមសាលារៀន ការិយាល័យ អប់រំយុវជន និងកីឡា ក្រុងស្រុក តាមរយៈការចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃ លើលទ្ធផលបំពេញការងារ របស់មន្ត្រីអប់រំ ។
- ✓ បំប៉នសមត្ថភាព លើការងារ រៀបចំរបាការណ៍ រៀបចំផែនការ និងការបំពេញ ស្ថិតិអប់រំដល់ថ្នាក់ ក្រុងស្រុក និងសាលារៀន ។
- ✓ ធ្វើការទំនាក់ទំនងជាប្រចាំជាមួយអង្គការដៃគូដើម្បីគៀងគរជំនួយគាំទ្រវិស័យអប់រំ
- ✓ ពង្រឹងការទំនាក់ទំនង ជាមួយដៃគូ ដើម្បីបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ
- ✓ បន្តអនុវត្ត ការបញ្ចូលទិន្នន័យហិរញ្ញប្បទានវិស័យអប់រំ អប់រំតាមប្រព័ន្ធ Online បានទាន់ពេល ។
- ✓ ចុះណែនាំការរៀបចំផែនការប្រតិបត្តិ២០១៨ របាយការណ៍សមិទ្ធកម្ម របាយការណ៍រីកចំរើនសម្រាប់សាលារៀន និងការិយាល័យ អប់រំក្រុងស្រុក ។
- ✓ ប្រជុំក្រុមបច្ចេកទេសចម្រុះ ៤លើកក្នុង១ឆ្នាំ ដោយពិភាក្សាលើ បញ្ហាប្រឈម ដំណោះស្រាយ និង លើកទិសដៅបន្ត ។

- ✓ បញ្ចូល និង ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យអប់រំឱ្យបានត្រឹមត្រូវទាន់ពេល ដោយយកមន្ត្រីក្រុងស្រុកមកជួយបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ ។
- ✓ បើកវគ្គបណ្តុះបណ្តាលពិការរៀបចំផែនការប្រតិបត្តិ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ
- ✓ ពង្រឹងការប្រមូលទិន្នន័យមត្តេយ្យសិក្សាសហគមន៍ ឱ្យបានត្រឹមត្រូវទាន់ពេល
- ✓ រៀបចំផែនការយុទ្ធសាស្ត្រវិស័យ អប់រំ ២០១៩-២០២៣
- ✓ រៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២០-២០២២
- ✓ ចុះជួយរៀបចំរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំនៅថ្នាក់ក្រុងស្រុក
- ✓ រៀបចំសំណើសុំតម្រូវការសៀវភៅសិក្សាគោល និងពង្រឹងការគ្រប់គ្រងទុកដាក់សៀវភៅ
- ✓ ផ្សព្វផ្សាយគោលនយោបាយ កំណែទម្រង់ លិខិតបទដ្ឋានគតិយុទ្ធរបស់ក្រសួងអប់រំ ដល់នាយកសាលា និង មន្ត្រីក្រុងស្រុក ។
- ✓ បន្តរៀបចំផែនការវិនិយោគបីឆ្នាំរំកិលជូនរដ្ឋបាលខេត្តឱ្យបានទាន់ពេលវេលា ។

## ៣-២-៣-ការងារសំណង់

- ✓ បន្តចុះសិក្សាសំណង់អគារសិក្សាដែលត្រូវស្នើសុំសាងសង់ និង ជួសជុល
- ✓ ចុះជួយដល់មន្ត្រីថ្នាក់ក្រុងស្រុកពីការធ្វើតម្រូវការ និងលើកទិសដៅអទិភាពសម្រាប់សាងសង់
- ✓ អគារសិក្សា អណ្តូងទឹកបង្គន់អនាម័យ អាងលាងដៃ ស្រះទឹក និងតម្រូវផ្សេងៗទៀត ។
- ✓ ទំនាក់ទំនងជាមួយដៃគូពាក់ព័ន្ធ ដើម្បីធ្វើសំណើរសុំអគារសិក្សា ។
- ✓ ចុះផ្ទៀងផ្ទាត់បច្ចុប្បន្នភាពសំណង់អគារសិក្សានៅតាមក្រុងស្រុក

## ៣-២-៤-ការិយាល័យ គណនេយ្យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

- ✓ ទំនាក់ទំនងជាមួយអង្គភាពពាក់ព័ន្ធ នូវឯកសារផ្សេងៗ ដើម្បីអនុវត្តថវិកា ឆ្នាំ២០១៨
- ✓ បូកសរុបការបែងចែកថវិកាឆ្នាំ២០១៨ ទៅតាមកម្មវិធី អនុកម្មវិធី ចង្កោមសកកម្ម និងសកម្មភាព និងអាគារធនធាន/សាលារបណ្តាញ (ការិយាល័យជំនាញបែងចែកថវិកាឆ្នាំ ២០១៨)
- ✓ តាមដានការអនុវត្តថវិកា និងការទូទាត់ឲ្យបានទៀងទាត់ និងច្បាស់លាស់ និងសហការគ្នាដើម្បីសម្រេចបាននូវផែនការសកម្មភាព (តាមមាតិកាថវិកាថ្មី នៃប្រកាសលេខ ៥២៣) ។
- ✓ ពង្រឹងភាពជាម្ចាស់ ការដឹកនាំ ការគ្រប់គ្រង និងស្មារតីទទួលខុសត្រូវរបស់កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព **(ឲ្យសមស្របតាមលិខិតបទដ្ឋានផ្សេងៗ)** ។
- ✓ រៀចំផែនការយុត្តិសាស្ត្រថវិកា២០១៩-២០២១(ខែ៣-៥/២០១៨ និងកញ្ចប់ថវិកា/២០១៩)បំប៉នស្តីពី ការពង្រឹងសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធការគ្រោងថវិកានៅតាមគ្រឹះស្ថានសិក្សាសធារណៈ ទូទាំងខេត្ត និងរបាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ឆ្ពោះទៅការប្រើប្រាស់ប្រព័ន្ធFMIS ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឲ្យមានតម្លាភាព គណនេយ្យភាព ប្រសិទ្ធិភាព និងអនុវត្តទាន់ពេវេលាស្របតាមកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣។
- ✓ ពង្រឹងសមត្ថភាពមន្ត្រី/ចុះជួយណែនាំបន្ថែម នូវកិច្ចបញ្ជិកាទាំង ៦មុខ ដល់ក្រុង-ស្រុក និងសាលារៀនដែលថ្មី (លើការធ្វើផែនការថវិកា/ការអនុវត្តថវិកា និងការត្រួតពិនិត្យលទ្ធផល) ។

- ✓ ធ្វើការសម្របសម្រួលជាមួយអង្គភាពពាក់ពន្ធ័ លើសក្ខីបត្រមួយចំនួនឱ្យសមស្របទៅ តាមនិតិវិធី ហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអនុវត្តថវិកាឲ្យមានភាពប្រសើរជាងមុន ។
- ✓ លិតខំប្រមូលសំណុំឯកសារដែលទាក់ទងការចំណាយ-ចំណូល និងការទូទាត់ ក្នុងការប្រើប្រាស់ថវិកាតាមកម្មវិធី។
- ✓ ពង្រឹងសមត្ថភាពមន្ត្រី/ចុះជួយណែនាំបន្ថែម លើការគ្រប់គ្រងសម្ភារ និងទ្រព្យសម្បត្តិរដ្ឋដោយធ្វើការជម្រះសម្ភារបរិក្ខាបច្ចេកទេសនិងសង្ហារឹម ដែលខូចកន្លងមក(តារាងកើន ថយ/ឆ្នាំ ២០១៧ និងជំរុញការធ្វើប័ណ្ណកម្មសិទ្ធិអចលនវត្ថុនូវអង្គភាពដែលមិនបានធ្វើ) ។
- ✓ ក្នុងឆ្នាំ២០១៨ ការិយាល័យជំនាញ និងជំរុញធ្វើតារាងកើន ថយឆ្នាំ២០១៧ (ឲ្យបានមុន ត្រីមាសទី២ នៃឆ្នាំ២០១៨ ) ដើម្បីងាយស្រួលជម្រះសម្ភារ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

## ៣-២-៥ ការងារសុខភាពសិក្សា

- ✓ បើកវគ្គបំប៉នសមត្ថភាពដល់មន្ត្រីទទួលបន្ទុកសុខភាពសិក្សាមិនទាន់បានគ្រប់គ្នា
- ✓ ការផ្គត់ផ្គង់សម្ភារ ដាក់ក្នុងហិបមិនទាន់បានគ្រប់គ្រាន់តាមតម្រូវការ
- ✓ ការពិនិត្យតាមដានមិនទាន់បានគ្រប់សាលា និងតាមតម្រូវការ

## ៣-២-៦ ការងារអធិការកិច្ច

- ✓ ចុះអធិការកិច្ចតាមកាលកំណត់ តាមប្រព័ន្ធអធិការកិច្ចថ្មី ឱ្យបាន ៣៨សាលា ។
- ✓ ចុះពិនិត្យតាមដានការបំប៉ន និងលទ្ធផលប្រឡងឆមាសសិស្សថ្នាក់ទី១២ តាមមុខវិជ្ជា
- ✓ សម្របសម្រួលធ្វើអនុរក្សតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ថ្នាក់ជាតិ ថ្នាក់តំបន់ និងតេស្តវង្វាយតម្លៃសិស្សកម្រិតអន្តរជាតិ សម្រាប់ការអភិវឌ្ឍ (PISA-D)របស់សិស្សនៅតាមគ្រឹះស្ថានសិក្សាក្នុងខេត្ត
- ✓ បើកវគ្គសិក្ខាសាលាផ្សព្វផ្សាយស្តីពីលទ្ធផលចុះការងារអធិការកិច្ចតាមកាលកំណត់ បញ្ញត្តិជានាគុណភាពអប់រំ លទ្ធផលតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងតេស្តវង្វាយតម្លៃសិស្សកម្រិតអន្តរជាតិ (PISA-D) ជូនដល់ ក្រុមDTMT និងនាយកសាលា ។
- ✓ ប្រមូលផែនការចុះអធិការកិច្ច និងរបាយការណ៍ចុះអធិការកិច្ចពីក្រុមDTMTក្រុង/ស្រុក ដើម្បីពង្រឹងយន្ត ការអធិការកិច្ចរបស់ ក្រុមDTMTក្រុង/ស្រុកបន្ថែមទៀត
- ✓ បូកសរុបរបាយការណ៍ចុះអធិការកិច្ចរបស់ក្រុមDTMTក្រុង/ស្រុក មកបន្សឹគ្នាជាមួយរបាយការណ៍អធិការ កិច្ចតាមកាលកំណត់ថ្នាក់មន្ទីរ រួចធ្វើការវិភាគ និងសន្និដ្ឋានដើម្បីរកចំណុចរួមមួយ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំមន្ទីរ និងសួង ដើម្បីរកដំណោះស្រាយ កែលម្អ និងចាត់វិធានការទាន់ពេលវេលា។

## ៣-៣-សំណូមពរ

- ❖ សូមអង្គការដៃគូអភិវឌ្ឍទាំងអស់ជួយផ្ដល់ឯកសារដល់បណ្ណាល័យនៃខេត្តយើងខ្ញុំបន្ថែមទៀត។
- ❖ ស្នើសុំក្រសួងផ្ដល់អាទិភាពក្របខ័ណ្ឌអធិការកិច្ច ដែលមានមូលដ្ឋានក្នុងខេត្តឧត្តរមានជ័យ ។
- ❖ សូមក្រសួងបើកវគ្គបំប៉នដល់មន្ត្រីការិ.អធិការកិច្ច ដែលមិនមែនក្របខ័ណ្ឌជាអធិការស្ដីពីការងារ អធិការកិច្ចបន្ថែមទៀតឱ្យបានគ្រប់ម៉ូឌុលបន្ថែមទៀត ។
- ❖ សូមក្រសួងផ្ដល់ជាវគ្គបំប៉នសមត្ថភាពដល់គ្រូបង្រៀនអប់រំកាយ និងកីឡា លើជំនាញកីឡា
- ❖ សូមឱ្យក្រសួងរៀបចំបញ្ចូលទិន្នន័យក្រុមប្រឹក្សាយុវជន កុមារ ក្នុងEmis ( តារាងPri Sec )
- ❖ ស្នើសុំឱ្យមានម៉ោងដាច់ដោយឡែកសម្រាប់ការងារក្រុមប្រឹក្សាកុមារ និងយុវជន ( ក្នុងកម្មវិធីសិក្សា )
- ❖ សូមថ្នាក់ជាតិជួយកែលម្អ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធកីឡាក្នុងខេត្ត
- ❖ សូមនាយកដ្ឋានសំណង់ នៃក្រសួងអប់រំយុវជន និងកីឡា បើកវគ្គបំប៉នពីបច្ចេកទេសមើលសំណង់ និង ផែនការតម្រូវការសំណង់ ដល់នាយកសាលារៀន និងមន្ត្រីការិយាល័យ អប់រំក្រុងស្រុក ។
- ❖ សូមក្រសួងអប់រំ យុវជន និកីឡា ដៃគូ អង្គការជាតិ អន្តរជាតិ ជួយសាងសង់ និងជួសជុលអគារសិក្សាសរុបចំនួន 52ខ្នងនិងចំនួន 241បន្ទប់ ក្នុងនោះ
    - ○ មត្តេយ្យសិក្សា ចំនួន 2 ខ្នង 10 បន្ទប់
    - ○ បឋមសិក្សា ចំនួន 30 ខ្នង 150 បន្ទប់
    - ○ មធ្យមសិក្សាបឋមភូមិ ចំនួន 3 ខ្នង 15 បន្ទប់
    - ○ មធ្យមសិក្សាទុតិយភូមិ ចំនួន 3 ខ្នង 15 បន្ទប់
    - ○ អន្តេវាសិកដ្ឋាន( ផ្ទះគ្រូបង្រៀន )ចំនួន 14 ខ្នង 51 បន្ទប់
    - ○ សាងសង់អគារឈើទៅជាអគារថ្ម 100អគារ 269បន្ទប់ និង អគារឬស្សីទៅជាអគារថ្ម 9ខ្នង ១៥ បន្ទប់
    - ○ ជួសជុលអគារដែលគ្មាន កម្រាលល្អ65អគារ ដំបូលល្អ47អគារ ជញ្ជាំងល្អ48អគារ ។

## ៣-៤- លទ្ធផលនៃការពិភាក្សាលើប្រធានបទ និង ទិសដៅត្រូវអនុវត្តឆ្នាំសិក្សា ២០១៧-២០១៨

(តារាងឧបសម្ព័ន្ធ ជូនភ្ជាប់)

## ៤-សេចក្តីសន្និដ្ឋាន

តាមរយៈការអនុវត្តការងាររបស់ **មន្ទីរអប់រំ យុវជន និងកីឡាខេត្ត** ក្នុងឆ្នាំសិក្សា ២០១៦-២០១៧កន្លងមក មានសមិទ្ធផលជាច្រើន ដែលបានបង្ហាញក្នុងរបាយការណ៍សន្និបាតអប់រំ តាមអនុវិស័យទាំង៦ លទ្ធផលទាំងនេះបានដោយសារ មានការខិតខំប្រឹងប្រែងអនុវត្ត ប្រកបដោយជោគជ័យ ពីមន្រ្តីអប់រំគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដី មន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សប្បុរសជនក្រៅ និង ក្នុងប្រទេស ធ្វើឱ្យវិស័យអប់រំ យុវជន និងកីឡា ក្នុងខេត្ត មានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ។ ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួន មិនទាន់បានដោះស្រាយ ហើយត្រូវបានលើកទិសដៅអនុវត្តនៅឆ្នាំសិក្សា២០១៧-២០១៨ និង បន្តអនុវត្តកំណែទម្រង់ទាំង១៥ ចំណុច របស់ក្រសួងអប់រំ យុវជន និងកីឡា ។

សូមកាត់ជូនមកក្រុមលេខាធិការដ្ឋាន

ចំណុចត្រូវកែលម្អ

| ទំព័រ | កំហុសឆ្គង/ពាក្យខុស | ពាក្យត្រូវ/ពាក្យកែសម្រួល | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

✂ - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - →

សូមកាត់ជូនមកក្រុមការងារ

ឈ្មោះ ………………………………………………….អង្គភាព…………………………………………………..

សូមមានយោបល់ ឬសំណួរ ក្នុងការពិភាក្សា

| ល-រ | សំណួរ | អនុសាសន៍ | អនុវិស័យ |
|---|---|---|---|
| | | | |

ឈ្មោះ ………………………………………………….អង្គភាព…………………………………………………..

សូមមានយោបល់ ឬសំណួរ ក្នុងការពិភាក្សា

| ល-រ | សំណួរ | អនុសាសន៍ | អនុវិស័យ |
|---|---|---|---|
| | | | |

ឈ្មោះ ………………………………………………….អង្គភាព…………………………………………………..

សូមមានយោបល់ ឬសំណួរ ក្នុងការពិភាក្សា

| ល-រ | សំណួរ | អនុសាសន៍ | អនុវិស័យ |
|---|---|---|---|
| | | | |